ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# ផែនការយុទ្ធសាស្ត្រជាតិ
# សំរាប់
# បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន
# ២០០៨-២០១៥

ឆ្នាំ ២០០៨

# សហការឧបត្ថម្ភដោយ

Centers for Disease Control and Prevention

World Health Organization

unicef

បកប្រែត្រាវផ្លូវការជាភាសាខ្មែរ

# ផែនការយុទ្ធសាស្ត្រជាតិ
# សំរាប់
# បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន
# ២០០៨_២០១៥

ឆ្នាំ ២០០៨

# មាតិកា


**១ សារំតា ............ ៩**

១.១ គោលបំណង ............ ៩

១.២ ការបង្កើតផែនការយុទ្ធសាស្ត្រជាតិសំរាប់បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនឆ្នាំ២០០៨-២០១៥... ៩

**២ ការវិភាគស្ថានភាព និងការឆ្លើយតបទៅនឹងជម្ងឺអេដស៍ ............ ១០**

២.១ វិសាលភាពនៃបន្ទុកជម្ងឺអេដស៍ចំពោះស្ត្រី និងកុមារនៅកម្ពុជា ............ ១០

២.២ ការឆ្លើយតបទៅនឹងការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅកម្ពុជា ............ ១១

២.៣ ការអនុវត្តន៏សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនឆ្នាំ២០០៧ ............ ១៣

២.៤ ឧបសគ្គបន្ថែមចំពោះការធានាសុខសុវត្ថិភាពដល់មាតា ............ ១៧

២.៥ សង្ខេបពីបទពិសោធន៏ដែលទទួលបានកន្លងមកតាមរយៈការឆ្លើយតបទូទាំងប្រទេសទៅនឹងកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ............ ១៧

**៣ អនុសាសន៏សំខាន់ៗបានមកពីការពិនិត្យឡើងវិញរួមគ្នាលើកម្មវិធីជាតិបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនក្នុងឆ្នាំ២០០៧ ............ ១៨**

**៤ ផែនការយុទ្ធសាស្ត្រជាតិសំរាប់បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនឆ្នាំ២០០៨-២០១៥ ............ ១៩**

**ទស្សនៈវិស័យនៃផែនការយុទ្ធសាស្ត្រជាតិ ............ ១៩**

**គោលការណ៏ណែនាំសំខាន់ៗ ............ ២០**

៤.១ គោលដៅនៃផែនការយុទ្ធសាស្ត្រជាតិ ............ ២១

៤.២ គោលបំណងយុទ្ធសាស្ត្រនៃផែនការជាតិ ............ ២១

៤.៣ សកម្មភាពយុទ្ធសាស្ត្រនៃផែនការជាតិ ............ ២២

៤.៣.១ គោលបំណងទី១ ............ ២២

៤.៣.២ គោលបំណងទី២ ............ ២៤

៤.៣.៣ គោលបំណងទី៣ ............ ២៥

៤.៣.៤ គោលបំណងទី៤ ............ ២៦

៤.៤ តារាងម៉ាទ្រីកនៃផែនការយុទ្ធសាស្ត្រជាតិសំរាប់បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ............ ២៨

**៥ ការផ្សារភ្ជាប់ទំនាក់ទំនងលើគ្រប់វិស័យ ............ ៤៧**

**៦ ការតាមដាន និងវាយតម្លៃ ............ ៤៦**

**៧ ចំណុចគោលដៅសុច្ចនករសំខាន់ៗសំរាប់កម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនឆ្នាំ២០០៨-២០១៥ ............ ៤៨**

**៨ ឧបសម្ព័ន្ធ ............................................................................................... ៤៩**

៨.១ ឧបសម្ព័ន្ធទី ១: របៀបគិតចំណុចគោលដៅផ្អែកតាមចំនួនប្រជាជនសំរាប់ថ្នាក់ខេត្ត/ថ្នាក់ស្រុក ...... ៤៩

៨.២ ឧបសម្ព័ន្ធទី ២: វិធានការអនុវត្តន៏សំរាប់ការតាមដាននិងវាយតម្លៃតាមរយៈអនុសាសន៍នៃការពិនិត្យឡើងវិញរួមគ្នាលើកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្ដាយទៅកូនឆ្នាំ២០០៧ .. ៥១

៨.២.១ កសាងសមត្ថភាព និងធ្វើការណែនាំដល់មន្ត្រីបុគ្គលិកនៅគ្រប់កម្រិតទាំងអស់ឱ្យប្រើប្រាស់ទិន្នន័យ ប្រកបដោយប្រសិទ្ធភាព សំរាប់ធ្វើផែនការកម្មវិធី កែលំអកម្មវិធី និងតាមដានអ្នកជម្ងឺ ................................................................ ៥១

៨.២.២ ពិនិត្យឡើងវិញលើប្រព័ន្ធត្រួតពិនិត្យតាមដានកម្មវិធី PMTCT បច្ចុប្បន្ន និងរកឱ្យឃើញ នូវកង្វះខាតទាំងឡាយនៃទិន្នន័យសំខាន់ៗ .................................. ៥២

៨.២.៣ ដាក់បញ្ចូលព័ត៌មាន PMTCT និង HIV ទៅក្នុងសៀវភៅបទដ្ឋានកំណត់ត្រាសម្រាលសៀវភៅសុខភាពម្ដាយ និងទៅក្នុងប័ណ្ណចាក់ថ្នាំបង្ការកុមារ និងធានាថាសៀវភៅកំណត់ត្រាពិនិត្យផ្ទៃពោះថ្មីនេះនឹងឆ្លុះបញ្ចាំងពីបច្ចុប្បន្នភាពនៃប្រព័ន្ធតាមដានកម្មវិធីជាតិ ........................................................................... ៥៤

៨.៣ ឧបសម្ព័ន្ធទី ៣: ព័ត៌មានសំខាន់ៗដែលឆ្លបនៅសេវាថែទាំផ្ទៃពោះទាំងអស់ត្រូវដឹងដើម្បីពន្យល់ដល់ស្ត្រីមានផ្ទៃពោះអំពីសារៈសំខាន់នៃការធ្វើតេស្តឈាមនៅពេលមានផ្ទៃពោះតាមវិធីសាស្ត្រនៃការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមដែលផ្តួចផ្តើមដោយអ្នកផ្តល់សេវា..... ៥៥

៨.៤ ឧបសម្ព័ន្ធទី ៤: និយមន័យនៃសុច្ចនករជាតិសំខាន់ៗ ....................................................... ៥៦

# អក្សរកាត់ សេចក្ដីពន្យល់ជាភាសាខ្មែរ

| | |
|---|---|
| AFASS | ល័ក្ខខ័ណ្ឌ៥យ៉ាងសំរាប់ម្ដាយផ្ទុកមេរោគអេដស៍ដែលចិញ្ចឹមកូនដោយទឹកដោះគោម្សៅ ដូចជា ការទទួលយកបាន ការអាចធ្វើបាន ការលៃលកបាន មាននិរន្តរ៍ភាព និង មានសុវត្ថិភាព |
| AIDS | ជម្ងឺអេដស៍ : ចង្កោមរោគសញ្ញាដែលកើតមានឡើងក្រោយពីប្រព័ន្ធភាពស៊ាំការពាររាងកាយចុះខ្សោយ |
| ANC | ការថែទាំផ្ទៃពោះមុនពេលសម្រាល ឬការពិនិត្យផ្ទៃពោះ |
| ART | ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ |
| ARV | ឱសថប្រឆាំងនឹងមេរោគអេដស៍ |
| AZT | ឱសថឈ្មោះ អេហ្ស៊ិតធី សំរាប់ប្រឆាំងនឹងមេរោគអេដស៍ (Azydothymidine) |
| CBOs | អង្គការដែលមានមូលដ្ឋាននៅសហគមន៍ |
| CDHS | របាយការណ៍អង្កេតសុខភាពប្រជាសាស្ត្រនៅកម្ពុជា |
| CoC | ការថែទាំបន្ត |
| CPA | សំណុំសកម្មភាពបង្គ្រប់ |
| GFATM | មូលនិធិសកលប្រយុទ្ធនឹងជម្ងឺអេដស៍ របេង និងគ្រុនចាញ់ |
| HAART | ការព្យាបាលជម្ងឺអេដស៍ដោយមានឱសថច្រើនមុខរួមបញ្ចូលគ្នា |
| HBC | ការថែទាំនៅតាមផ្ទះ |
| HIV | វីរុសដែលធ្វើឱ្យប្រព័ន្ធការពាររាងកាយមនុស្សចុះខ្សោយ |
| HPITC | ការធ្វើតេស្តឈាម និងផ្តល់ប្រឹក្សាដែលផ្តួចផ្តើមដោយអ្នកផ្តល់សេវាសុខភាព |
| HSS | ការអង្កេតរកប្រេវ៉ាឡង់មេរោគអេដស៍ |
| IYCF | ការចិញ្ចឹមទារក និងកុមារតូចៗ |
| M&E | ការតាមដាននិងវាយតម្លៃ |
| MCH | សុខភាពមាតា និងកុមារ |
| MoH | ក្រសួងសុខាភិបាល |
| MPA | សំណុំសកម្មភាពអប្បបរមា |
| MTCT | ការចម្លងមេរោគអេដស៍ពីម្ដាយទៅកូន |
| NAA | អាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ |
| NCHADS | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និងកាមរោគ |
| NCHP | កម្មវិធីជាតិលើកកំពស់សុខភាព |

| | |
|---|---|
| NGOs | អង្គការមិនមែនរដ្ឋាភិបាល |
| NMCHC | មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក |
| NNP | កម្មវិធីជាតិអាហារូបត្ថម្ភ |
| NRHP | កម្មវិធីជាតិសុខភាពបន្តពូជ |
| NSP | ផែនការយុទ្ធសាស្ត្រជាតិ |
| NVP | ឱសថឈ្មោះ ណេវីរ៉ាពីន សំរាប់ប្រឆាំងនឹងមេរោគអេដស៍ (Nevirapine) |
| OD | ស្រុកប្រតិបត្តិ |
| OI | ជម្ងឺឱកាសនិយម |
| PEP | ការព្យាបាលបង្ការក្រោយប្រឈមនឹងការឆ្លងមេរោគអេដស៍ ( ដោយសារមុត ឬរបួស) |
| PLHA | អ្នកផ្ទុកមេរោគអេដស៍ និងជម្ងឺអេដស៍ |
| PMTCT | ការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន |
| RH | មន្ទីរពេទ្យបង្អែក |
| RHAC | សមាគមរ៉ាក់ |
| SOP | នីតិវិធីប្រតិបត្តិស្តង់ដា |
| STI/STDs | ការបង្ករោគតាមការរួមភេទ/ជម្ងឺកាមរោគ |
| ToR |ល័ក្ខខ័ណ្ឌការងារ (Terms of Reference) |
| TWG | ក្រុមការងារបច្ចេកទេស |
| UNFPA | មូលនិធិសហប្រជាជាតិសំរាប់ប្រជាជន |
| UNGASS | កិច្ចប្រជុំសភាជាន់ខ្ពស់ពិសេសរបស់អង្គការសហប្រជាជាតិ |
| UNICEF | មូលនិធិសហប្រជាជាតិសំរាប់កុមារ |
| US CDC | មជ្ឈមណ្ឌលប្រយុទ្ធ និងបង្ការជម្ងឺឆ្លងសហរដ្ឋអាមេរិក ( យូអេសស៊ីឌីស៊ី) |
| VCCT | ការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ |
| VHSG | ក្រុមទ្រទ្រង់សុខភាពភូមិ |
| WHO | អង្គការសុខភាពពិភពលោក |

# បុព្វកថា

ការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅកម្ពុជាត្រូវបានប៉ាន់ប្រមាណថាមានប្រហែល ១/៣នៃអ្នកឆ្លងមេរោគអេដស៍ថ្មី។ នាពេលបច្ចុប្បន្ននេះ ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍អាចជួយទប់ស្កាត់ការចម្លងមេរោគអេដស៍ពីម្តាយទៅកូនបានដោយជោគជ័យ។ ក្រោមកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍សង្គមស៊ីវិល ព្រមទាំងអង្គការអន្តរជាតិជាច្រើន ក្រសួងសុខាភិបាល នៃព្រះរាជាណាចក្រកម្ពុជាមានឆន្ទៈនឹងលុបបំបាត់ការចម្លងមេរោគអេដស៍ពីម្តាយទៅកូន គឺធ្វើយ៉ាងណាឱ្យកុមារដែលកើតពីម្តាយ ដែលមានផ្ទុកមេរោគអេដស៍បានជៀសផុតពីការឆ្លងមេរោគអេដស៍ពីម្តាយ និងបានរស់រានមានជីវិតប្រកបដោយសុខភាពល្អ។

អេដស៍គឺជាជម្ងឺមួយដ៏កាចសាហាវដែលមកទល់បច្ចុប្បន្ននេះ មិនទាន់មានឱសថណាមួយអាចព្យាបាលជម្ងឺនេះឱ្យជាសះស្បើយបានទេ ថ្វីត្បិតតែមានឱសថប្រឆាំងមេរោគអេដស៍ក៏ពិតមែន តែឱសថទាំងនោះមានលទ្ធភាពគ្រាន់តែជួយពន្យារជីវិតដល់អ្នកផ្ទុកមេរោគអេដស៍ឱ្យរស់នៅបានយូរតែប៉ុណ្ណោះ។ ស្ត្រីភាគច្រើនដែលបានឆ្លងមេរោគអេដស៍ពីបុរសជាស្វាមី ឬដៃគូ មិនបានដឹងថាខ្លួន មានផ្ទុកមេរោគអេដស៍នោះទេ ដោយសារតែមេរោគអេដស៍អាចរស់នៅក្នុងខ្លួនមនុស្សបានរយៈពេលយូរឆ្នាំដោយគ្មានរោគសញ្ញា អ្វីឡើយ។ ជាយថាហេតុ មេរោគអេដស៍អាចចម្លងពីម្តាយទៅកូនរបស់គាត់នៅពេលដែលគាត់មានផ្ទៃពោះ នៅពេលសំរាល និង នៅពេលបំបៅដោះកូន។ ឱសថប្រឆាំងមេរោគអេដស៍ដែលប្រើសំរាប់ព្យាបាល ក៏អាចប្រើសំរាប់បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនផងដែរ។ ហេតុដូច្នេះហើយ ការជំរុញលើកទឹកចិត្តឱ្យស្ត្រីជាម្តាយធ្វើតេស្តឈាមរកមេរោគអេដស៍នៅពេលមានផ្ទៃពោះនៅពេលឈឺពោះសម្រាល ឬមុនពេលសំរាលគឺជាការសំខាន់ណាស់។ ធ្វើដូច្នេះស្ត្រីអាចទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍បានទាន់ពេលវេលាដើម្បីបង្ការកុំឱ្យមេរោគអេដស៍ចម្លងពីម្តាយទៅកូនបាន។

តាងនាមឱ្យក្រសួងសុខាភិបាល ខ្ញុំសូមគាំទ្រដល់គម្រោងផែនការយុទ្ធសាស្ត្រជាតិសំរាប់បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ដែលជាចំណែកមួយក្នុងការជួយទប់ស្កាត់ការឆ្លងរាលដាលនៃជម្ងឺអេដស៍នៅកម្ពុជា និងធ្វើឱ្យសុខភាពមាតានិងកុមារកាន់តែមានភាពប្រសើរឡើង។ ខ្ញុំសង្ឃឹមថាកុមារទាំងឡាយដែលកើតពីម្តាយផ្ទុកមេរោគអេដស៍នឹងមានសុខភាពល្អ គ្មានឆ្លងមេរោគអេដស៍ដោយសារតែយើងមានផែនការយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធិភាពនេះជាមគ្គុទ្ទេសក៍។

ទោះបីជាយ៉ាងណាក៏ដោយ ផែនការយុទ្ធសាស្ត្រនេះគ្រាន់តែជាដំណាក់កាលដំបូងតែប៉ុណ្ណោះ ។ ដើម្បីធ្វើឱ្យសុបិនរបស់យើងក្លាយជាការពិតបាន លុះត្រាតែយើងទាំងអស់រួមគ្នាអនុវត្តនូវផែនការយុទ្ធសាស្ត្រនេះឱ្យបានទូលំទូលាយ ។ ខ្ញុំជឿជាក់ថាការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល មន្ត្រីសុខាភិបាល ថ្នាក់ដឹកនាំសង្គមស៊ីវិល និងកិច្ចសហការល្អជាមួយដៃគូអភិវឌ្ឍន៍នឹងធ្វើឱ្យយើងសំរេចគោលដៅដែលបានកំណត់ដោយជោគជ័យ ។

ភ្នំពេញ ថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៨

**ឯឧ. សាស្ត្រាចារ្យ អេង ហួត**
រដ្ឋលេខាធិការក្រសួងសុខាភិបាល

# សេចក្តីថ្លែងអំណរគុណ

ផែនការយុទ្ធសាស្ត្រជាតិសំរាប់បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនឆ្នាំ២០០៨-២០១៥ បានរៀបរៀងឡើងដោយមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក រួមសហការជាមួយគ្រប់ដៃគូទាំងអស់ដែលកំពុងតែចូលរួមក្នុងការកាត់បន្ថយការចម្លងមេរោគអេដស៍ពីម្តាយទៅកូន និងក្រោមការជួយឧបត្ថម្ភជាថវិកានិងបច្ចេកទេសពីអង្គការសុខភាពពិភពលោក អង្គការយូនីសេហ្វ និង យូអេសស៊ីឌីស៊ី។ ផែនការយុទ្ធសាស្ត្រនេះនឹងក្លាយជាមគ្គុទ្ទេសក៏ដ៏ប្រសើរមួយសំរាប់ជំរុញការអនុវត្តន៍កម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនឱ្យកាន់តែមានសន្ទុះលឿនទៅមុខ និងកាន់តែមានភាពប្រសើរឡើង។

មជ្ឈមណ្ឌលជាតិគាំពារមាតានិងទារកសូមថ្លែងអំណរគុណដល់លោក-លោកស្រីទាំងអស់ ដែលបានរួមចំណែកក្នុងការរៀបចំផែនការយុទ្ធសាស្ត្រជាតិសំរាប់បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនឆ្នាំ២០០៨-២០១៥ ឱ្យលេចចេញជារូបរាងឡើង។ ខ្ញុំសូមថ្លែងអំណរគុណជាពិសេសចំពោះសមាជិកសមាជិកានៃក្រុមការងារបច្ចេកទេសបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ដែលបានចំណាយពេលវេលាដ៏មានតម្លៃផ្តល់មតិយោបល់ក្នុងការស្ថាបនាលំអសៀវភៅនេះ។

ភ្នំពេញ, ថ្ងៃទី ១៥ ខែឧសភា ឆ្នាំ២០០៨

**សាស្ត្រាចារ្យ គុំ ភាណារ៉ាល់**

ប្រធានមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក

# ១ សាវតា

## ១.១ វត្ថុបំណង

ផែនការយុទ្ធសាស្ត្រសំរាប់បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនឆ្នាំ២០០៨-២០១៥ មានគោលបំណងនឹងធ្វើជាផែនទីបង្ហាញផ្លូវមួយ ដើម្បីលើកកំពស់ការផ្តល់សេវាសុខភាពបន្តពូជដល់ស្ត្រីមានផ្ទៃពោះនិងកូនរបស់គាត់ឱ្យកាន់តែមានភាពប្រសើរឡើង។ ផែនការយុទ្ធសាស្ត្រនេះបានកំណត់ពីកញ្ចប់សកម្មភាពសំរាប់អនុវត្តសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ដែលក្នុងនោះមានបញ្ជាក់ពីគោលបំណងយុទ្ធសាស្ត្រ និងអំពីសកម្មភាពដែលត្រូវធ្វើដើម្បីពន្លឿនការគ្របដណ្តប់សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ឱ្យកាន់តែមានសន្ទុះលឿនទៅមុខបានឆាប់រហ័សឈានទៅសម្រេចគោលដៅនៃកិច្ចប្រជុំសភាជាន់ខ្ពស់ពិសេសរបស់អង្គការសហប្រជាជាតិ ដែលហៅកាត់ថា យូអិនហ្គាស ក្នុងការកាត់បន្ថយអត្រាឆ្លងមេរោគអេដស៍លើកុមារ ដែលកើតពីម្តាយផ្ទុកមេរោគអេដស៍ឱ្យនៅត្រឹម៥០%នៅឆ្នាំ២០១០ ហើយនិងធ្វើឱ្យអត្រានេះចុះថយជាបន្តបន្ទាប់ទៅទៀត។

## ១.២ ការបង្កើតផែនការយុទ្ធសាស្ត្រជាតិសំរាប់បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនឆ្នាំ២០០៨-២០១៥

ឆ្លើយតបទៅនឹងលទ្ធផលដែលមិនសូវល្អប្រសើរនៃការធ្វើតេស្តឈាមរកមេរោគអេដស៍ដល់ស្ត្រីមានផ្ទៃពោះ និងការផ្តល់ឱសថប្រឆាំងមេរោគអេដស៍ដើម្បីបង្ការ និងព្យាបាលដល់ស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍នៅកម្ពុជា ការិយាល័យនៃកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន បានស្នើឱ្យធ្វើការពិនិត្យឡើងវិញមួយដើម្បីវាយតម្លៃលើការអនុវត្តន៍កម្មវិធីកន្លងទៅ។ ការពិនិត្យឡើងវិញលើកម្មវិធីនេះ ត្រូវបានធ្វើឡើងដោយមានជំនួយបច្ចេកទេសពីទីប្រឹក្សាអន្តរជាតិនៃអង្គការយូនីសេហ្វ អង្គការសុខភាពពិភពលោក យូអេសស៊ីឌីស៊ី និងធានាគារពិភពលោក រួមជាមួយដៃគូអភិវឌ្ឍន៍នានា និងមន្ត្រីសុខាភិបាលពីគ្រប់ស្ថាប័ន ខេត្ត-ក្រុងដែលកំពុងតែអនុវត្តកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន។ ដំណើរការពិនិត្យឡើងវិញរួមគ្នានេះ បានប្រព្រឹត្តទៅកាលពីខែសីហា រហូតដល់ខែកញ្ញា ឆ្នាំ២០០៧។ អនុសាសន៍ទាំងឡាយដែលជាលទ្ធផលនៃការពិនិត្យឡើងវិញរួមគ្នា ត្រូវបានអនុម័តនិងផ្សព្វផ្សាយដោយក្រសួងសុខាភិបាល (របាយការណ៍ពិនិត្យឡើងវិញរួមគ្នាលើកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនឆ្នាំ ២០០៧)។

អនុសាសន៍ទីមួយក្នុងចំណោមអនុសាសន៍សំខាន់ៗទាំងបួនដែលផ្តល់ដោយក្រុមត្រួតពិនិត្យរួមគ្នានេះ បានលើកឡើងថា " គេត្រូវបង្កើត និងអនុវត្តយុទ្ធសាស្ត្រជាតិសំរាប់បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងរៀបចំផែនការពង្រីកគម្រោងសកម្មភាពដែលមានបញ្ជាក់ពីតម្រូវការថវិកា ពេលវេលាជាក់លាក់ និងមានគោលដៅចំណុចដែលផ្តែកលើចំនួនប្រជាជន ដែលយុទ្ធសាស្ត្រនេះនឹងជំរុញឱ្យមានការបណ្តុះនូវគំនិតផ្តួចផ្តើមថ្មីៗ" (របាយការណ៍ពិនិត្យឡើងវិញរួមគ្នា លើកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនឆ្នាំ ២០០៧)។

បន្ទាប់ពីការផ្សព្វផ្សាយនូវលទ្ធផលនៃការពិនិត្យឡើងវិញរួមគ្នានេះ ក្រុមការងារបច្ចេកទេសបានលើកយកអនុសាសន៍ទាំងនេះជា អាទិភាពដោយផ្សារភ្ជាប់អនុសាសន៍ទាំងនោះទៅនឹងយុទ្ធសាស្ត្រ សកម្មភាពសុច្ចនករ និងគោលដៅចំណុចជាក់លាក់ដើម្បីប្រុងប្រៀបរៀបចំបង្កើតផែនការយុទ្ធសាស្ត្រជាតិសំរាប់បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន។ ដោយមានជំនួយបច្ចេកទេស ពីទីប្រឹក្សាអន្តរជាតិដែលបានរៀបចំពង្រាងច្បាប់ដើមនៃផែនការយុទ្ធសាស្ត្រសំរាប់

បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន កិច្ចប្រជុំថ្នាក់ជាតិមួយត្រូវបានរៀបចំឡើងដើម្បីពិភាក្សាស្វែងរកមតិជាឯកច្ឆន្ទ ដោយមានការចូលរួមពីគ្រប់តំណាងដៃគូអភិវឌ្ឍន៍ និងមន្ត្រីសុខាភិបាលរដ្ឋាភិបាលខេត្ត-ក្រុងដែលទទួលខុសត្រូវលើការអនុវត្តន៍កម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន។ មតិយោបល់ដែលទទួលបានពីកិច្ចពិភាក្សាត្រូវបានដាក់បញ្ចូលទៅក្នុងគម្រោងផែនការ និងធ្វើការកែសំរួលជាបន្តបន្ទាប់ដោយក្រុមការងារបច្ចេកទេស ក្រោមកិច្ចសហការជាមួយការិយាល័យបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន។

ដំណើរការរៀបចំធ្វើផែនការយុទ្ធសាស្ត្រនេះមានគោលបំណងប្រមូលផ្តុំគំនិតឱ្យបានច្រើនពីអ្នកជំនាញពីខាងក្រៅក៏ដូចជាពីការចូលរួមយ៉ាងច្រើនពីសំណាក់ដៃគូធ្វើការនៅក្នុងស្រុក។ លទ្ធផលដែលបានមកគឺជាផែនការយុទ្ធសាស្ត្រជាតិមួយដែលនឹងធ្វើជាផ្លូវត្រួសត្រាយដ៏មានប្រសិទ្ធិភាព សំដៅឈានទៅសំរេចបាននូវគោលដៅជាតិ និងគោលដៅនៃយូអិនហ្គាស (UNGASS) ក្នុងការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន។

## ២. ការវិភាគស្ថានភាពនិងការឆ្លើយតបទៅនឹងជម្ងឺអេដស៍

### ២.១ វិសាលភាពនៃបន្ទុកជម្ងឺអេដស៍ចំពោះស្ត្រីនិងកុមារនៅកម្ពុជា

មេរោគអេដស៍ត្រូវបានស្រាវជ្រាវរកឃើញជាលើកដំបូងនៅឆ្នាំ១៩៩១ និងករណីនៃជម្ងឺអេដស៍ដំបូងត្រូវបានរកឃើញនៅឆ្នាំ១៩៩៣។ នៅឆ្នាំ១៩៩៨ អត្រាឆ្លងនៃមេរោគអេដស៍មាន២%ក្នុងចំណោមប្រជាជនទូទៅដែលមានវ័យចន្លោះពី១៥-៤៩ឆ្នាំ ដែលជាអត្រាខ្ពស់ជាងគេបំផុតនៅក្នុងតំបន់អាស៊ី[១]។ របាយការណ៍ឆ្នាំ២០០៦នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និង កាមរោគស្តីពីការប៉ាន់ប្រមាណអត្រាឆ្លងនៃមេរោគអេដស៍និងការប៉ាន់រំកិលសំរាប់ឆ្នាំ២០០៦-២០១២ បានឱ្យដឹងថា មេរោគអេដស៍ បានឆ្លងរាលដាលជាដំបូងពីស្ត្រីរកស៊ីផ្លូវភេទមកអតិថិជនរបស់គាត់។ ចាប់ពីឆ្នាំ១៩៩៨ ដល់ឆ្នាំ២០០៦ អត្រាឆ្លងនៃមេរោគអេដស៍បានធ្លាក់ចុះជាលំដាប់រហូតមកនៅត្រឹម ០.៩%[២] ដែលមួយផ្នែកតូចនៃការធ្លាក់ចុះនេះបណ្តាលមកពីការស្លាប់របស់អ្នកជម្ងឺអេដស៍មុនពេលពេលមានសេវាព្យាបាលជម្ងឺអេដស៍ និងមួយផ្នែកធំទៀតគឺដោយសារជោគជ័យនៃកម្មវិធីប្រើប្រាស់ស្រោមអនាម័យ១០០ភាគរយ និងកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការទប់ស្កាត់ជម្ងឺអេដស៍តាមមធ្យោបាយផ្សេងៗជាច្រើនទៀត ដោយរួមសហការយ៉ាងជិតស្និទ្ធជាមួយគ្រប់អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល។ ជាមួយគ្នានេះដែរ អត្រាឆ្លងនៃមេរោគអេដស៍នៅក្នុងចំណោមស្ត្រីដែលមកពិនិត្យផ្ទៃពោះនៅតាមមណ្ឌលសុខភាពក៏បានធ្លាក់ចុះផងដែរ គឺពី២.១%នៅឆ្នាំ១៩៩៨ មកនៅត្រឹម ១.១% នៅឆ្នាំ២០០៦[៣]។

ទោះបីជាយ៉ាងណាក៏ដោយ នៅខណៈដែលអត្រាប្រេវ៉ាឡង់ និងអត្រាឆ្លងមេរោគអេដស៍ថ្មីបានធ្លាក់ចុះក្នុងស្រទាប់ក្រុមប្រឈមខ្ពស់ ដែលបានបញ្ជាក់នៅក្នុងការធ្វើអង្កេតអេពីដេមីសាស្ត្រ (ដូចជាក្រុមស្ត្រីរកស៊ីផ្លូវភេទដោយផ្ទាល់ ដោយប្រយោល ក្រុមប៉ូលីស និងក្រុមទាហាន) មេរោគអេដស៍បាននឹងកំពុងតែរាលដាលមកលើស្ត្រីមេផ្ទះកាន់តែច្រើនឡើង។ សមាមាត្រនៃស្ត្រីផ្ទុកមេរោគអេដស៍ក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍ទាំងអស់បានកើនឡើងពី

---

[1] Consensus Workshop on Estimation of HIV Prevalence 2007, NCHADS/MoH
[2] Ibid
[3] Ibid

៣៥%នៅឆ្នាំ១៩៩៨ ទៅ៥២.១% នៅឆ្នាំ២០០៦ (របាយការណ៍អង្កេតពីមេរោគអេដស៍ឆ្នាំ១៩៩៨ និង របាយការណ៍ឆ្នាំ ២០០៧ ស្តីពីការប៉ាន់ប្រមាណពីអត្រាឆ្លងមេរោគអេដស៍ និងការប៉ាន់រំកិលសំរាប់ឆ្នាំ២០០៦-២០១២)។ នេះគឺជាសញ្ញានៃបំលាស់ប្តូរអេពីដេមីសាស្ត្រពី "រលកទីមួយ" ដែលសន្ទុះនៃការឆ្លង បានកើតឡើងនៅលើក្រុមស្ត្រីរកស៊ីផ្លូវភេទ និងអតិថិជនរបស់ពួកគេមក "រលកទីពីរ"ដែលមេរោគអេដស៍បានឆ្លងរាលដាលមកលើស្ត្រីមេផ្ទះ (និងបន្ទាប់ មកទៀតគឺការឆ្លងទៅកូនរបស់គាត់)។ បំលាស់ប្តូរនៃការឆ្លងរាលដាលនៃមេរោគអេដស៍លើយេនដ៏នេះ បានគូសបញ្ជាក់ពីសារៈសំខាន់នៃកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនដ៏មានប្រសិទ្ធិភាពមួយនៅកម្ពុជា ដើម្បីកាត់បន្ថយឱ្យបានក្នុងកំរិតជាអប្បបរិមានូវចំនួនកុមារ ដែលឆ្លងមេរោគអេដស៍ពីម្តាយ។

## ២.២ ការឆ្លើយតបទៅនឹងកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅកម្ពុជា

ដើម្បីជាការឆ្លើយតបទៅនឹងបញ្ហានៃការចម្លងមេរោគអេដស៍ពីម្តាយទៅកូន នាឆ្នាំ១៩៩៩ ក្រសួងសុខាភិបាលបានបង្កើតក្រុមការងារបច្ចេកទេសមួយ សំរាប់រៀបចំកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនដែលមានមជ្ឈមណ្ឌលគាំពារមាតា និងទារក និងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែកនិង កាមរោគជាសហប្រធាន។ ហើយនៅឆ្នាំ២០០០ ក្រសួងសុខាភិបាល ក៏បានបង្កើតជាគោលនយោបាយជាតិស្តីពីកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូននេះឡើង។ ក្នុងឆ្នាំ ២០០១ កម្មវិធីសាកល្បងសំរាប់បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនបានដំណើរការជាលើកដំបូងនៅមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារកនៅក្នុងទីក្រុងភ្នំពេញ ដោយអនុវត្តវិធីផ្តល់សេវាប្រឹក្សា និងធ្វើតេស្តឈាមតាមការស្ម័គ្រចិត្តរបស់ស្ត្រីមានផ្ទៃពោះនិងដៃគូរបស់គាត់ រួមទាំងការផ្តល់នូវឱសថណេវីរ៉ាពីនចំនួនមួយដូសគត់ដល់ស្ត្រីផ្ទុកមេរោគអេដស៍នៅពេលឈឺពោះសំរាល ព្រមទាំងកូនរបស់គាត់ក្រោយពេលសំរាល ដើម្បីបង្ការការឆ្លងមេរោគអេដស៍ពីម្តាយទៅកូន។ នៅឆ្នាំ២០០៣ កម្មវិធីបានពង្រីកសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនបានចំនួន ៨កន្លែង ហើយរហូតមកដល់ចុងឆ្នាំ២០០៧នេះ សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនមានទាំងអស់ចំនួន ៩៨កន្លែង ហើយនៅទូទាំងប្រទេស។ ក្នុងចំណោមមណ្ឌលសុខភាពសាធារណៈទាំងអស់ដែលមានសេវាថែទាំផ្ទៃពោះចំនួន ៩៥៦[4] កន្លែង មានមណ្ឌលសុខភាពចំនួន ៩៥អាចដំណើរការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមដល់ស្ត្រីមានផ្ទៃពោះព្រមទាំងដៃគូរបស់គាត់ ដែលក្នុងនោះរួមមានមន្ទីរពេទ្យជាតិចំនួន២ មន្ទីរពេទ្យបង្អែកចំនួន៤៩ (មន្ទីរពេទ្យបង្អែកចំនួន ៣គ្មានសេវាពិនិត្យផ្ទៃពោះទេ) មណ្ឌលសុខភាពចំនួន ២៣ (មណ្ឌលសុខភាពដែលនៅក្រៅបរិវេណនៃមន្ទីរពេទ្យ) និងមណ្ឌលសុខភាពដែលជាអតីតមន្ទីរពេទ្យស្រុកចំនួន២១។ បន្ថែមពីលើគ្រឹះស្ថានសុខាភិបាល មានគ្លីនិករ៉ាក់ចំនួន១៦កន្លែងផ្សេងទៀតកំពុង តែផ្តល់សេវាប្រឹក្សា និងធ្វើតេស្តឈាមដល់ស្ត្រីមានផ្ទៃពោះផងដែរ។ សរុបមកនៅឆ្នាំ២០០៧ មានគ្លីនិកថែទាំផ្ទៃពោះទាំងអស់ចំនួន ១១១កន្លែង ដែលអាចផ្តល់សេវាប្រឹក្សានិងធ្វើតេស្តឈាមដល់ស្ត្រីមានផ្ទៃពោះនិងដៃគូរបស់គាត់។

នៅខែកញ្ញាឆ្នាំ២០០៥ កម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនបានធ្វើការកែសំរួលពីរបៀបប្រើប្រាស់ឱសថប្រឆាំងមេរោគអេដស៍ចំពោះស្ត្រីមានផ្ទៃពោះ ដោយប្តូរពីការប្រើឱសថណេវីរ៉ាពីនតែមួយដូសគត់នៅពេលឈឺពោះសំរាលមកជាការប្រើឱសថប្រឆាំងមេរោគអេដស៍ច្រើនមុខរួមផ្សំគ្នាវិញ តាមគោលការណ៍ណែនាំរបស់អង្គការសុខភាពពិភពលោក ដើម្បីបង្កើនប្រសិទ្ធិភាពនៃការព្យាបាលបង្ការដល់ស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍។

[4] Department of Planning and Information, MoH,2007.

នៅខែឧសភា ឆ្នាំ២០០៦ វិធីសាស្ត្រនៃការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមដល់ស្ត្រីមានផ្ទៃពោះត្រូវបានប្តូរពីការធ្វើតេស្តឈាមដែលផ្តួចផ្តើមដោយអតិថិជន (អុបអ៊ីន) មកជាការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមដែលផ្តួចផ្តើមឡើងដោយអ្នកផ្តល់សេវាវិញ (អេចភីអាយធីស៊ី)។ វិធីសាស្ត្រនេះត្រូវបានអនុវត្តជាដំបូង នៅមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក និងបន្ទាប់មកត្រូវបានផ្សព្វផ្សាយអនុវត្តនៅតាមមណ្ឌលដទៃៗទៀត។ វិធីសាស្ត្រនៃការធ្វើតេស្តឈាមបែបថ្មីនេះមានគោលបំណងធ្វើយ៉ាងណា ជួយឱ្យស្ត្រីមានផ្ទៃពោះដែលមកពិនិត្យសុខភាពនៅមណ្ឌលសុខភាព មានឱកាសបានទទួលសេវាធ្វើតេស្តឈាមបានគ្រប់ៗគ្នា ទោះបីជាមណ្ឌលសុខភាពមាន ឬគ្មានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនក្តី។ ស្ត្រីមានផ្ទៃពោះដែលរកឃើញថាមានផ្ទុកមេរោគអេដស៍នឹងត្រូវបានបញ្ជូនទៅទទួលសេវាព្យាបាលជម្ងឺឱកាសនិយមនិងជម្ងឺអេដស៍ដែលនៅជិតបំផុតដើម្បីទទួលឱសថប្រឆាំងមេរោគអេដស៍ និងត្រូវបានលើកទឹកចិត្តឱ្យមកសំរាលកូននៅមន្ទីរពេទ្យដែលមានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនផងដែរ។ ព័ត៌មានស្តីពីការបង្ការបឋមត្រូវបានផ្តល់ជូនដល់ស្ត្រី និងដៃគូដែលមានលទ្ធផលតេស្តអវិជ្ជមាន។ រីឯព័ត៌មានស្តីពីជម្រើសនៃការចិញ្ចឹមកូនឱ្យបានត្រឹមត្រូវក៏បានផ្តល់ជូនដល់ស្ត្រីផ្ទុកមេរោគអេដស៍ផងដែរ។

## ផែនទីបង្ហាញពីទីតាំងមណ្ឌលសុខភាពដែលមានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅកម្ពុជា



## ២.៣ ការអនុវត្តន៍សេវាបង្ការការចម្លងមេរោគអេដស៍ពីម្ដាយទៅកូនឆ្នាំ២០០៧

ឆ្លងតាមរយៈលទ្ធផលនៃការអនុវត្តន៏កម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្ដាយទៅកូនក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ គេសង្កេតឃើញថា ភាគរយនៃស្ត្រីមានផ្ទៃពោះស្ម័គ្រចិត្តធ្វើតេស្តឈាមរកមេរោគអេដស៍ និងបានមកទទួលលទ្ធផលតេស្តឈាមមានកំណើនកើនឡើងជាលំដាប់ក្នុងចំណោមស្ត្រីដែលមកទទួលសេវាពិនិត្យផ្ទៃពោះលើកទី១ នៅមណ្ឌលដែលមានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្ដាយទៅកូន។ ជាមួយគ្នានេះដែរ ភាគរយនៃស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ដែលបានទទួលឱសថប្រឆាំងមេរោគអេដស៍ដើម្បីព្យាបាលឬបង្ការនៅឯសេវាព្យាបាលជម្ងឺឱកាសនិយមនិងជម្ងឺអេដស៍ និងនៅឯមន្ទីរសំរាលដែលមានសេវាបង្ការការចម្លងមេរោគអេដស៍ ក៏មានកំណើនកើនឡើងច្រើនផងដែរ។ នេះគឺជាជោគជ័យមួយដែលគួរឱ្យកត់សំគាល់របស់ក្រសួងសុខាភិបាល។ តែទោះបីជាយ៉ាងណាក៏ដោយ នៅខណៈដែលវិធីសាស្ត្រនៃការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាម ដែលផ្តួចផ្តើមដោយអ្នកផ្តល់សេវាកំពុងតែទទួលជោគជ័យយ៉ាងខ្លាំងក្នុងការធ្វើឱ្យអត្រាធ្វើតេស្តឈាមស្ត្រីមានផ្ទៃពោះកើនឡើង នៅតាមគ្រឹះស្ថានសុខាភិបាលដែលមានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្ដាយទៅកូន នៅមានមណ្ឌលសុខភាពប្រមាណ៩០០កន្លែងទៀតដែលមិនទាន់បានទទួលជោគជ័យក្នុងការជំរុញឱ្យស្ត្រីមានផ្ទៃពោះឱ្យបានធ្វើតេស្តឈាមគ្រប់ៗគ្នានៅឡើយទេ ដោយសារតែទីនោះមានផ្តល់ត្រឹមតែសេវាពិនិត្យពិគ្រោះផ្ទៃពោះតែប៉ុណ្ណោះ នៅមិនទាន់មានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្ដាយទៅកូននេះនៅឡើយនោះទេ ។

ទិន្នន័យខាងក្រោមនេះ បង្ហាញពីបន្ទុកនៃការចម្លងមេរោគអេដស៍ពីម្ដាយទៅកូន និងលទ្ធផលនៃការអនុវត្តន៏សេវាបង្ការការចម្លងមេរោគអេដស៍ពីម្ដាយទៅកូននៅកម្ពុជានៅឆ្នាំ២០០៧។

នៅឆ្នាំ២០០៧ ក្នុងចំណោមស្ត្រី ៩១,០២១នាក់ ដែលបានមកពិនិត្យផ្ទៃពោះលើកទី១នៅមណ្ឌលសុខភាពដែលមានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្ដាយទៅកូន និងនៅគ្លីនិករ៉ាក់ មានស្ត្រីចំនួន៧២,៤៩៥នាក់ (៧៩.៦%) បានស្ម័គ្រចិត្តធ្វើតេស្តឈាម និងមានស្ត្រីចំនួន ៦៦,១៨៦នាក់ (៧២.៧%) បានទទួលលទ្ធផលតេស្តឈាម។ ក្នុងចំណោមស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ទាំង ៧៦៩នាក់ ដែលគេបានរកឃើញនៅសេវាថែទាំផ្ទៃពោះ មានស្ត្រីចំនួន ៥១២នាក់ បានទទួលការធ្វើតេស្តរកមេរោគអេដស៍ នៅឯគ្លីនិកសុខភាពរបស់រដ្ឋាភិបាល និងនៅគ្លីនិករ៉ាក់ ហើយស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ចំនួន ២៥៧នាក់ផ្សេងទៀត ត្រូវបានបញ្ជូនពីសេវានានា ដូចជាសេវាព្យាបាលជម្ងឺអេដស៍ សេវាធ្វើតេស្តឈាមរកមេរោគអេដស៍ គ្លីនិករបស់អង្គការមិនមែនរដ្ឋាភិបាល និងពីគ្លីនិកផ្សេងៗទៀត ឱ្យមកទទួលសេវាពិនិត្យផ្ទៃពោះនៅឯមណ្ឌលសុខភាពដែលមានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្ដាយទៅកូន ព្រោះគ្លីនិកទាំងនោះគ្មានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្ដាយទៅកូនទេ។

នៅក្នុងឆ្នាំដដែល មានស្ត្រីផ្ទុកមេរោគអេដស៍ចំនួន៥៣០នាក់បានមកសំរាលកូននៅឯមន្ទីរពេទ្យដែលមានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្ដាយទៅកូន។ ក្នុងចំណោមស្ត្រីផ្ទុកមេរោគអេដស៍ទាំងនោះ មានតែស្ត្រីចំនួន៥០៥នាក់ទេដែលបានទទួលឱសថប្រឆាំងមេរោគអេដស៍ រួមជាមួយកូនរបស់គាត់ដើម្បីបង្ការការចម្លងមេរោគអេដស៍។ ស្ត្រីផ្ទុកមេរោគអេដស៍ចំនួន២៥នាក់ទៀត មិនបានទទួលឱសថប្រឆាំងមេរោគអេដស៍ទេ ទាំងនៅពេលមានផ្ទៃពោះ ទាំងនៅពេលសំរាល ដោយមូលហេតុគាត់មកសំរាលកូនយឺតពេល។ ទារកចំនួន ៥១៧នាក់ ដែលកើតពីម្ដាយផ្ទុកមេរោគ

អេដស៍បានទទួលឱសថប្រឆាំងមេរោគអេដស៍ដើម្បីបង្ការ ដោយរួមបញ្ចូលទាំងកូនដែលកើតពីម្តាយដែលមិនបានទទួលឱសថប្រឆាំងមេរោគអេដស៍ផងដែរ ។

យោងទៅតាមតួលេខខាងលើ យើងឃើញថានៅឆ្នាំ២០០៧ ៧៣%នៃស្ត្រីមានផ្ទៃពោះដែលមកពិនិត្យផ្ទៃពោះលើកទី១នៅមណ្ឌលដែលមានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន បានយល់ព្រមធ្វើតេស្តឈាម និងបានទទួលការប្រឹក្សាក្រោយតេស្ត ។ ៦៦%នៃស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ដែលបានរកឃើញនៅពេលពិនិត្យផ្ទៃពោះបានទទួលការព្យាបាលបង្ការដោយឱសថប្រឆាំងមេរោគអេដស៍នៅពេលមានផ្ទៃពោះ ឬនៅពេលសំរាលកូនឯគ្រឹះស្ថានសុខាភិបាល ។

ទោះបីជាយ៉ាងណាក៏ដោយ ការពិនិត្យទៅលើចំនួនប៉ាន់ស្មាននៃស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍នៅទូទាំងប្រទេស យើងឃើញ ថាការកាត់បន្ថយផលប៉ះពាល់នៃការចម្លងមេរោគអេដស៍ពីម្តាយទៅកូនរបស់កម្មវិធីស្ថិតនៅមានកំរិតនៅឡើយ ។ ប្រសិនបើយើងប្រើប្រាស់ចំនួនសរុបនៃកំណើត *("៤១០.០០០នាក់") (សូមមើលតារាងខាងក្រោម) ដែលបានប៉ាន់ស្មាននៅឆ្នាំ២០០៧ និងអត្រាផ្ទុកមេរោគអេដស៍នៅលើស្ត្រីមានផ្ទៃពោះដែលមកទទួលសេវាថែទាំផ្ទៃពោះនៅទូទាំងប្រទេស ដែលបានធ្វើអង្កេតឃើញនៅឆ្នាំ ២០០៦ (១.១%) យើងអាចប៉ាន់ស្មានបានថា នៅកម្ពុជាមានស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ប្រមាណ ៤,៥១០នាក់ ។ ប្រសិនជាគ្មានអន្តរាគមន៍ណាមួយទេ កុមារប្រមាណ ១,៥៧៨នាក់ ដែលកើតពីម្តាយដែលមានផ្ទុកមេរោគអេដស៍ ត្រូវបានរំពឹងថានឹងឆ្លងមេរោគអេដស៍ពីម្តាយ ។ យ៉ាងណាមិញកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនបានធ្វើតេស្ត និងផ្តល់លទ្ធផលតេស្តដល់ស្ត្រីមានផ្ទៃពោះត្រឹមតែ ១៦.១% នៃស្ត្រីមានផ្ទៃពោះទាំងអស់ និងផ្តល់ឱសថប្រឆាំងមេរោគអេដស៍ដល់ស្ត្រីមានផ្ទៃពោះផ្ទុក មេរោគអេដស៍បានត្រឹមតែ ១១.២%ប៉ុណ្ណោះ ។ រីឯកូនដែលសំរាលពីម្តាយផ្ទុកមេរោគអេដស៍ទាំងអស់ដែលបានទទួលឱសថប្រឆាំងមេរោគអេដស៍ត្រូវបានប៉ាន់ស្មានថាមានអត្រាប្រហាក់ប្រហែលនឹងម្តាយដែរ (កូន ៥១៧នាក់ បានទទួលឱសថប្រឆាំងមេរោគអេដស៍ក្រោយសំរាល ក្នុងចំណោមម្តាយ ៤,៥១០នាក់ ដែលប៉ាន់ស្មានថាមានផ្ទុកមេរោគអេដស៍ ។ ផ្ទុយមកវិញ យើងអាចនិយាយបានថា ៨៣.៩%នៃស្ត្រីមានផ្ទៃពោះទាំងអស់គ្មានឱកាសបានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន ហើយកូនដែលកើតពីម្តាយផ្ទុកមេរោគអេដស៍ប្រមាណ៨៨% ក៏គ្មានឱកាសបានទទួលអន្តរាគមន៍ដើម្បីបង្ការការចម្លងមេរោគអេដស៍នេះដែរ ។ បន្ថែមពីលើកង្វះខាតនៃការផ្តល់សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូននេះ ៥៩%នៃស្ត្រីដែលមកសំរាលកូននៅឯមន្ទីរពេទ្យដែលមានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនមិនបានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់គាត់ទេ ។

មុនពេលរៀបចំផែនការយុទ្ធសាស្ត្រ កម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនបានធ្វើការពង្រីកទីតាំងសេវាដោយផ្តោតជាសំខាន់លើការបណ្តុះបណ្តាលបុគ្គលិកនៅតាមមណ្ឌលដែលមានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន និងផ្តោតលើការសាងសង់ជួសជុលបន្ទប់ផ្តល់ប្រឹក្សាដែលអាចធានាបាននូវការសំងាត់ដល់បុគ្គល ។ ក៏ប៉ុន្តែកម្មវិធីបានផ្តោតការយកចិត្តទុកដាក់តិចតួចណាស់ទៅលើការពង្រីកចំណេះដឹងស្តីពីគ្រោះប្រឈមនៃការឆ្លងមេរោគអេដស៍ និងការប្រឈមរបស់ទារកទៅនឹងការឆ្លងមេរោគអេដស៍ពីម្តាយដល់មណ្ឌលសុខភាពដែលមិនទាន់មានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ។ កម្មវិធីក៏មិនទាន់បានរៀបចំឱ្យបានល្អនូវប្រព័ន្ធទំនាក់ទំនង និងប្រព័ន្ធបញ្ជូនរវាង

មណ្ឌលសុខភាពមានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនជាមួយនឹងមណ្ឌលសុខភាពមានសេវាដែលនៅក្បែរគ្នា ដើម្បីឱ្យតំបន់គ្របដណ្តប់សេវាកាន់តែទូលំទូលាយ និងបង្កើនអត្រាស្ត្រី មកទទួលសេវាឱ្យបានច្រើននៅឡើយទេ។ ជាងនេះទៅទៀត ការលើកទឹកចិត្តឱ្យស្ត្រីមានផ្ទៃពោះព្រមធ្វើតេស្តឈាមរកមេរោគអេដស៍នៅតាមមណ្ឌលសុខភាពដែលពុំមានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន នៅមិនទាន់បានអនុវត្តឱ្យបានទូលំទូលាយនៅឡើយ។

ដូច្នេះដើម្បីកាត់បន្ថយការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ប្រការសំខាន់គឺប្រទេសកម្ពុជាត្រូវមានកម្មវិធីបង្ការការចម្លងមេរោគអេដស៍ដ៏មានប្រសិទ្ធិភាពមួយដែលអាចផ្តល់សេវាបង្ការបានទូលំទូលាយដល់ស្ត្រីមានផ្ទៃពោះនៅទូទាំងប្រទេសដោយសេវានេះត្រូវដាក់បញ្ច្រាបទៅក្នុងសេវាថែទាំផ្ទៃពោះដែលមានស្រាប់។ ជាមួយគ្នានេះដែរកម្មវិធីត្រូវគ្របដណ្តប់ឱ្យបានលើស្ត្រីមានផ្ទៃពោះ ដែលស្ថិតនៅក្នុងចំណោមក្រុមប្រជាជនដែលប្រឈមខ្ពស់ទៅនឹងការឆ្លងមេរោគអេដស៍ដើម្បីកាត់បន្ថយការចម្លងមេរោគអេដស៍ពីម្តាយទៅកូន។ ហេតុដូច្នេះហើយដើម្បីឆ្លើយតបទៅនឹងតំរូវការទាំងនេះយើងត្រូវរៀបចំឱ្យមានផែនការយុទ្ធសាស្ត្រជាតិដ៏មាន ប្រសិទ្ធិភាពមួយសំរាប់បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅកម្ពុជា។

**តារាងខាងក្រោមសង្ខេបពីទិន្នន័យ និងប្រភពនៃទិន្នន័យនៅឆ្នាំ២០០៧:**

| ផែនកំណត់ប្រជាសាស្ត្រ | តួលេខប៉ាន់ស្មាន | ប្រភពប៉ាន់ប្រមាណ |
|---|---|---|
| ចំនួនប្រជាជនសរុប | ១៤, ៣៦៤, ០០០នាក់ | ចំនួនប្រជាជនរំពឹងទុកឆ្នាំ១៩៩៨-២០២០ វិទ្យាស្ថានស្ថិតិជាតិ ក្រសួងផែនការ ឆ្នាំ២០០៤ |
| អត្រាកំណើត | ២៨.៥៤កំណើត/១០០០នាក់ | ដូចខាងលើ បំរែបំរួលកំណើតគិតជាមធ្យម ឆ្នាំ២០០៧ |
| អត្រាស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ប៉ាន់ស្មានក្នុងចំណោមស្ត្រីដែលមកទទួលសេវាថែទាំផ្ទៃពោះ | ១.១% | របាយការណ៍ឆ្នាំ២០០៧នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និង កាមរោគស្តីពីការប៉ាន់ប្រមាណពីអត្រាឆ្លងមេរោគអេដស៍ និងការប៉ាន់ប្រមាណរំកិលសំរាប់ ឆ្នាំ២០០៦-២០១២ |
| អត្រាឆ្លងមេរោគអេដស៍ពីម្តាយទៅកូនប៉ាន់ ស្មានបើគ្មានអន្តរាគមន៍បង្ការ | ៣៥% | DeCock KM, Fowler MG, Mercier E, et.al,.ការបង្ការការចម្លងមេរោគ អេដស៍ពីម្តាយទៅកូននៅប្រទេសក្រីក្រ: ការប្រែក្លាយពីការស្រាវជ្រាវទៅជាគោលនយោបាយ |

| | | |
|---|---|---|
| | | និងអនុវត្ត JAMA 2000: 283: 1175-1182 (cites ranges of 25-48%) |
| ចំនួនស្ត្រីដែលបានមកពិនិត្យផ្ទៃពោះលើកទី១នៅមណ្ឌលសុខភាពដែលមានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ឬនៅគ្លីនិកឯកជន | ៩១,០២១នាក់ (៧៣,០១២នាក់ នៅមណ្ឌលសុខភាព និង ១៨,០០៩ នាក់នៅគ្លីនិកឯកជន) | របាយការណ៍ពីមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក ឆ្នាំ២០០៨ |
| ចំនួនស្ត្រីមានផ្ទៃពោះដែលបានស្ម័គ្រចិត្តធ្វើតេស្តឈាម | ៧២,៤៥៥នាក់ (៥៥,៩៩៤នាក់នៅមណ្ឌលសុខភាព និង ១៦,៤៦១នាក់នៅគ្លីនិកឯកជន) | របាយការណ៍ពីមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក ឆ្នាំ២០០៨ |
| ចំនួនស្ត្រីមានផ្ទៃពោះដែលបានមកទទួលលទ្ធផលតេស្តឈាមនិងប្រឹក្សាក្រោយតេស្ត | ៦៦,១៨៦ នាក់ (៥០,១៨៦នាក់នៅមណ្ឌលសុខភាព និង ១៥,៥៨២នាក់នៅគ្លីនិកឯកជន ) | របាយការណ៍ពីមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក ឆ្នាំ២០០៨ |
| ចំនួនស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍រកឃើញនៅសេវាថែទាំផ្ទៃពោះ | ៧៦៩ នាក់ (៥១២នាក់រកឃើញនៅពេលមកទទួលលទ្ធផល និង ២៥៧ នាក់បញ្ជូនមកពីកន្លែងដទៃ) | របាយការណ៍ពីមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក ឆ្នាំ២០០៨ |
| ចំនួនស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍បានទទួលឱសថប្រឆាំងមេរោគអេដស៍ដើម្បីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន | ៥០៥នាក់ | របាយការណ៍ពីមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក ឆ្នាំ២០០៨ |
| ចំនួនកូនកើតពីម្តាយផ្ទុកមេរោគអេដស៍បាន ទទួលឱសថប្រឆាំងមេរោគអេដស៍ | ៥១៧នាក់ | របាយការណ៍ពីមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក ឆ្នាំ២០០៨ |
| ■ ចំនួនកំណើតសរុប = ចំនួនប្រជាជនសរុប x អត្រាកំណើត<br>= ១៤,៣៦៤,០០០នាក់ x ២៨.៥៤/១,០០០ = ៤០៩,៩៤៥នាក់ (ប្រហែល ៤១០,០០០នាក់)<br>■ ចំនួនស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍នៅកម្ពុជា = ៤១០,០០០នាក់ x 0.0១១ = ៤,៥១០នាក់<br>■ ចំនួនកុមារប្រឈមដែលរំពឹងថាឆ្លងមេរោគអេដស៍បើគ្មានបានទទួលឱសថប្រឆាំងមេរោគអេដស៍បង្ការ = ៤,៥១០នាក់ x 0.៣៥ = ១,៥៧៨នាក់ | | |

## ២.៤ ឧបសគ្គបន្ថែមចំពោះការធានាសុវត្ថិភាពដល់មាតា

តាមរបាយការណ៍អង្កេតសុខភាពប្រជាសាស្ត្រឆ្នាំ២០០៥ បានឱ្យដឹងថាអត្រាស្លាប់របស់ម្តាយនៅមានកំរិតខ្ពស់នៅឡើយគឺក្នុង ១០០,០០០ កំណើតកូនរស់មានម្តាយស្លាប់ចំនួន៤៧២នាក់ ។ អត្រាស្លាប់នេះមិនមានការថយចុះទេ ចាប់តាំងពីឆ្នាំ២០០០មក ។ របាយការណ៍អង្កេតសុខភាពប្រជាសាស្ត្រឆ្នាំ២០០៥ក៏បានឱ្យដឹងផងដែរថា ៧១.៤% នៃ ស្ត្រីមានផ្ទៃពោះបានទទួលសេវាថែទាំផ្ទៃពោះយ៉ាងតិចមួយដងនៅមណ្ឌលសុខភាព និងមានតែ ២៤% ទេដែលបានមកពិនិត្យផ្ទៃពោះ ៤ដងឬលើសពីនេះ ។ ស្ត្រីភាគច្រើន (៧៨%) បានសំរាលកូននៅតាមផ្ទះឬសំរាលដោយឆ្មបដែលមិនមានជំនាញច្បាស់លាស់ ។ មានស្ត្រីប្រមាណ ២២%តែប៉ុណ្ណោះ ដែលបានសំរាលកូននៅតាមគ្រឹះស្ថានសុខាភិបាល ។ ស្ត្រីបានសំរាលកូនដោយមានជំនួយពីគ្រូពេទ្យឬឆ្មបដែលមានការបណ្តុះបណ្តាល ត្រឹមត្រូវមានតែ ៤៤% តែប៉ុណ្ណោះ ។

តាមរបាយការណ៍នៃអង្គការយូអិនអេហ្វភីអេឆ្នាំ២០០៦ បានឱ្យដឹងថាមូលហេតុដែលបណ្តាលឱ្យការប្រើប្រាស់សេវាសំរាលមានកំរិតទាប គឺដោយសារតែកង្វះខាតឆ្មបជំនាញនៅតាមមណ្ឌលសុខភាពដែលនៅជិតផ្ទះស្ត្រីភាពក្រីក្រ កង្វះខាតធនធាន កង្វះខាតមធ្យោបាយធ្វើដំណើរការឧ្យត់បណ្តាញបញ្ជូន និងការខ្វះខាតនូវការលើកទឹកចិត្តដល់មន្ត្រី-បុគ្គលិក ដែលជាអ្នកផ្តល់សេវា ។

តាមការអនុវត្តន៍ជាក់ស្តែង មណ្ឌលសុខភាពមួយចំនួនមានការខ្វះខាតឆ្មបយ៉ាងខ្លាំង ។ ចំណែកឯមណ្ឌលសុខភាពដែលមានឆ្មបគ្រប់គ្រាន់ បែរជាត្រូវទទួលភារកិច្ចច្រើនមុខដែលត្រូវផ្តល់ដល់អតិថិជន ដូចជាផ្តល់សេវាចាក់វ៉ាក់សាំង និងសេវាសុខភាពដទៃៗទៀត បន្ថែមពីលើសេវាសុខភាពបន្តពូជ ។ ហេតុនេះហើយធ្វើឱ្យបុគ្គលិកនៅតាមមណ្ឌលសុខភាពទាំងនោះមិនអាចមានលទ្ធភាពគ្រប់គ្រាន់នឹងទទួលរ៉ាប់រងលើបន្ទុកការងារដ៏ច្រើនទាំងអស់នោះបានឡើយ ។ ជាចុងក្រោយការយល់ដឹងរបស់ប្រជាជនស្តីពីការប្រឈមនឹងការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅមានកំរិតទាបនៅឡើយ ។ របាយការណ៍អង្កេតសុខភាពប្រជាសាស្ត្រឆ្នាំ២០០៥បានឱ្យដឹងថា មានតែ ១/៣ នៃស្ត្រី និងប្រហែល១/៤ នៃបុរសតែប៉ុណ្ណោះបានយល់ដឹងពីគ្រោះប្រឈមនឹងការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ដែលអាចកាត់បន្ថយបានតាមរយៈការប្រើឱសថប្រឆាំងមេរោគអេដស៍នៅពេលមានផ្ទៃពោះ ។ របាយការណ៍នេះក៏បានឱ្យដឹងផងដែរថាមាន ស្ត្រី ៦៩% និងបុរសប្រមាណ ៦០% តែប៉ុណ្ណោះដែលបានដឹងថា មនុស្សដែលមើលទៅហាក់ដូចជាមានសុខភាពល្អក៏អាចមានផ្ទុកមេរោគអេដស៍ ហើយក៏អាចចម្លងមេរោគអេដស៍នេះទៅអ្នកដទៃបានដែរ ។ ម្យ៉ាងវិញទៀតចំណេះដឹងស្តីពីការឆ្លងមេរោគអេដស៍គឺទាក់ទងជាសំខាន់ទៅនឹងកំរិតសិក្សា និងស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ប្រជាជន គឺថាអ្នកក្រីក្រ និងអ្នកដែលមិនបានទទួលការសិក្សាមានការយល់ដឹងពីមេរោគអេដស៍ តិចតួចបំផុត ។

## ២.៥ សង្ខេបពីបទពិសោធន៍ដែលបានអនុវត្តកន្លងមកក្នុងការឆ្លើយតបទៅនឹងកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

- កម្មវិធីមិនបានផ្តោតការយកចិត្តទុកដាក់ឱ្យបានខ្លាំងក្លាក្នុងការលើកកំពស់ឱ្យមានការយល់ដឹងស្តីពីការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនក្នុងចំណោមប្រជាជនដែលរស់នៅតាមសហគមន៍ ដើម្បីឱ្យគាត់បានមកទទួលប្រើប្រាស់សេវាដែលគាត់ត្រូវការ ។

- យុទ្ធសាស្ត្រដំបូងនៃកម្មវិធីដែលបានផ្តោតទៅលើតែការពង្រីកចំនួនសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅតាមមណ្ឌលសុខភាព និងទៅលើការបណ្តុះបណ្តាលដល់បុគ្គលិកមិនបានបង្ហាញច្បាស់ពីប្រសិទ្ធិភាពក្នុងការបង្កើនការមកទទួលសេវាធ្វើតេស្តឈាមរកមេរោគអេដស៍ក្នុងចំណោមស្ត្រីមានផ្ទៃពោះ ឱ្យបានច្រើននៅឡើយទេ។
- វិធីផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមដែលផ្តួចផ្តើមដោយអ្នកផ្តល់សេវា បានផ្តល់ឱកាសដ៏ច្រើនដល់ស្ត្រីមានផ្ទៃពោះឱ្យបានទទួលសេវាធ្វើតេស្តឈាមយ៉ាងទូលំទូលាយ ។នីតិវិធីអនុវត្តន៍ស្តង់ដានៃការផ្តល់ប្រឹក្សា និង ធ្វើតេស្តឈាមដែលផ្តួចផ្តើមឡើងដោយអ្នកផ្តល់សេវា អនុញ្ញាតឱ្យមានការបញ្ជូនអតិថិជនទៅធ្វើតេស្តឈាមក៏បាន ឬក៏បញ្ជូនសំណាកទឹបឈាមទៅធ្វើតេស្តរកមេរោគអេដស៍ក៏បាន។ ការងារនេះត្រូវការសំរបសំរួលពីគ្រប់ភាគី ទាំងអស់រួមមានមណ្ឌលធ្វើតេស្តឈាម មណ្ឌលសុខភាពដែលមាន ឬគ្មានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន និងអង្គការមិនមែនរដ្ឋាភិបាលនៅតាមសហគមន៍ដែលអាចមានថវិកាជួយគាំទ្រដល់ថ្លៃធ្វើដំណើររបស់អតិថិជន។ ក៏ប៉ុន្តែអ្នកទទួលខុសត្រូវក្នុងការសំរបសំរួលលើការងារនេះនៅមិនទាន់មានភាពច្បាស់លាស់ពីការងាររបស់ខ្លួននៅឡើយ ដែលភាពមិនច្បាស់លាស់នេះ អាចជាកត្តាមួយ ធ្វើឱ្យការអនុវត្តន៍ការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមដែលផ្តួចផ្តើមដោយអ្នកផ្តល់ប្រឹក្សា នេះមិនសូវជឿនលឿនទៅមុខបានល្អទេ។
- ការធ្វើតេស្តឈាមរកមេរោគអេដស៍លើស្ត្រីមានផ្ទៃពោះនៅពេលឈឺពោះសំរាលនៅឯមន្ទីរពេទ្យដែលមានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ផ្តល់ឱកាសដល់ស្ត្រីផ្ទុកមេរោគអេដស៍បានដឹងពីស្ថានភាព ផ្ទុកមេរោគអេដស៍របស់ខ្លួនបានទាន់ពេលវេលាដើម្បីចាត់វិធានការណ៍កាត់បន្ថយការចម្លងមេរោគអេដស៍ពីម្តាយទៅកូន នៅពេលឈឺពោះសំរាល និងក្រោយសំរាលតាមរយៈការប្រើឱសថប្រឆាំងមេរោគអេដស៍។ តែទោះបីជាយ៉ាងណាក៏ដោយ សកម្មភាពនេះមិនទាន់បានអនុវត្តឱ្យបានទូលំទូលាយនៅឡើយ។
- បច្ចុប្បន្ននេះគ្រប់សកម្មភាពនៃកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនត្រូវបានអនុវត្តដោយការិយាល័យបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនតាមរបៀបមជ្ឈការ ដូចជាការបណ្តុះបណ្តាល និងការអភិបាល។ ការអនុវត្តន៍បែបមជ្ឈការនេះ ធ្វើឱ្យអ្នកគ្រប់គ្រងនៅថ្នាក់ស្រុក ប្រតិបត្តិនិងខេត្តមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការអនុវត្តន៍គោលការណ៍ណែនាំជាតិស្តីពីការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅតាមមូលដ្ឋានឱ្យបានពេញលេញទេ។ ជាលទ្ធផលការពង្រីកកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន តាមបែបមជ្ឈការនេះនឹងមិនត្រូវបានយកមកអនុវត្តទៀតទេនាពេលខាងមុខ។

## ២ អនុសាសន៍បានមកពីការពិនិត្យឡើងវិញរួមគ្នាលើកម្មវិធីជាតិបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

របាយការណ៍នៃការពិនិត្យឡើងវិញរួមគ្នាលើកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅកម្ពុជាឆ្នាំ ២០០៧ បានបង្ហាញពីយុទ្ធសាស្ត្រថ្មីសំខាន់ៗដែលរកឃើញដោយក្រុមការងារចំរុះ ដូចជាទីប្រឹក្សាបច្ចេកទេសអន្តរជាតិ

ចំរុះ ដែលមកពីអង្គការសុខភាពពិភពលោក អង្គការយូនីសេហ្វ យូអេសស៊ីឌីស៊ី និងធនាគារពិភពលោក រួមទាំងដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិក្នុងស្រុក។ យុទ្ធសាស្ត្រទាំងនោះបានកំណត់យ៉ាងច្បាស់ពីគោលបំណងក្នុងការធានាធ្វើឱ្យកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន អនុវត្តកាន់តែលឿនទៅមុខបានឆាប់រហ័ស។ យុទ្ធសាស្ត្រសំខាន់ៗបួន ត្រូវបានលើកឡើងជាអនុសាសន៍ដូចតទៅ :

*១. បង្កើត និងអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនគ្រប់ជ្រុងជ្រោយ និងរៀបចំផែនការពង្រីកគំរោងសកម្មភាពដែលមានបញ្ជាក់ពីតួនាទីការថវិកា ពេលវេលាជាក់លាក់ និងគោលដៅចំណុចផ្តែកលើ ចំនួនប្រជាជន។ យុទ្ធសាស្ត្រនេះនឹងជំរុញឱ្យមានការបណ្តុះនូវគំនិត ផ្តួចផ្តើមថ្មីៗ។*

*២. ពង្រីកការផ្តល់សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ដើម្បីគ្របដណ្តប់លើស្ត្រីមានផ្ទៃពោះឱ្យបានភាគច្រើនសំដៅសម្រេចឱ្យបាននូវលទ្ធភាពទទួលសេវាបង្ការព្យាបាល និងថែទាំជាសកលដល់អ្នកផ្ទុកមេរោគអេដស៍។*

*៣. ធានាឱ្យមានការគោរពតាមគោលនយោបាយនិងគោលការណ៍ណែនាំជាតិស្តីពីការចិញ្ចឹមទារក និងកុមារតូចៗក្នុងបរិបទនៃមេរោគអេដស៍ និងត្រូវពង្រឹងការអនុវត្តន៍ និងត្រួតពិនិត្យតាមដានកន្លែងផ្តល់សេវាគ្រប់ថ្នាក់ និងគ្រប់ដៃគូទាំងអស់ ។*

*៤. កែលំអការប្រមូលទិន្នន័យនិងធ្វើការវិភាគលើទិន្នន័យរបស់កម្មវិធីដែលតាមដានជាប្រចាំដោះស្រាយចំណុចខ្វះខាតនៃទិន្នន័យសំខាន់ៗ ព្រមទាំងចែករំលែកព័ត៌មានទាំងឡាយជាមួយនឹងកម្មវិធីនានា និងជាមួយភាគីពាក់ព័ន្ធផ្សេងៗទៀត ប្រកបដោយប្រសិទ្ធភាព។*

ដោយយោងទៅលើអនុសាសន៍សំខាន់ៗខាងលើក្រសួងសុខាភិបាលបានអនុម័តឱ្យមានការរៀបចំផែនការយុទ្ធសាស្ត្រជាតិសំរាប់ បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ដូចបានរៀបរាប់នៅផ្នែកខាងក្រោមនេះ។

# ៤ ផែនការយុទ្ធសាស្ត្រជាតិសំរាប់បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ឆ្នាំ២០០៨-២០១៥

កម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនត្រូវបានដាក់បញ្ជ្រាបទៅក្នុងប្រព័ន្ធសុខាភិបាលដែលមានស្រាប់ហើយមានគោលដៅបង្ការការឆ្លងមេរោគអេដស៍ក្នុងចំណោមស្ត្រី និងកុមារ។ ទន្ទឹមនឹងនេះដែរ កម្មវិធីក៏មានគោលបំណងពង្រឹងសេវាសុខភាពមាតានិងទារកផងដែរ។

## ទស្សនៈវិស័យនៃផែនការយុទ្ធសាស្ត្រជាតិ

ទស្សនៈវិស័យនៃផែនការយុទ្ធសាស្ត្រជាតិសំរាប់កម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនឆ្នាំ២០០៨-២០១៥ គឺជាសង្គមកម្ពុជាមួយដែលគ្មានការចម្លងមេរោគអេដស៍ពីម្តាយទៅកូន។ ទស្សនៈវិស័យនេះផ្អែកតាមផែន

ការយុទ្ធសាស្ត្រជាតិប្រយុទ្ធ នឹងជម្ងឺអេដស៍ឆ្នាំ២០០៧-២០១០ គោលនយោបាយជាតិស្តីពីការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនឆ្នាំ២០០៥ និង គោលការណ៍ណែនាំជាតិសំរាប់អនុវត្តកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនឆ្នាំ២០០៥។

### គោលការណ៍ណែនាំសំខាន់ៗ

ផែនការយុទ្ធសាស្ត្រជាតិស្តីពីការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនផ្សារភ្ជាប់ទៅនឹងគោលការណ៍ណែនាំដូចតទៅ :

១) វាគឺជាផែនការណ៍យុទ្ធសាស្ត្រមួយដែលផ្អែកលើភស្តុតាងជាមូលដ្ឋាន និងអនុវត្តតាមអនុសាសន៍អន្តរជាតិស្តីអំពីអន្តរាគមន៍ បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន។

២) ការធ្វើផែនការសំរាប់បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនត្រូវមានលក្ខណៈវិមជ្ឈការទៅដល់ថ្នាក់ខេត្តដើម្បីឱ្យពួកគេអាចរៀបចំធ្វើផែនការយុទ្ធសាស្ត្រ និងដាក់ទិសដៅសំរាប់អនុវត្តសមស្របនៅតាមមូលដ្ឋានរបស់ពួកគេ ។

៣) សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនត្រូវដាក់បញ្ជ្រាបទៅក្នុងសេវាសុខភាពមាតា និងទារក និង សេវាជម្ងឺអេដស៍ដែលមានស្រាប់ ។

៤) ទំនាក់ទំនងក្នុងគ្រឹះស្ថានសុខាភិបាលនិងទំនាក់ទំនងរវាងគ្រឹះស្ថានសុខាភិបាលជាមួយនឹងសហគមន៍មូលដ្ឋានត្រូវពង្រឹងឱ្យបានរឹងមាំដោយយកចិត្តទុកដាក់ជាពិសេសក្នុងការស្រាវជ្រាវរកក្រុមប្រឈមខ្ពស់ដែលរស់នៅតាមសហគមន៍ ។

៥) ការអនុវត្តកញ្ចប់សកម្មភាពនៃកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ត្រូវពឹងផ្អែកទាំងស្រុងទៅលើការសហការ និងការសំរបសំរួលរវាងកម្មវិធីសុខភាពមាតានិងទារកជាមួយនឹងកម្មវិធីអេដស៍ដោយកំណត់ឱ្យបានច្បាស់ពី តួនាទីនិងការទទួលខុសត្រូវរបស់កម្មវិធីនីមួយៗ។

ប្រទេសកម្ពុជាបានទទួលយកនូវការអនុវត្តន៍កម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនចំនួនបួនទទួលស្គាល់ដោយសកលលោកដែលរួមមាន :

១. បង្ការការចម្លងមេរោគអេដស៍ដល់ស្ត្រីដែលស្ថិតក្នុងវ័យបន្តពូជ
២. បង្ការការមានកូនដែលមិនតាមបំណងដល់ស្ត្រីដែលមានផ្ទុកមេរោគអេដស៍
៣. បង្ការការចម្លងមេរោគអេដស៍ពីម្តាយផ្ទុកមេរោគអេដស៍ទៅកូនរបស់គាត់
៤. ថែទាំ និងគាំទ្រដល់ស្ត្រីផ្ទុកមេរោគអេដស៍ និងកូនរបស់គាត់

ដើម្បីសំរេចបាននូវយុទ្ធសាស្ត្រសកលទាំងអស់នេះបាន ក្រសួងសុខាភិបាលត្រូវៈ

- បន្តលើកកំពស់សិទ្ធិរបស់ប្រជាជនគ្រប់រូប រួមទាំងអ្នកដែលមានផ្ទុកមេរោគអេដស៍ដើម្បីឱ្យពួកគេបានរស់នៅដោយគ្មានការមាក់ងាយនិងរើសអើង។ ដើម្បីបំបាត់ភាពរើសអើងមាក់ងាយនេះបានបុគ្គលិកសុខាភិបាល

ត្រូវមានឥរិយាបថស្វាគមន៍រាក់ទាក់ចំពោះស្ត្រីជាដំបូងបង្អស់នៅពេលដែលស្ត្រីមកទទួលសេវាថែទាំផ្ទៃពោះ ហើយក៏ត្រូវបន្តធ្វើការលុបបំបាត់ភាពរើសអើងនិងមាក់ងាយនេះនៅតាមសហគមន៍ផងដែរ ។

- ពង្រឹងការយល់ដឹងនៅតាមសហគមន៍ស្តីពី ការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនដើម្បីជំរុញឱ្យមានការចូលរួមធ្វើតេស្តឈាមរកមេរោគអេដស៍ឱ្យបានច្រើនពីស្ត្រីមានផ្ទៃពោះ ដែលការធ្វើតេស្តឈាមនេះគឺ ជាផ្នែកមួយនៃកញ្ចប់សកម្មភាពនៅសេវាថែទាំផ្ទៃពោះនិងនៅសេវាសំរាលដើម្បីធានាថាកូនដែលកើតមកមានសុខភាពល្អ ។
- ធានាថាស្ត្រីមានផ្ទៃពោះនឹងទទួលបានជាសកលនូវការធ្វើតេស្តឈាមរកមេរោគអេដស៍នៅតាមគ្រឹះស្ថានសុខាភិបាល ។
- ធានាថាស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ទទួលបាននូវការថែទាំព្យាបាលដើម្បីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ។
- ពង្រឹងទំនាក់ទំនង និងយន្តការបញ្ជូនរវាងសេវាថែទាំជម្ងឺអេដស៍ សេវាជម្ងឺកាមរោគ សេវាសុខភាពបន្តពូជ និង សេវាផែនការគ្រួសារ ។

## ៤.១ គោលដៅនៃផែនការយុទ្ធសាស្ត្រជាតិ

គោលដៅនៃផែនការយុទ្ធសាស្ត្រជាតិ គឺសំដៅលុបបំបាត់នូវការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅកម្ពុជាតាមរយៈការធ្វើឱ្យប្រសើរឡើងនូវអត្រាគ្របដណ្តប់នៃសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន និងការផ្តល់សេវាដែលមានគុណភាពល្អ ដល់ស្ត្រីមានផ្ទៃពោះទាំងអស់ តាមរយៈការផ្តល់ចំណេះដឹងស្តីពីការបង្ការមេរោគអេដស៍ឱ្យបានខ្លាំងក្លាដល់បុរសស្ត្រីដែលបំរុងនឹងក្លាយជាមាតាបិតារបស់ក្មេងនាពេលអនាគត និងតាមរយៈការផ្តល់នូវសេវាថែទាំព្យាបាលនិងគាំទ្រដល់ស្ត្រីផ្ទុកមេរោគអេដស៍ កូនព្រមទាំងគ្រួសាររបស់គាត់ ។

## ៤.២ គោលបំណងនៃផែនការយុទ្ធសាស្ត្រជាតិ

ផែនការយុទ្ធសាស្ត្រជាតិស្តីពីការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន មានគោលបំណងសំខាន់៧៤គឺ:

១) ពង្រីកការផ្តល់សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងមានគុណភាពល្អ ដល់ស្ត្រីមានផ្ទៃពោះនិងកូនរបស់គាត់ និងជាពិសេសដល់ពួកក្រុមប្រឈមខ្ពស់ ។

២) ពង្រឹងការធ្វើផែនការកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ការគ្រប់គ្រង ការសំរបសំរួល ការអនុវត្តន៍ និងការអភិបាលឱ្យបានគ្រប់គ៏រិត ដើម្បីធ្វើឱ្យកម្មវិធីសំរេចបានគោលដៅចំណុចឆ្នាំ ២០០៨-២០១៥ ។

៣) ពង្រឹងការអនុវត្តន៍ និងធ្វើការតាមដានលើការអនុវត្តន៍គោលនយោបាយជាតិនិងគោលការណ៍ណែនាំជាតិស្តីពីការចិញ្ចឹមទារកនិងកុមារតូចៗក្នុងបរិបទនៃមេរោគអេដស៍-ជម្ងឺអេដស៍ឱ្យបានគ្រប់កន្លែងផ្តល់សេវាទាំងនៅសហគមន៍ ដោយមានការចូលរួមពីគ្រប់ដៃគូទាំងអស់ ។

៤) ធ្វើការប្រមូលទិន្នន័យគ្រប់គ្រងទិន្នន័យ និងប្រើប្រាស់ទិន្នន័យឱ្យមានប្រសិទ្ធិភាពនៅគ្រប់លំដាប់ថ្នាក់សំរាប់ការធ្វើផែនការសកម្មភាពការអនុវត្តន៍កម្មវិធី ការកែលំអគុណភាពនៃសេវា និងសំរាប់តាមដានអ្នកជម្ងឺ ឱ្យបានជាប់ជាប្រចាំ ។

## ៤.៣ សកម្មភាពនៃផែនការយុទ្ធសាស្ត្រជាតិ

សកម្មភាពលំអិតនៃផែនការយុទ្ធសាស្ត្រជាតិត្រូវបានដាក់បញ្ចូលទៅក្នុងតារាងម៉ាទ្រីកនៃទំព័រខាងក្រោយ ។ ជាបន្តទៅនេះ គឺជាការសង្ខេបនូវចំណុចសំខាន់៧នៃគោលបំណង យុទ្ធវិធី និងសកម្មភាពដែលត្រូវអនុវត្ត ។

### ៤.៣.១ គោលបំណងទី១

ពង្រីកការផ្តល់សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយនិងមានគុណភាពល្អដល់ស្ត្រីមានផ្ទៃពោះនិងកូនរបស់គាត់ និងជាពិសេសដល់ក្រុមប្រឈមខ្ពស់ ។

**យុទ្ធវិធី**

- ពង្រឹងការយល់ដឹងរបស់សហគមន៍ស្តីអំពីការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ដើម្បីបង្កើនការចូលរួមរបស់ស្ត្រីមានផ្ទៃពោះឱ្យមកទទួលយកសេវាបង្ការនេះ តាមរយៈការចល័តធនធាននៅតាមសហគមន៍ និងតាមរយៈប្រព័ន្ធទំនាក់ទំនង ។
- បញ្ជ្រាបសមាសភាគនៃសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនទៅក្នុងសកម្មភាពនៃមណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែក និងធ្វើការសហការយ៉ាងជិតស្និទ្ធជាមួយនឹងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និងកាមរោគ ដើម្បីពង្រីកតួនាទីក្រុមដែលធ្វើការនៅតាមសហគមន៍ ។
- ផ្តល់ឱកាសធ្វើតេស្តឈាមដល់ស្ត្រីមានផ្ទៃពោះនិងដៃគូរបស់គាត់ឱ្យបានច្រើន ។
- បង្កើនការទទួលប្រើប្រាស់ឱសថប្រឆាំងមេរោគអេដស៍ ចំពោះស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ និងកូនរបស់គាត់ ។
- ធានាឱ្យបាននូវការបង្ការជាសកល និងការបង្ការគ្រោះប្រឈមនឹងការឆ្លងមេរោគអេដស៍ក្រោយមុតរបួសដល់គ្រប់បុគ្គលិកដែលធ្វើការផ្ទាល់ជាមួយអ្នកជម្ងឺ ។
- បង្កើនចំណងទាក់ទង និងយន្តការបញ្ជូនជាមួយសេវាព្យាបាលជម្ងឺអេដស៍ សេវាជម្ងឺកាមរោគ សេវាសុខភាពបន្តពូជ និងសេវាផែនការគ្រួសារ ដើម្បីបង្កើនប្រសិទ្ធិភាពនៃយុទ្ធសាស្ត្រសកលលោកទី៣ និងដើម្បីផ្សារភ្ជាប់ទំនាក់ទំនងជាមួយនឹងយុទ្ធសាស្ត្រសកលលោកទី១ ទី២ និងទី៤ ។
- ធានាថាកុមារប្រឈមត្រូវបានតាមដានជាប់ជាប្រចាំដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយនិងត្រូវបានធ្វើតេស្តឈាមរករោគវិនិច្ឆ័យជម្ងឺអេដស៍បានទាន់ពេល ។

**សកម្មភាពសំខាន់ៗ:**

១. បង្កើនការប្រើប្រាស់សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនដោយបង្កើត និងអនុវត្តយុទ្ធវិធីទំនាក់ទំនងផ្សព្វផ្សាយព័ត៌មានដែលនាំឱ្យមានការផ្លាស់ប្តូរឥរិយាបថប្រព្រឹត្តសំរាប់បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនដោយសហការជាមួយក្រសួងកិច្ចការនារីដែលប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងចល័តធនធានមនុស្សតាមរយៈការធ្វើសម្ព័ន្ធភាពជាមួយមេដឹកនាំសហគមន៍ជាមួយអ្នកថែទាំអ្នកជម្ងឺអេដស៍នៅតាមសហគមន៍ និងជាមួយក្រុមគាំទ្រអ្នកផ្ទុកមេរោគអេដស៍ ។

២. ដាក់បញ្ចូលចំណេះដឹងស្តីពីជម្ងឺអេដស៍ និងវិធីសាស្ត្រនៃការផ្តល់ប្រឹក្សាធ្វើតេស្តឈាម ដែលផ្តួចផ្តើមដោយអ្នកផ្តល់សេវាទៅក្នុងពិធីសារកញ្ចប់សកម្មភាពអប្បបរិមា ដើម្បីធានាថាស្ត្រីមកពិនិត្យផ្ទៃពោះទាំងអស់បានទទួល ព័ត៌មានស្តីពីមេរោគអេដស៍ និងបានធ្វើតេស្តឈាមរកមេរោគអេដស៍។

៣. ពង្រីកទីតាំងធ្វើតេស្តឈាមសំរាប់ស្ត្រីមានផ្ទៃពោះនៅតាមមណ្ឌលផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមដែលមានស្រាប់ និងនៅតាមមន្ទីរសំរាលដែលមានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន (ធ្វើតេស្តឈាមនៅពេលឈឺពោះសំរាល)។ ជាមួយគ្នានេះដែរត្រូវធ្វើការវាយតម្លៃពីលទ្ធភាពធ្វើស្ត្រីនតេស្តរកមេរោគអេដស៍ នៅតាមមណ្ឌលសុខភាព ដែលស្ថិតនៅឆ្ងាយពីមណ្ឌលផ្តល់ប្រឹក្សាធ្វើតេស្តឈាម។

៤. ធានាថាស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍បានទទួលឱសថប្រឆាំងមេរោគអេដស៍នៅពេលមានផ្ទៃពោះ ពេលឈឺពោះសំរាល និងពេលក្រោយសំរាល ដោយអនុវត្តនូវសកម្មភាពដូចតទៅនេះ :

ក) ល័ក្ខខ័ណ្ឌក្នុងការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ចំពោះស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ត្រូវប្តូរពីការរាប់កោសិកាស៊ីឌីហ្វ័រចំនួន ២៥០ មក ៣៥០/មីក្រូលីត្រវិញ។ ល័ក្ខខ័ណ្ឌព្យាបាលចំពោះស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍នេះនឹងត្រូវពិនិត្យវាយតម្លៃជារៀងរាល់ឆ្នាំ ដោយធ្វើការកែតំរូវទៅតាមគោលការណ៍របស់ជាតិ និងអនុសាសន៍អន្តរជាតិ។

ខ) ស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ ដែលមានកោសិកាស៊ីឌីហ្វ័រច្រើនជាង៣៥០/មីក្រូលីត្រ ត្រូវទទួល ឱសថអេហ្ស៊ិតធីនៅពេលផ្ទៃពោះមានអាយុចាប់ពី ២៨សប្តាហ៍ឡើងទៅ។ ឱសថណេវីរ៉ាពីនចំនួន ១ដូសគត់ (២០០មីលីក្រាម) នឹងផ្តល់ជូនស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ដែលរស់នៅឯជនបទឆ្ងាយដាច់ស្រយាលនៅពេលដែលស្ត្រីមកទទួលសេវាថែទាំផ្ទៃពោះសំរាប់ទុកឱ្យគាត់លេបនៅពេលឈឺពោះសំរាល មុនពេលមកដល់មន្ទីរពេទ្យសំរាលកូន។ ការផ្តល់ឱសថណេវីរ៉ាពីនដែលជាឱសថប្រឆាំងមេរោគអេដស៍ មានប្រសិទ្ធិភាពខ្ពស់សំរាប់បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនបែបនេះ គឺដើម្បីធានាថាស្ត្រីបានលេបវាទាន់ពេលវេលាជៀសវាងការខកខានមិនបានលេបដោយសារការយឺតយ៉ាវក្នុងការធ្វើដំណើរ។ ការផ្តល់ឱសថណេវីរ៉ាពីនដល់ស្ត្រីយកទៅផ្ទះបែបនេះមិនមែនមានន័យថា លើកទឹកចិត្តស្ត្រីឱ្យមានការសំរាលកូននៅតាមផ្ទះនោះទេ។ ក៏ប៉ុន្តែវាជាជោគជ័យក្នុងដំណាក់កាលដំបូងនៃអន្តរាគមន៍បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន នៅតាមគ្រឹះស្ថានសុខាភិបាល។

គ) អង្គការធ្វើការនៅតាមសហគមន៍ (រួមទាំងក្រុមថែទាំអ្នកជម្ងឺនៅតាមផ្ទះ)នឹងត្រូវបានពង្រឹងដើម្បីផ្តល់ការគាំទ្រដល់ស្ត្រីផ្ទុកមេរោគអេដស៍នៅពេលមានផ្ទៃពោះ ដោយធ្វើការសំរួលឱ្យស្ត្រីបានមកទទួលឱសថប្រឆាំងមេរោគអេដស៍ឱ្យស្ត្រីមកសំរាលកូននៅមន្ទីរពេទ្យ និងធ្វើការតាមដានម្តាយ និងកូនក្រោយ ពេលសំរាលបានសមស្រប។

ឃ) ចំពោះស្ត្រីផ្ទុកមេរោគអេដស៍ដែលក្រីក្រ ថ្លៃសំរាលឬថ្លៃចំណាយផ្សេងៗគួរលើកលែង អ្នកផ្តល់សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនត្រូវផ្តល់ព័ត៌មានពីការចំណាយនេះឱ្យបានច្បាស់លាស់ ដើម្បីធានាថាថវិកាមិនមែនជាឧបសគ្គចំពោះស្ត្រីក្នុងការមកទទួលឱសថប្រឆាំងមេរោគអេដស៍ និងការសំរាល ដ៏មានសុវត្ថិភាពរបស់គាត់ឡើយ។

៥. ផ្តល់អាទិភាពដល់ខេត្តទាំងអស់ក្នុងការពង្រីកសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ដោយយោងទៅតាមចំនួនប្រជាជន អត្រាកំណើត និងអត្រាប្រេវ៉ាឡង់ស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍។ ចំពោះការពង្រីកសេវានៅតាមស្រុកវិញ អាទិភាពត្រូវផ្តល់ឱ្យស្រុកប្រតិបត្តិ ឬតំបន់ណាដែលមានអត្រាប្រេវ៉ាឡង់ស្ត្រី មានផ្ទៃពោះផ្ទុកមេរោគអេដស៍ក្នុងកំរិតខ្ពស់ ឬមានក្រុមមនុស្សដែលមានឥរិយាបថប្រឈមនឹងការឆ្លងមេរោគអេដស៍ខ្ពស់ ឬក៏មានស្ត្រីមានផ្ទៃពោះច្រើន។

## ៤.៣.២ គោលបំណងទី២

ពង្រឹងការធ្វើផែនការកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ការគ្រប់គ្រងការសំរបសំរួល ការអនុវត្តន៍ និង ការអភិបាលឱ្យបានគ្រប់កំរិត ដើម្បីធ្វើឱ្យកម្មវិធីសំរេចបានគោលដៅចំណុចឆ្នាំ ២០០៨-២០១៥។

### យុទ្ធវិធី

- ពង្រឹងការធ្វើផែនការកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅគ្រប់កំរិតតាមរយៈផែនការប្រតិបត្តិ ប្រចាំឆ្នាំ និងមានគោលដៅប្រជាជនចំណុច។
- ពង្រឹងការគ្រប់គ្រងកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅថ្នាក់ជាតិ ដោយធ្វើការពង្រឹងតួនាទី ក្រុមការងារបច្ចេកទេស លេខាធិការដ្ឋាននៃកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន និងលើកកំពស់កិច្ចសំរបសំរួលជាមួយនឹងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និងកាមរោគ។
- ពង្រឹងការសំរបសំរួលកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅថ្នាក់ជាតិ និងថ្នាក់ខេត្ត។
- ធ្វើវិមជ្ឈការសមាសភាគសំខាន់ៗនៃកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ដូចជាការបណ្តុះបណ្តាល និង ការអភិបាល។

### សកម្មភាពសំខាន់ៗ:

១. ធ្វើវិមជ្ឈការផែនការ ការអនុវត្តន៍ ការអភិបាល ការតាមដាន និងវាយតម្លៃកម្មវិធី រួមទាំងការបណ្តុះបណ្តាលផងដែរ ទៅថ្នាក់ខេត្ត និង/ឬថ្នាក់ស្រុក។ ថ្នាក់ជាតិមានភារកិច្ចពិនិត្យមើលរួមនូវការតាមដាននិងវាយតម្លៃកម្មវិធី។

២. ថ្នាក់ខេត្ត/ថ្នាក់ស្រុកត្រូវធ្វើការគណនាចំនួនប្រជាជនមូលដ្ឋានរបស់ខ្លួន និងកំណត់ចំណុចគោលដៅដែលមានរយៈពេលជាក់លាក់ប្រចាំឆ្នាំ (សូមអានឧបសម្ព័ន្ធទី១) និងរៀបចំយុទ្ធសាស្ត្រសំរាប់មូលដ្ឋានរបស់ខ្លួនដើម្បីឱ្យសំរេចបាននូវចំណុចគោលដៅទាំងនោះ ឧទាហរណ៍ដូចជាយុទ្ធសាស្ត្រសំរាប់ ធ្វើការជួបជាមួយក្រុមប្រជាជន ដែលមានអត្រាប្រឈមខ្ពស់។

៣. បណ្តុះបណ្តាលបុគ្គលិកនៅតាមគ្លីនិកដែលមានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនៈ ដើម្បីឱ្យសំរេចគោលដៅ បុគ្គលិកដែលធ្វើការនៅផ្នែកថែទាំផ្ទៃពោះ និងផ្នែកសំរាល ត្រូវទទួលការបណ្តុះបណ្តាលស្តីពី កម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន (ការផ្តល់ព័ត៌មានមុនធ្វើ

តេស្តឈាម ការផ្តល់ប្រឹក្សា ក្រោយតេស្ត ការធ្វើតេស្តឈាម ការគ្រប់គ្រងការសំរាល ការចិញ្ចឹមទារកនិងកុមារតូចៗ ។ល។) បន្ថែមពីលើបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាលរួចទៅតាមមណ្ឌលដែលកំពុងដំណើរការស្រាប់ ។ ដោយបុគ្គលិកនៅតាមមូលដ្ឋានដែលកំពុងតែអនុវត្តសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនមានបទពិសោធន៍ច្រើនស្រាប់ ការបណ្តុះបណ្តាលត្រូវផ្ទេរពីលេខាធិការដ្ឋានទៅឱ្យមន្ត្រីខេត្ត ឬតំបន់ជាអ្នកទទួលខុសត្រូវលើកិច្ចការនេះ ដើម្បីឱ្យមន្ត្រីថ្នាក់ជាតិអាចមានពេលវេលាទទួលខុសត្រូវលើការងារគ្រប់គ្រងសំខាន់ៗវិញ។ ថ្នាក់ជាតិត្រូវបង្កើតក្រុមគ្រូបង្គោលថ្នាក់ខេត្ត ដើម្បីឱ្យទទួលភារកិច្ចបណ្តុះបណ្តាលនេះ។ ការបណ្តុះបណ្តាលដល់គ្រូបង្គោលខេត្តគួរធ្វើតាមតំបន់ដោយពិនិត្យលើលទ្ធភាពនៃការប្រើប្រាស់មជ្ឈមណ្ឌលបណ្តុះបណ្តាលប្រចាំតំបន់ ឬសាលាបណ្តុះបណ្តាលឆ្មប ។

៤. បណ្តុះបណ្តាលមន្ត្រីគ្រប់គ្រងកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនៈ ត្រូវធ្វើការបណ្តុះបណ្តាលដល់មន្ត្រីខេត្តនិងស្រុកប្រតិបត្តិ ស្តីពីការគ្រប់គ្រងផ្នែកផ្គត់ផ្គង់ និងគ្រប់គ្រងការតាមដានវាយតម្លៃ ដោយហេតុថាការធ្វើផែនការ ការអភិបាល ការតាមដាននិងវាយតម្លៃ សកម្មភាពការងារនឹងត្រូវធ្វើតាមបែបវិមជ្ឈការ ។

## ៤.៣.៣ គោលបំណងទី៣

ពង្រឹងការអនុវត្តន៍ និងធ្វើការតាមដានលើការអនុវត្តន៍គោលនយោបាយជាតិនិងគោលការណ៍ណែនាំជាតិស្តីពីការចិញ្ចឹមទារក និងកុមារតូចៗក្នុងបរិបទនៃមេរោគអេដស៍-ជម្ងឺអេដស៍ឱ្យបានគ្រប់កន្លែងផ្តល់សេវាទាំងនៅសហគមន៍ដោយមានការចូលរួមពីគ្រប់ដៃគូទាំងអស់ ។

### យុទ្ធវិធី

- ពង្រឹងសមត្ថភាពបុគ្គលិកកម្មវិធីបង្ការការចម្លងមេរោគអេដស៍គ្រប់កំរិតអំពីអាហារូបត្ថម្ភ និងការចិញ្ចឹមទារក និងកុមារតូចៗក្នុងបរិបទនៃមេរោគអេដស៍។
- ពង្រឹងការអនុវត្តន៍គោលនយោបាយជាតិនិងគោលការណ៍ណែនាំជាតិស្តីពីអាហារូបត្ថម្ភនិងការចិញ្ចឹមទារក និងកុមារតូចៗក្នុងបរិបទនៃមេរោគអេដស៍។ ធានាថាគោលការណ៍ទាំងនេះស្របគ្នាជាមួយគោលការណ៍ស្តង់ដាអន្តរជាតិដែលថ្មីបំផុត។ ព័ត៌មានទាំងឡាយទាក់ទងទៅនឹងការអនុវត្តន៍គោលការណ៍ណែនាំ ត្រូវផ្សព្វផ្សាយដោយ ឈរលើភស្តុតាងអនុវត្តជាក់ស្តែងនៅកម្ពុជា។

### សកម្មភាពសំខាន់ៗ

១. ផ្សព្វផ្សាយព័ត៌មានស្តីពីគោលនយោបាយស្តីពីការចិញ្ចឹមទារកនិងកុមារតូចៗ ឱ្យបានច្បាស់លាស់ដល់បុគ្គលិកសុខាភិបាលគ្រប់កំរិត ដើម្បីជៀសវាងការផ្តល់សារផ្សេងពីគ្នាទៅដល់សហគមន៍។

២. បើកកិច្ចប្រជុំថ្នាក់ជាតិស្តីពីការចិញ្ចឹមកូន ដើម្បីពិនិត្យមើលពីរបាយការណ៍ស្រាវជ្រាវរបស់ពិភពលោក ជាមួយនឹងទិន្នន័យដែលប្រមូលបាននៅក្នុងប្រទេស ដើម្បីឱ្យគ្រប់គ្នាបានយល់កាន់តែប្រសើរឡើង ពីផលប៉ះពាល់ និងផលចំណេញនៃវិធីចិញ្ចឹមផ្សេងៗគ្នា និងដើម្បីផ្សព្វផ្សាយពីគោលនយោបាយជាតិផងដែរ ។

៣. រៀបចំបង្កើតឯកសារសំរាប់ផ្សព្វផ្សាយអប់រំ និងទំនាក់ទំនងព័តិមានសំរាប់ជួយដល់ស្ត្រីមានផ្ទៃពោះឱ្យធ្វើការជ្រើសរើសវិធីចិញ្ចឹមកូនសមស្របទោះបីជាម្តាយចិញ្ចឹមកូនដោយទឹកដោះគ្លី ដោយទឹកដោះគោម្សៅក្តី ។

៤. ផ្តល់ការគាំទ្របច្ចេកទេសនូវវិធីចិញ្ចឹមកូនដល់ស្ត្រីផ្ទុកមេរោគអេដស៍ដែលជ្រើសរើសការចិញ្ចឹមកូនដោយអាហារជំនួសទឹកដោះម្តាយក្នុងបរិយាកាសពោរពេញដោយភាពកក់ក្តៅ ដែលនេះជាយុទ្ធសាស្ត្រអាទិភាពមួយនៃកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ។

## ៤.៣.៤ គោលបំណងទី៤

ធ្វើការប្រមូលទិន្នន័យគ្រប់គ្រងទិន្នន័យ និងប្រើប្រាស់ទិន្នន័យឱ្យមានប្រសិទ្ធិភាពនៅគ្រប់លំដាប់ថ្នាក់សំរាប់ការធ្វើផែនការសកម្មភាពការអនុវត្តន៏កម្មវិធីការកែលំអគុណភាពនៃសេវា និងសំរាប់តាមដានអ្នកជម្ងឺឱ្យបានជាប់ជាប្រចាំ ។

## យុទ្ធវិធី

- ពិនិត្យឡើងវិញ និងកែសំរួលប្រព័ន្ធតាមដានកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនដែលកំពុងតែប្រើប្រាស់ក្នុងពេលបច្ចុប្បន្ន។ កែសំរួល និងផ្សព្វផ្សាយពីគោលការណ៍ណែនាំស្តីពីការតាមដាន និងវាយតម្លៃ ដែលក្នុងនោះមានរួមទាំងឧបករណ៏សំរាប់ប្រមូលទិន្នន័យនិងសំរាប់ធ្វើរបាយការណ៏ ដើម្បីងាយស្រួលក្នុងការតាមដាន ផ្ទៀងផ្ទាត់ជាមួយនឹង សុច្ចនករសំខាន់ៗ ។
- ពង្រឹងការកត់ត្រាទិន្នន័យ (រួមទាំងពិនិត្យផ្ទៀងផ្ទាត់គុណភាពទិន្នន័យ) ការធ្វើរបាយការណ៏ និងការគ្រប់គ្រងទិន្នន័យនៅតាមសេវានានា នៅថ្នាក់ស្រុកប្រតិបត្តិថ្នាក់ខេត្ត និងថ្នាក់ជាតិ តាមរយៈការអភិវឌ្ឍន៏សមត្ថភាពការអភិបាល និងការគ្រប់គ្រងផ្នែកតាមដាននិងវាយតម្លៃ។
- លើកទឹកចិត្តឱ្យមានការប្រើប្រាស់និងផ្សព្វផ្សាយទិន្នន័យនៃកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន (កម្មវិធីអេដស៍ និងកម្មវិធីសុខភាពមាតានិងទារក) នៅឯថ្នាក់ជាតិ និងថ្នាក់ខេត្ត ដើម្បីជំរុញឱ្យការធ្វើផែនការកម្មវិធីការគ្រប់គ្រង និងការសហការសំរបសំរួលកាន់តែមានភាពប្រសើរឡើង ។
- ពង្រឹងសមត្ថភាពតាមដាន និងវាយតម្លៃនៃកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន នៅគ្រប់ក៏រិតទាំងអស់តាមរយៈការបណ្តុះបណ្តាលសកម្មភាពគ្រប់បែបយ៉ាង ។
- លើកទឹកចិត្តនិងគាំទ្រយ៉ាងសកម្មដល់គម្រោងផ្តួចផ្តើមថ្មីៗលើការអនុវត្តន៏យុទ្ធសាស្ត្រសកលលោកទាំង៤នៃកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ដែលក្នុងនោះមានបញ្ចូលពីការផ្តល់អាហារូបត្ថម្ភ និងវិធីចិញ្ចឹមទារក និងកុមារតូចៗផងដែរ ។

**សកម្មភាពសំខាន់ៗ:**

១. ពិនិត្យឡើងវិញនូវសុចនាករសំខាន់ៗ។ កំណត់ឱ្យបានច្បាស់លាស់នូវនិយមន័យនៃសុចនាករការប្រមូលទិន្នន័យ និង ប្រព័ន្ធរបាយការណ៍។ កំណត់ឱ្យបានច្បាស់ពីនីតិវិធីនៃការប្រមូលទិន្នន័យ និងរបៀបប្រើប្រាស់ឧបករណ៍ សំរាប់តាមដាននិងវាយតម្លៃដោយផ្ដោតជាសំខាន់ទៅលើការសំរបសំរួលការប្រមូលទិន្នន័យពីប្រភពផ្សេងៗ និងការចែកចាយព័ត៌មាន ឱ្យគ្នាទៅវិញទៅមក រវាងតំបន់ដែលមានផ្ដល់សេវាសំរាលកូនណាមួយ ទៅកាន់ថ្នាក់ស្រុកប្រតិបត្តិបន្ទាប់មកទៅថ្នាក់ខេត្តនិងថ្នាក់ជាតិ និងការចែកចាយព័ត៌មានឱ្យគ្នាទៅវិញទៅមករវាងតំបន់ ដែលមានផ្ដល់សេវាសំរាលកូនណាមួយ ទៅកាន់តំបន់ដូចគ្នាមួយទៀតដើម្បីតាមដានអ្នកជម្ងឺឱ្យបានជាប់លាប់ល្អពីគ្រប់សេវាទាំងឡាយដែល អ្នកជម្ងឺបានទទួល។

២. រៀបចំឡើងវិញនូវគោលការណ៍ណែនាំនីតិវិធីនៃការអនុវត្តន៍ព្រមទាំងឧបករណ៍សំរាប់តាមដាន និងវាយតម្លៃ។ ធ្វើការផ្សព្វផ្សាយពីគោលការណ៍ដែលបានកែសំរួលថ្មីៗទាំងនោះ និងបណ្ដុះបណ្ដាលបុគ្គលិកធ្វើការនៅថ្នាក់ស្រុកប្រតិបត្តិ ថ្នាក់ខេត្ត និងថ្នាក់ជាតិពីរបៀបប្រើប្រាស់ឧបករណ៍ទាំងនោះ ដោយផ្ដល់នូវការគាំទ្រ និង អភិបាលយ៉ាងជិតស្និទ្ធ ជាពិសេសនៅក្នុងតំណាក់កាលដំបូងនៃការអនុវត្តន៍កម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្ដាយទៅកូន។

៣. ផ្ដល់ព័ត៌មានត្រឡប់តាមពេលវេលាមួយជាក់លាក់ទៅ :

ក) សេវាបង្ការការចម្លងមេរោគអេដស៍ពីម្ដាយទៅកូន។ ដូច្នេះទិន្នន័យដែលប្រមូលបាននឹងត្រូវបានប្រើប្រាស់ដើម្បីឆ្លុះបញ្ចាំងភាពរីកចំរើនរបស់កម្មវិធី។

ខ) អ្នកគ្រប់គ្រង និងអ្នកសំរបសំរួលនៅថ្នាក់ស្រុកប្រតិបត្តិ ថ្នាក់ខេត្ត និងថ្នាក់ជាតិ។ ដូច្នេះ ទិន្នន័យដែលប្រមូលបាននឹងត្រូវបានប្រើប្រាស់សំរាប់ធ្វើឱ្យការបង្កើតផែនការ ការគ្រប់គ្រង និងការសំរបសំរួលកាន់តែប្រសើរឡើង។

៤. ផ្ដល់ការគាំទ្រប្រព័ន្ធអភិបាលវិមជ្ឈកាលសំរាប់កម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្ដាយទៅកូនដោយធ្វើការបណ្ដុះបណ្ដាលផ្នែកតាមដាន និងវាយតម្លៃដល់មន្ត្រី-បុគ្គលិកនៅថ្នាក់ខេត្ត និងថ្នាក់ស្រុក តាមរយៈការវាយតម្លៃពីតំរូវការបណ្ដុះបណ្ដាលសមត្ថភាពនៃមន្ត្រីមូលដ្ឋាន។

៥. លើកទឹកចិត្ត និងគាំទ្រដល់ការវាយតម្លៃ និងការសិក្សាស្រាវជ្រាវលើប្រធានបទជាក់លាក់ទាក់ទងទៅនឹងកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្ដាយទៅកូន ដើម្បីកំណត់រកវិធីសាស្ត្រដ៏ប្រសើរ បំផុតដែលអាចជូនជាព័ត៌មានដល់ថ្នាក់ដឹកនាំ និងដែលអាចជួយជំរុញការអនុវត្តន៍កម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្ដាយទៅកូនកាន់តែល្អប្រសើរឡើង។

(សូមអានព័ត៌មានលំអិតក្នុងឧបសម័ន្ធទី២ ទាក់ទងទៅនឹងសកម្មភាពតាមដាន និងវាយតម្លៃដែលបានលើកឡើងនៅក្នុងរបាយការណ៍នៃការពិនិត្យឡើងវិញរួមគ្នាលើកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្ដាយទៅកូន)។

## ៤.៤ តារាងម៉ាទ្រីកនៃផែនការយុទ្ធសាស្ត្រជាតិសំរាប់បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

| សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន | | |
|---|---|---|
| **គោលបំណង** | **យុទ្ធវិធី** | **សកម្មភាព** |
| ១) ពង្រីកការផ្តល់សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយនិងមានគុណភាពល្អដល់ស្ត្រីមានផ្ទៃពោះនិងកូនរបស់គាត់និងជាពិសេសដល់ក្រុមប្រឈមខ្ពស់ | ១.១) បង្កើតជាយុទ្ធវិធីសំរាប់ទំនាក់ទំនងមួយដើម្បីពង្រឹងការយល់ដឹងរបស់សហគមន៍ស្តីអំពីការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន និង ដើម្បីបង្កើនការចូលរួមរបស់ស្ត្រីមានផ្ទៃពោះឱ្យមកទទួលយកសេវាបង្ការនេះតាមរយៈការចល័តធនធាននៅតាមសហគមន៍ និងតាមរយៈប្រព័ន្ធទំនាក់ទំនង | ១.១.១) កំណត់ឱ្យបាននូវចលនាស្ត្រីមានផ្ទៃពោះនៅតាមសហគមន៍ (ជាពិសេសស្ត្រីដែលជាក្រុមប្រឈមខ្ពស់នឹងការឆ្លងមេរោគអេដស៍) និង ដៃគូរបស់គាត់ឱ្យមកទទួលសេវាថែទាំផ្ទៃពោះ និងធ្វើតេស្តឈាម |
| | | ១.១.២) បង្កើតយន្តការទំនាក់ទំនងជាមួយក្រសួងកិច្ចការនារី ដើម្បីឱ្យស្ថាប័នរដ្ឋាភិបាលទាំងពីរកាន់តែខ្លាំងក្នុង ការរៀបចំយុទ្ធសាស្ត្រនៅតាមសហគមន៍ឱ្យ កាន់តែមានប្រសិទ្ធភាពខ្លាំងឡើង |
| | | ១.១.៣) ផ្តល់ព័តិមានស្តីពីកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនដល់សហគមន៍ថ្នាក់ដឹកនាំ គ្រួសារប្រជាជន និងបុគ្គលម្នាក់ៗ ក្នុងបរិបទសុខភាពមាតាកុមារ និងផែនការគ្រួសារនៅពេលចុះធ្វើការផ្ទាល់ ជាមួយសហគមន៍ |
| | | ១.១.៤) បង្កើត និងផ្សព្វផ្សាយព័តិមានអប់រំ ទំនាក់ទំនងស្តីពីការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន សំរាប់សហគមន៍ដល់គ្រប់មណ្ឌលសុខភាពទាំងអស់ |
| | | ១.១.៥) គាំទ្រដល់គំនិតផ្តួចផ្តើមថ្មីៗដែលជួយជំរុញឱ្យស្ត្រីនិងដៃគូបានទទួលសេវាផ្តល់ប្រឹក្សាធ្វើតេស្តឈាមរកមេរោគអេដស៍ និងទទួលបានសេវាថែទាំផ្សេងៗទៀតយ៉ាងមានប្រសិទ្ធភាព និងប្រសិទ្ធផល |

| | | |
|---|---|---|
| | | ១.១.៦) ធ្វើការទំនាក់ទំនងតាមប្រព័ន្ធផ្សព្វផ្សាយដើម្បីឱ្យប្រជាជននៅតាមសហគមន៍ ថ្នាក់ដឹកនាំ និងបុគ្គល ម្នាក់ៗមានការយល់ដឹង និងចូលរួមបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ( ដូចជា ផ្សាយរឿងខ្លីៗតាមទូរទស្សន៍ វិទ្យុ ឬល្ខោន ដោយបង្ហាញពីកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនក្នុងបរិបទសុខភាពមាតា) |
| | | ១.១.៧) ធ្វើការទំនាក់ទំនងសំដៅផ្តោះទៅរកបុគ្គលដោយផ្តល់សារសំខាន់ៗ ដើម្បីបំពេញ និងពង្រឹងកម្លាំងចលនាសង្គម |
| | ១.២) បញ្ច្រាបសមាសភាគនៃសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ទៅក្នុងសកម្មភាពនៃមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក ព្រមទាំងធ្វើការ សហការយ៉ាងជិតស្និទ្ធជាមួយនឹងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និងកាមរោគ ដើម្បីពង្រីកតួនាទីក្រុមដែលធ្វើការនៅតាមសហគមន៍ | ១.២.១) ដាក់បញ្ចូលសកម្មភាពបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនដែលមាននៅឯគ្លីនិកថែទាំផ្ទៃពោះ និង នៅឯផ្នែកសំរាល ទៅក្នុងគោលការណ៍ណែនាំ នៃកញ្ចប់សកម្មភាពអប្បបរិមា និងកញ្ចប់សកម្មភាព បង្គ្រប់ ព្រោះវាជាសមាសភាគមួយនៃសេវា សុខភាពមាតា និងទារក ដែលមាននៅគ្រប់កំរិតទាំងអស់ ( រួមទាំង មន្ទីរពេទ្យជាតិផងដែរ) :<br>ក) លើកកំពស់យុទ្ធសាស្ត្រសកលនៃការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនទី១ និង ទី២ បន្ថែមពីលើយុទ្ធសាស្ត្រទី៣ និង ទី៤<br>ខ) ជំរុញ និងជួយស្ត្រីមានផ្ទៃពោះឱ្យមកទទួលសេវាថែទាំផ្ទៃពោះ និងសំរាលកូននៅមន្ទីរពេទ្យ<br>គ) ផ្តល់ការគាំទ្រដល់ស្ត្រីផ្ទុកមេរោគអេដស៍ទាំងនៅពេលមានផ្ទៃពោះ និងក្រោយសំរាល<br>ឃ) ផ្តល់ការគាំទ្រដល់កុមារប្រឈមនឹងមេរោគអេដស៍ រួមទាំងគាំទ្រដល់ការចិញ្ចឹមកូនផងដែរ |

| | | |
|---|---|---|
| | | ១.២.២) ពិនិត្យឡើងវិញនូវគោលការណ៍ណែនាំស្តីពីមាតុភាពគ្មានគ្រោះថ្នាក់ និងប្រាកដថា សកម្មភាព បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនគឺជាផ្នែកមួយនៃគោលការណ៍នេះ |
| | | ១.២.៣) ដាក់បញ្ចូលសកម្មភាពបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនទៅក្នុងនិយាមបែបបទអនុវត្ត ស្តង់ដា និងទៅក្នុងការបណ្តុះបណ្តាលក្រុមថែទាំអ្នកជម្ងឺនៅតាមផ្ទះ |
| | | ១.២.៤) អង្គការដែលធ្វើការនៅតាមសហគមន៍ត្រូវដាក់បញ្ចូលសកម្មភាពបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ទៅក្នុងការពង្រីកសកម្មភាពនិងការបណ្តុះបណ្តាល |
| | ១.៣) ផ្តល់ឱកាសធ្វើតេស្តឈាមដល់ស្ត្រីមានផ្ទៃពោះនិងដៃគូរបស់គាត់ឱ្យបានច្រើន | ១.៣.១) ពង្រីកសេវាធ្វើតេស្តឈាមដល់ស្ត្រីមានផ្ទៃពោះនៅមណ្ឌលសុខភាពតាមទីកន្លែងណាដែលមានសេវា ផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមឱ្យបានឆាប់រហ័ស បន្ថែមសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅតាមតំបន់ណាដែលមានសកម្មភាពប្រឈមខ្ពស់ និងដែលស្ថិតនៅឆ្ងាយពីមណ្ឌល ធ្វើតេស្តឈាម។ ដើម្បីធានាបាននូវការទទួលយកការធ្វើតេស្តឈាមរកមេរោគអេដស៍ឱ្យបានច្រើនបំផុតនៅតាមតំបន់ថែទាំសុខភាពពេល សម្រាលដែលមានផ្តល់សេវាបង្ការការចម្លងមេរោគ អេដស៍ពីម្តាយទៅកូនគេត្រូវ :<br>ក) ផ្តល់ព័ត៌មានមុនធ្វើតេស្តឈាមស្តីពីមេរោគអេដស៍/ការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅ កូនដល់ស្ត្រីមានផ្ទៃពោះនៅឯបន្ទប់អប់រំម្តាយ<br>ខ) ប្រើប្រាស់សៀវភៅរូបភាពមុនពេលធ្វើតេស្តឈាម នៅតាមគ្រប់មណ្ឌលសុខភាពទាំងអស់ ដើម្បី ជាជំនួយក្នុងការងារ<br>គ) ផ្តល់ការប្រឹក្សាមុនពេលធ្វើតេស្តឈាមជាលក្ខណៈបុគ្គល តែក្នុងករណីពិសេសស្នើសុំដោយស្ត្រីមានផ្ទៃពោះ ឬដៃគូរបស់គាត់ |

| | | |
|---|---|---|
| | | ១.៣.២) ពង្រីកវិធីសាស្ត្រផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមដែលផ្តួចផ្តើមដោយអ្នកផ្តល់សេវា ដោយប្រាកដថា បុគ្គលិកនៅគ្រប់មណ្ឌលសុខភាពទាំងអស់បាន ផ្តល់ព័ត៌មានស្តីពីមេរោគអេដស៍/ការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនដល់ស្ត្រីមានផ្ទៃពោះព្រមទាំងដៃគូរបស់គាត់ និងបានបញ្ជូនស្ត្រី (ឬបញ្ជូនសំណាកឈាម ស្ត្រី-នេះមានភាពងាយស្រួលជាង) ទៅធ្វើតេស្តឈាមនៅឯមណ្ឌល ធ្វើតេស្តឈាមដែលស្ថិតនៅជិតបំផុត ។ នៅថ្នាក់ខេត្តតំរូវឱ្យមានការសំរបសំរួលពីប្រធាន គាំពារសុខភាពមាតានិងទារកខេត្ត ។ ចំណែកឯនៅថ្នាក់ជាតិកិច្ចការនេះ តំរូវឱ្យមាននិយាមបែបបទអនុវត្តស្តង់ដាររវាងកម្មវិធីសុខភាពបន្តពូជ និងកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន |
| | | ១.៣.៣) ផ្តួចផ្តើមឱ្យមានកម្មវិធីសាកល្បងថ្មីៗ ដើម្បីវាយតម្លៃពីលទ្ធភាពដែលអាចធ្វើបាន និងវាយតម្លៃពីផលប៉ះពាល់នៃការផ្តល់ព័ត៌មានមុនធ្វើតេស្តឈាម ស្តីពីមេរោគអេដស៍/ការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន និងផលប៉ះពាល់នៃការធ្វើស្ក្រីនតេស្តឈាមរកមេរោគអេដស៍តាមរយៈវិធីផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមដែលផ្តួចផ្តើមដោយអ្នកផ្តល់សេវា<br><br>ក) ជ្រើសរើសគ្លីនិកដែលមិនទាន់មានសេវាបង្ការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ហើយស្ថិតនៅឆ្ងាយពីទីតាំងនៃសេវាធ្វើតេស្តឈាម<br><br>ខ) ធ្វើការបញ្ជាក់រាល់លទ្ធផលតេស្តដែលវិជ្ជមាននៅឯមណ្ឌលធ្វើតេស្តឈាម (ដោយបញ្ជូនសំណាកទីបឈាមអ្នកដែលរកឃើញថាវិជ្ជមាន ទៅមណ្ឌលធ្វើតេស្តឈាមដែលស្ថិតនៅជិតបំផុត)<br><br>គ) ត្រូវបញ្ចូលការត្រួតពិនិត្យគុណភាពនៃការធ្វើតេស្តឈាម និងធ្វើទៅតាមប្រព័ន្ធជាតិ |

| | | |
|---|---|---|
| | | ១.៣.៤) បង្កើនការធ្វើតេស្តឈាមរកមេរោគអេដស៍ដល់ដៃគូរបស់ស្ត្រីមានផ្ទៃពោះ ។ ការធ្វើតេស្តឈាមដល់ដៃគូស្ត្រីដែលមានផ្ទុកមេរោគអេដស៍អាចធ្វើឱ្យយើងរកឃើញករណីអ្នកឆ្លងមេរោគអេដស៍កាន់តែច្រើន ។ ការធ្វើតេស្តដល់ដៃគូស្ត្រីដែលគ្មានផ្ទុកមេរោគអេដស៍នឹងធ្វើឱ្យការផ្តល់ព័ត៌មានបង្ការកាន់តែមានប្រសិទ្ធភាពខ្ពស់ ពីព្រោះបុរសជាប្តីបានចូលរួមជាពិសេសក្នុងការបង្ការ កុំឱ្យមេរោគអេដស៍ឆ្លងទៅប្រពន្ធរបស់គាត់ |
| | ១.៤) បង្កើនការទទួលប្រើប្រាស់ឱសថប្រឆាំងមេរោគអេដស៍ចំពោះស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍និងកូនរបស់គាត់ | ១.៤.១) ល័ក្ខខ័ណ្ឌក្នុងការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ត្រូវប្តូរការរាប់កោសិកាសេដេ៤ ពីតិចជាង២៥០/មីក្រូលីត្រ ទៅតិចជាង៣៥០/មីក្រូលីត្រ ព្រមទាំងធានានូវគុណភាពនៃការផ្តល់ឱសថនេះផងដែរ |
| | | ១.៤.២) ធ្វើស្រ្តីនតេស្តឈាមរហ័សដល់ស្ត្រីដែលមិនដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍ ។ ត្រូវធ្វើតេស្តឈាមនៅពេលឈឺពោះសំរាល និងធ្វើការបញ្ជាក់លទ្ធផលតេស្តវិជ្ជមាននៅមណ្ឌលធ្វើតេស្តឈាម |
| | | ១.៤.៣) បង្កើនការផ្តល់សេវាបង្ការការចម្លងមេរោគអេដស៍នៅតាមគ្រឹះស្ថានសុខាភិបាលតាមរយៈ:<br>ក) ការសហការរវាងបុគ្គលិកនៅផ្នែកពិនិត្យផ្ទៃពោះ ជាមួយក្រុមថែទាំអ្នកជម្ងឺតាមផ្ទះ និងអង្គការ ធ្វើការនៅតាមសហគមន៍ ដើម្បីតាមដានស្ត្រីផ្ទុកមេរោគអេដស៍ឱ្យបានជាប់លាប់ល្អ និងសំរបសំរួលឱ្យគាត់មកសំរាលកូន នៅឯមន្ទីរពេទ្យដែលមានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ដោយជួយគាំទ្រដល់ថ្លៃធ្វើដំណើរ និង ថ្លៃសំរាលដល់គាត់ ។ |

| | | |
|---|---|---|
| | | ខ) គំរោងលើកទឹកចិត្តរបស់រដ្ឋាភិបាល<br>គ) ការលើកលែងថ្លៃបង់ប្រាក់សេវា និងថ្លៃឈ្នួលផ្សេងៗដល់ស្ត្រីក្រីក្រ ដែលក្នុងនោះមានស្ត្រីផ្ទុកមេរោគអេដស៍ផងដែរ ព្រមទាំងគាំទ្រដល់គោលនយោបាយលើកលែងការបង់ថ្លៃ ព្យាបាលដល់អ្នកក្រីក្រ<br>ឃ) ការលើកទឹកចិត្តអង្គការមិនមែនរដ្ឋាភិបាលឱ្យជួយគាំទ្រដល់សកម្មភាពបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ដោយផ្តល់ទឹកន្លែងស្នាក់នៅដល់ស្ត្រីផ្ទុកមេរោគអេដស៍ដែលរស់នៅឆ្ងាយពីមន្ទីរសម្ភពដែលមានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនមុនពេលស្ត្រីឈឺពោះសំរាលកូន<br>ង) សកម្មភាពនេះនឹងមានភាពងាយស្រួល បើសិនជាព័ត៌មាននៃការប្រឹក្សា ធ្វើតេស្តឈាមត្រូវបានបញ្ចូលទៅក្នុង ប័ណ្ណមាតា (ជាទំរង់លេខកូដ) ក្នុងសៀវភៅបញ្ជីពិនិត្យផ្ទៃពោះនិង សៀវភៅបញ្ជីសំរាលកូន (សូមអានកថាខណ្ឌតាមដាននិងវាយតម្លៃ)<br>ច) ដើម្បីធានាថាស្ត្រីដែលមានកោសិកាស៊ីឌីហ្វ័រលើសពី៣៥០/មីក្រូលីត្របានទទួលឱសថប្រឆាំង មេរោគអេដស៍បានពេញលេញ ម្តាយគួរទទួលបានឱសថណេវីរ៉ាពីន មួយដូសទុកនៅផ្ទះសំរាប់លេប នៅពេលឈឺពោះសំរាលមុនពេលមកដល់មន្ទីរពេទ្យ ។ ធ្វើបែបនេះដើម្បីធានា ថាស្ត្រីបានទទួលឱសថបង្ការបានគ្រប់គ្រាន់ទោះបីជាគាត់មកដល់មន្ទីរពេទ្យកៀកពេលនឹង សំរាលរយៈពេលតិចជាង ២ ម៉ោងក៏ដោយ ។ (គោលការណ៍ជាតិតំរូវឱ្យផ្តល់ឱសថ ណេវីរ៉ាពីន តែនៅពេលស្ត្រីមកសំរាលកូនរយៈ ពេលច្រើនជាង ២ម៉ោងប៉ុណ្ណោះ) ។ ការផ្តល់ឱសថណេវីរ៉ាពីនមួយដូសដល់ស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍បែបនេះ មិនបានលើកទឹកចិត្តឱ្យស្ត្រីសំរាលកូននៅផ្ទះទេ ។ |

| | | |
|---|---|---|
| | ១.៥) ធានាឱ្យបាននូវការបង្ការជាសកល និងការបង្ការគ្រោះប្រឈមនឹងការឆ្លងមេរោគអេដស៍ក្រោយមុតរបួសដល់គ្រប់បុគ្គលិកដែលធ្វើការផ្ទាល់ជាមួយអ្នកជម្ងឺ | ១.៥.១) ធានាការបង្ការជាសកល និងការបង្ការក្រោយប្រឈមនឹងការឆ្លងមេរោគអេដស៍ដោយការមុតរបួសដល់បុគ្គលិកសុខាភិបាលៈ<br>ក) ផ្តល់ការបណ្តុះបណ្តាលស្តីពីការបង្ការជាសកល និងការបង្ការក្រោយប្រឈមនឹងការ ឆ្លងមេរោគអេដស៍ ដោយការមុតរបួសដល់បុគ្គលិកសុខាភិបាល<br>ខ) ត្រៀមឱសថនិងបរិក្ខារចាំបាច់<br>គ) នៅមណ្ឌលនីមួយៗ កំណត់នីតិវិធីឱ្យបានច្បាស់លាស់នូវអ្នកទទួលខុសត្រូវ ដែលត្រូវទាក់ទងនៅ ពេលមានករណីមុតរបួសកើតឡើង |
| | ១.៦) បង្កើនចំណងទាក់ទង និងយន្តការបញ្ជូនរវាងសេវាព្យាបាលជម្ងឺអេដស៍ សេវា ជម្ងឺកាមរោគ សេវាសុខភាពបន្តពូជ និង សេវាផែនការគ្រួសារ ដើម្បីបង្កើនប្រសិទ្ធិភាព នៃយុទ្ធសាស្ត្រសកលលោកទី៣ និងដើម្បីផ្សារភ្ជាប់ទំនាក់ទំនងជាមួយ នឹងយុទ្ធសាស្ត្រសកលលោកទី១ ទី២ និងទី៤ | ១.៦.១) ផ្តល់ព័ត៌មានស្តីពីវិធីបង្ការកុំឱ្យឆ្លងមេរោគអេដស៍ឱ្យបានជាប្រចាំដល់គ្រប់អតិថិជនដែលមកទទួល លទ្ធផលទាំងអស់ |
| | | ១.៦.២) បញ្ជូនស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ទៅសេវាព្យាបាលជម្ងឺអេដស៍ដើម្បីវាយតម្លៃពីលទ្ធភាពក្នុងការទទួលឱសថប្រឆាំងមេរោគអេដស៍ និងធ្វើការតាមដានបន្ត |
| | | ១.៦.៣) បញ្ជូនស្ត្រីមានផ្ទៃពោះដែលធ្វើការនៅផ្នែកកំសាន្តសប្បាយ និងស្ត្រីដែលប្រឈមខ្ពស់រស់នៅតាមសហគមន៍ និងនៅតាមគ្លីនិកជម្ងឺកាមរោគឱ្យមកធ្វើតេស្តឈាមរកមេរោគអេដស៍ និងបញ្ជូនមក សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនប្រសិនបើអាចធ្វើបាន |
| | | ១.៦.៤) ផ្តល់ព័ត៌មានអំពីផែនការគ្រួសារដល់ស្ត្រីទាំងអស់ រួមទាំងស្ត្រីផ្ទុកមេរោគអេដស៍ព្រមទាំងដៃគូរបស់គាត់ និងបញ្ជូនពួកគាត់មកទទួលសេវាផែនការគ្រួសារ ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើក្រោយសំរាលកូន<br>**ចំណាំ :** ស្ត្រីផ្ទុកមេរោគអេដស៍ដែលកំពុងតែទទួលការថែទាំនិងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ត្រូវជំរុញគាត់ឱ្យមកទទួលសេវាផែនការគ្រួសារ |

| | | |
|---|---|---|
| | | ១.៦.៥) បញ្ជូនស្ត្រីផ្ទុកមេរោគអេដស៍ឱ្យមកទទួលសេវាព្យាបាលជម្ងឺកាមរោគតាមកាលៈទេសៈសមស្រប |
| | | ១.៦.៦) បញ្ជូនស្ត្រីផ្ទុកមេរោគអេដស៍ទៅក្រុមថែទាំអ្នកជម្ងឺនៅតាមផ្ទះនិងអង្គការតាមសហគមន៍ ដើម្បីទទួលការគាំទ្រនិងថែទាំបន្ត រួមទាំងការចិញ្ចឹមកូនផងដែរ ទោះបីជាគាត់ជ្រើសរើសការចិញ្ចឹមកូនដោយដោះក្តី ដោយទឹកដោះគោម្សៅក្តី |
| | ១.៧) ធានាថាកុមារប្រឈមត្រូវបានតាមដានជាប់ជាប្រចាំមានលក្ខណៈគ្រប់ជ្រុងជ្រោយនិងត្រូវបានធ្វើតេស្តឈាមរករោគវិនិច្ឆ័យជម្ងឺអេដស៍បានទាន់ពេល | ១.៧.១) បញ្ជូនកុមារប្រឈមទាំងអស់ឱ្យទៅទទួលសេវាថែទាំជម្ងឺអេដស៍កុមារ ដើម្បីទទួលការបង្ការ ដោយឱសថកូទ្រីម៉ុកសាសុល និងធ្វើរោគវិនិច្ឆ័យការឆ្លងមេរោគអេដស៍លើកុមារឱ្យបានឆាប់រហ័ស ដោយមានការជំនួយពីក្រុមថែទាំអ្នកជម្ងឺតាមផ្ទះនិងអង្គការសហគមន៍ផ្សេងៗទៀត ។<br>**ចំណាំ:** បន្ទាប់ពី៦សប្តាហ៍នៃការតាមដាននៅឯសេវាថែទាំជម្ងឺអេដស៍ ការតាមដានបន្តនិងការផ្តល់ឱសថ កូទ្រីម៉ុកសាសុលបន្ត អាចត្រូវបានផ្តល់ដោយផ្ទួបនៅសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ( បន្ទាប់ពីបណ្តុះបណ្តាលរួចហើយ) បើសិនជាសេវាថែទាំជម្ងឺអេដស៍កុមារនៅឆ្ងាយ ។ តែទោះបីជាយ៉ាងណាក៏ដោយកុមារត្រូវតែបញ្ជូនត្រឡប់មកសេវាថែទាំជម្ងឺកុមារវិញបើសិនជា មានជម្ងឺ ឬក៏សង្ស័យថាមានប្រតិកម្មជាមួយនឹងថ្នាំ ។ ក្រុមថែទាំអ្នកជម្ងឺតាមផ្ទះ និងក្រុមធ្វើការផ្ទាល់ជាមួយសហគន៏ត្រូវតាមដានកុមាររហូតដល់កំណត់ច្បាស់ថាកុមារលែងប្រឈមនឹងការឆ្លងមេរោគអេដស៍ |
| | | ១.៧.២) ធ្វើការវាយតម្លៃជាអាទិភាពពីការចិញ្ចឹមកូននិងផ្តល់ប្រឹក្សាដល់ស្ត្រីផ្ទុកមេរោគអេដស៍ជាពិសេស:<br>ក) នៅពេលធ្វើរោគវិនិច្ឆ័យជម្ងឺអេដស៍កុមារនៅពេលដំបូង<br>ខ) នៅពេលចាប់ផ្តើមផ្តល់អាហារបន្ថែមដល់កុមារ នៅពេលវាមានអាយុ៦ខែ |

| | | |
|---|---|---|
| | | ១.៧.៣) ផ្សារភ្ជាប់ទំនាក់ទំនងរវាងមណ្ឌលសុខភាពជាមួយនឹងអង្គការនៅតាមសហគមន៍ ដើម្បីផ្តល់ការតាមដានថែទាំបន្តដល់ស្ត្រីផ្ទុកមេរោគអេដស៍ ( មានក្រុមថែទាំអ្នកជម្ងឺនៅតាមផ្ទះ ក្រុមស្ម័គ្រចិត្តគាំទ្រសុខភាពនៅ តាមភូមិ ក្រុមគាំទ្រមាតា ។ល ។) |
| | | ១.៧.៤) ពង្រឹងការលើកកំពស់និងតាមដានការលូតលាស់របស់កុមារនៅតាមមណ្ឌលសុខភាព ដោយប្រើប្រាស់ ការតាមដានកុមារ |
| **ការគ្រប់គ្រងកម្មវិធី និង ភាពជាដៃគូ** | | |
| **គោលបំណង** | **យុទ្ធវិធី** | **សកម្មភាព** |
| ២) ពង្រឹងការធ្វើផែនការកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ការគ្រប់គ្រងការសំរបសំរួលការអនុវត្តន៍ និងការអភិបាលឱ្យបានគ្រប់កំរិតដើម្បីធ្វើឱ្យកម្មវិធីសំរេចបានគោលដៅចំណុចឆ្នាំ២០០៨-២០១៥ ។ | ២.១) ពង្រឹងការធ្វើផែនការកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅគ្រប់កំរិតតាមរយៈផែនការប្រតិបត្តិប្រចាំឆ្នាំ និងមានគោលដៅប្រជាជនចំណុច | ២.១.១) បង្កើតចំណុចគោលដៅប្រចាំឆ្នាំសំរាប់ថ្នាក់ស្រុកប្រតិបត្តិ ( មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក) ថ្នាក់ខេត្ត និងថ្នាក់ជាតិ ដើម្បីឱ្យការប្រើប្រាស់សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនកាន់តែប្រសើរឡើង និងដើម្បីជាមគ្គុទេសន៍សំរាប់ការពង្រីកកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពី ម្តាយទៅកូន ដោយផ្តោតជាជាដំបូងលើខេត្តដែលមានអទិភាព ។ |
| | | ២.១.២) រៀបចំផែនការសកម្មភាពប្រចាំឆ្នាំ |
| | | ២.១.៣) រៀបចំផែនការរំកិល៣ឆ្នាំ |
| | | ២.១.៤) រៀបចំសិក្ខាសាលាប្រចាំឆ្នាំជាមួយគ្រប់ដៃគូ |
| | | ២.១.៥) ធ្វើរបាយការណ៍ប្រចាំត្រីមាសនិងប្រចាំឆ្នាំដែលមានបញ្ចូលរបាយការណ៍ជាតិ របាយការណ៍ខេត្ត និង របាយការណ៍របស់គ្លីនិកឯកជន ព្រមទាំងធ្វើការផ្សព្វផ្សាយផងដែរ |

| | | |
|---|---|---|
| | | ២.១.៦) ខេត្តត្រូវធ្វើផែនការវិមជ្ឈការប្រចាំឆ្នាំដោយយោងទៅលើចំណុចគោលដៅថ្នាក់ជាតិ<br>ក) ផ្អែកលើយន្តការផែនការដែលមានស្រាប់ ស្របជាមួយការគាំទ្ររបស់ដៃគូ<br>ខ) យកចិត្តទុកដាក់លើស្ថានភាពជាក់លាក់ក្នុងមូលដ្ឋាន ដោយបញ្ចូលទាំងធនធានដែលមានស្រាប់នៅក្នុងខេត្ត និងដៃគូអភិវឌ្ឍន៏<br>គ) គាំទ្រសកម្មភាពវិមជ្ឈការសំខាន់ៗ ដែលបច្ចុប្បន្នកំពុងតែអនុវត្តនៅថ្នាក់ជាតិ ដូចជាការបណ្តុះបណ្តាល និងការអភិបាល<br>ឃ) ការិយាល័យកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនត្រូវរៀបចំណែនាំ និង សុច្ចនករសំរាប់ វាស់វែងសកម្មភាពការងារឬពិនិត្យមើលជោគជ័យនៃកម្មវិធី<br>ង) ការិយាល័យបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ត្រូវផ្តល់ព័តិមានត្រឡប់រៀងរាល់៣ខែម្តង ទៅអ្នកសំរបសំរួលខេត្តដើម្បីបង្ហាញភាពរីក ចំរើន និងការអនុវត្តន៏របស់ខេត្តនីមួយៗ ដោយប្រៀបធៀបជាមួយ និងសុច្ចនករជាតិ ។ អ្នកសំរបសំរួលខេត្តត្រូវផ្តល់ព័តិមានត្រឡប់រៀងរាល់ ត្រីមាសទៅថ្នាក់ស្រុកផងដែរ ពីការអនុវត្តន៏ និងការរីកចំរើនរបស់គេ ។ |
| | ២.២) ពង្រឹងការគ្រប់គ្រងកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅថ្នាក់ជាតិដោយធ្វើការពង្រឹងតួនាទីក្រុមការងារបច្ចេកទេសលេខាធិការដ្ឋាន | ២.២.១) កែសំរួលរចនាសម្ព័ន្ធ និងមុខងាររបស់ក្រុមការងារបច្ចេកទេសបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនដើម្បីឆ្លុះបញ្ចាំងពីគោលបំណងនៃការពង្រីកកម្មវិធីជាតិ និងការពង្រឹងទំនាក់ទំនង ដើម្បីធានាឱ្យការថែទាំបន្តឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដូចជា:<br>ក) មុខងារសហប្រធាន និងភាពដឹកនាំច្បាស់លាស់នៃមជ្ឈមណ្ឌលជាតិគាំពារមាតា |

| | | |
|---|---|---|
| | នៃកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន និងលើកកំពស់កិច្ចសំរបសំរួលជាមួយនឹងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និងកាមរោគ | និងទារក និង មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និងកាមរោគ<br>ខ) កែសំរួលសមាជិកភាពនៃក្រុមការងារបច្ចេកទេសដើម្បីឆ្លុះបញ្ចាំងពីដៃគូការងារដែលជាប់ពាក់ព័ន្ធ<br>គ) អញ្ជើញតំណាងស្ថាប័នផ្សេងៗដែលសមស្រប ដើម្បីពិភាក្សាពីបញ្ហាជាក់លាក់ផ្សេងៗ<br>ឃ) គាំទ្រការអភិវឌ្ឍន៍និងការអនុវត្តន៍កម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ដែលនៅក្នុងនោះ មានការគាំទ្រដល់វិធីអនុវត្តផ្តួចផ្តើមថ្មីៗ ដើម្បីផ្តល់សេវានៅតាមតំបន់ដែលត្រូវបានជ្រើសរើស ។<br>ង) ពង្រឹងបន្ថែមការចូលរួមនៃកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនទៅក្នុងក្រុមការងារបច្ចេកទេសនៃគំរោងថែទាំបន្ត<br>ច) ពង្រឹងតួនាទី និងការទទួលខុសត្រូវនូវការតាមដាននិងវាយតម្លៃ<br>ឆ) បង្កើតអនុក្រុមការងារបច្ចេកទេសសមស្រប |
| | | ២.២.២) ពង្រឹងបន្ថែមនូវសមត្ថភាពនៃការិយាល័យកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនដែលជាកម្មវិធីដ៏សំខាន់មួយនៃមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក :<br>ក) ពង្រឹងការសហការរវាងកម្មវិធីផ្សេងៗនៅក្នុងមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក<br>ខ) ពង្រឹងសមត្ថភាពនៃមន្ត្រីការិយាល័យកម្មវិធីជាតិបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន |

| | | |
|---|---|---|
| | | គ) លើកយកប្រធានបទនៃកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ទៅចូលរួមប្រជុំក្នុងអនុក្រុមការងារបច្ចេកទេសសុខាភិបាលជាតិ និងអនុក្រុមការងារបច្ចេកទេស ផ្សេងៗទៀតដែលសមស្រប<br>ឃ) ផ្សារភ្ជាប់សកម្មភាពបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនទៅនឹងសកម្មភាពគាំពារមាតា និងទារក |
| | | ២.២.៣) តែងតាំងមន្ត្រីខាងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និងកាមរោគ សំរាប់ទំនាក់ទំនង ជាមួយកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនដើម្បីៈ<br>ក) ប្រតិបត្តិ និងតាមដានការអនុវត្តន៍សកម្មភាពបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន រួមគ្នា រវាងមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក ជាមួយនឹងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និងកាមរោគ<br>ខ) ត្រួតពិនិត្យ សហប្រតិបត្តិការលើគំរោងផ្តួចផ្តើមថ្មីៗ<br>គ) គាំទ្រដល់ក្រុមការងារបច្ចេកទេសនៃកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន និងក្រុមការងារបច្ចេកទេសនៃគំរោងថៃទាំបន្ត<br>ឃ) វិភាគពីប្រសិទ្ធិភាពនៃការធ្វើហិរញ្ញកិច្ចសំរាប់កម្មវិធីអេដស៍ឱ្យបានទូលំទូលាយ |
| | ២.៣) ពង្រឹងការសំរបសំរួលកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅ ថ្នាក់ជាតិ និងថ្នាក់ខេត្ត | ២.៣.១) ពង្រឹងបន្ថែមពីការចូលរួមនៃកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ក្នុងក្រុមការងារបច្ចេកទេសនៃគំរោងថៃទាំបន្ត |
| | | ២.៣.២) ធ្វើការសំរបសំរួលជាមួយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និងកាមរោគ កម្មវិធីជាតិ សុខភាពបន្តពូជ និងកម្មវិធីជាតិអាហារូបត្ថម្ភ |

| | | |
|---|---|---|
| | | ២.៣.៣) សំរបសំរួលឱ្យមានរបាយការណ៍រួមគ្នា និងត្រួតពិនិត្យឡើងវិញរួមគ្នា នៅថ្នាក់ខេត្ត និងថ្នាក់ស្រុក |
| | | ២.៣.៤) គ្រប់គ្រងការផ្គត់ផ្គង់សំភារៈនិងឧបករណ៍នៅថ្នាក់ខេត្ត ។ ធ្វើការបញ្ជាក់ឱ្យបានច្បាស់លាស់ពីរបៀបគ្រប់គ្រងការផ្គត់ផ្គង់សំភារៈដល់អ្នកអនុវត្ត និងជាពិសេសអ្នកសំរបសំរួលកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន |
| | | ២.៣.៥) ដើម្បីឱ្យការសំរបសំរួលកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន និងគំរោងថែទាំបន្តដល់ អ្នកផ្ទុកមេរោគអេដស៍មានដំណើរការកាន់តែល្អប្រសើរ រាល់ការប្រជុំ ឬកិច្ចជួបជុំទាំងឡាយត្រូវមានប្រធានបទទាក់ទងទៅនឹងការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ។ ឧ : ការតាមដាននិងវាយតម្លៃ ការតាមដានអ្នកជម្ងឺ (រួមទាំងតំរូវការរបស់ស្ត្រីផ្ទុកមេរោគអេដស៍ដែលបានរកឃើញ) ការធ្វើផែនការ ការបញ្ជូនពីសេវា មួយទៅសេវាមួយទៀតជាដើម ។ |
| | ២.៤) ធ្វើវិមជ្ឈការសមាសភាគសំខាន់ៗនៃកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ដូចជាការបណ្តុះបណ្តាល និងការធ្វើអភិបាលកិច្ច | ២.៤.១) បញ្ចូលកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនទៅក្នុងការបណ្តុះបណ្តាលទូទៅ មុនពេលអនុវត្តការងារនៅតាមមន្ទីរពេទ្យដល់ឆ្មប គិលានុប្បដ្ឋាក និងវេជ្ជបណ្ឌិត |
| | | ២.៤.២) ធ្វើវិមជ្ឈការនៃការបណ្តុះបណ្តាលដល់បុគ្គលិកផ្នែកបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនៈ<br>ក) បង្កើតគ្រូបណ្តុះបណ្តាលនៅតាមខេត្តនីមួយៗ<br>ខ) ខេត្តនីមួយៗត្រូវរៀបចំផែនការសកម្មភាព និងផែនការថវិកាប្រចាំឆ្នាំ |
| | | ២.៤.៣) ធ្វើវិមជ្ឈការនៃការអភិបាលដល់ខេត្ត ដើម្បីចុះទៅអភិបាលនៅតាមមណ្ឌលនីមួយៗ |

| អាហារូបត្ថម្ភ និងការចិញ្ចឹមទារកនិងកុមារតូចៗ | | |
|---|---|---|
| **គោលបំណង** | **យុទ្ធវិធី** | **សកម្មភាព** |
| ៣) ពង្រឹងការអនុវត្តន៍ និងធ្វើការតាមដានលើការអនុវត្តន៍គោលនយោបាយជាតិ និងគោលការណ៍ណែនាំជាតិស្តីពីការចិញ្ចឹមទារកនិងកុមារតូចៗក្នុងបរិបទនៃមេរោគអេដស៍-ជម្ងឺអេដស៍ឱ្យបានគ្រប់កន្លែងផ្តល់សេវាទាំងនៅសហគមន៍ដោយមានការចូលរួមពីគ្រប់ដៃគូទាំងអស់ ។ | ៣.១) ពង្រឹងការអនុវត្តន៍គោលនយោបាយជាតិនិងគោលការណ៍ណែនាំជាតិស្តីពីអាហារូបត្ថម្ភ និងការចិញ្ចឹមទារក និងកុមារតូចៗក្នុងបរិបទនៃមេរោគអេដស៍ ។ | ៣.១.១) បើកកិច្ចប្រជុំពិភាក្សាបច្ចេកទេសស្តីពីអាហារូបត្ថម្ភ និងការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ដែលក្នុងនោះមានអាហារូបត្ថម្ភសំរាប់ម្តាយ និងការចិញ្ចឹមទារក និងកុមារតូចៗ:<br>ក) ពិនិត្យវាយតម្លៃពីការស្រាវជ្រាវថ្មីៗ និងភស្តុតាងនៃការអនុវត្តន៍កម្មវិធីទាំងក្នុង និងក្រៅប្រទេស<br>ខ) បង្កើតគំនិតរួមមួយលើការអនុវត្តន៍វិធីចិញ្ចឹមកូន កាន់តែប្រសើរឡើង នៅក្នុងបរិបទនៃការរស់រានមានជីវិតរបស់កុមារ<br>គ) ផ្សព្វផ្សាយគោលនយោបាយជាតិ កែលំអគោលការណ៍ណែនាំជាតិ និងអនុវត្តការចិញ្ចឹមទារក និងកុមារតូចៗនៅក្នុងបរិបទនៃសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន |
| | ៣.២) ពង្រឹងសមត្ថភាពបុគ្គលិកកម្មវិធីបង្ការការចម្លងមេរោគអេដស៍គ្រប់កំរិតអំពីអាហារូបត្ថម្ភ និងការចិញ្ចឹមទារក និងកុមារតូចៗក្នុងបរិបទ នៃមេរោគអេដស៍ | ៣.២.១) ចាត់តាំងមន្ត្រីបង្គោលពីកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន និងកម្មវិធីអាហារូបត្ថម្ភ សំរាប់ធ្វើការងារចិញ្ចឹមទារកនិងកុមារតូចៗ នៅថ្នាក់ជាតិនិងថ្នាក់ខេត្ត |
| | | ៣.២.២) រៀបចំគោលដៅចំណុចនៃអាហារូបត្ថម្ភ សំរាប់ស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ ដោយបញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រនៃការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន |

| | | |
|---|---|---|
| | | ៣.២.៣) ធានាទំនាក់ទំនងល្អជាមួយថ្នាក់ខេត្ត ឬថ្នាក់ស្រុកក្នុងការធ្វើផែនការការបណ្តុះបណ្តាល និងការតាមដានលើការចិញ្ចឹមទារកនិងកុមារតូចៗក្នុងបរិបទនៃមេរោគអេដស៍ |
| | | ៣.២.៤) នៅមណ្ឌលបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូននីមួយៗ ត្រូវមានអ្នកផ្តល់ប្រឹក្សាបង្គោលមួយ ក្នុងចំណោមអ្នកផ្តល់ប្រឹក្សាទាំងឡាយសំរាប់ផ្តល់ប្រឹក្សាពីការចិញ្ចឹមកូនដល់ស្ត្រីផ្ទុកមេរោគអេដស៍ |
| | | ៣.២.៥) បង្កើតព័ត៌មានសំរាប់ស្វែងរកការគាំទ្រអប់រំ ទំនាក់ទំនងស្តីពីការចិញ្ចឹមទារកនិងកុមារតូចៗ ដោយសហការជាមួយមជ្ឈមណ្ឌលជាតិលើកកំពស់សុខភាព |
| | | ៣.២.៦) លើកកំពស់ចលនាសង្គមនៅតាមសហគមន៍ និងធ្វើទំនាក់ទំនងជុំវិញគោលការណ៍ស្តង់ដាជាតិ ស្តីពីអាហារូបត្ថម្ភ និងការចិញ្ចឹមទារកនិងកុមារតូចៗ |
| | | ៣.២.៧) ផ្សព្វផ្សាយគោលនយោបាយនៃការចិញ្ចឹមទារកនិងកុមារតូចៗ និងបណ្តុះឱ្យមានការយល់ដឹងពីគោលនយោបាយនេះ |
| | | ៣.២.៨) រៀបចំផែនការបណ្តុះបណ្តាលជាតិដើម្បីពង្រឹងការចិញ្ចឹមកូនក្នុងបរិបទនៃមេរោគអេដស៍ |
| | | ៣.២.៩) ពន្លឿនការអភិវឌ្ឍន៍ជំនាញនិងសមត្ថភាពនៃអ្នកផ្តល់សេវារួមទាំងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលអំពីការចិញ្ចឹមកូនឱ្យបានប្រសើរ និងផ្តល់ប្រឹក្សាពីការចិញ្ចឹមកូនដោយភាពអព្យាក្រិត |
| | | ៣.២.១០) ត្រូវបណ្តុះបណ្តាលប្រធានគ្រប់គ្រងការងារនិងបុគ្គលិកនៃកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូននូវប្រធានបទស្តីពីការចិញ្ចឹមទារកនិងកុមារតូចៗ ដោយធ្វើការតាមដានលើការ បណ្តុះបណ្តាលនេះ ផងដែរ |

| ការតាមដាន និងវាយតម្លៃ | | |
|---|---|---|
| **គោលបំណង** | **យុទ្ធវិធី** | **សកម្មភាព** |
| ៤) ធ្វើការប្រមូលទិន្នន័យគ្រប់គ្រងទិន្នន័យ និងប្រើប្រាស់ទិន្នន័យឱ្យមានប្រសិទ្ធិភាពនៅគ្រប់លំដាប់ថ្នាក់សំរាប់ការធ្វើផែនការសកម្មភាព ការអនុវត្តន៏កម្មវិធីការកែលំអគុណភាពនៃសេវា និងសំរាប់តាមដានអ្នកជម្ងឺឱ្យបានជាប់ជាប្រចាំ | ៤.១) ពិនិត្យឡើងវិញ និងកែសំរួលប្រព័ន្ធតាមដានកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្ដាយទៅកូនដែលកំពុងតែប្រើប្រាស់ក្នុងពេលបច្ចុប្បន្ន ។ កែសំរួល និង ផ្សព្វផ្សាយពីគោលការណ៏ណែនាំស្ដីពីការតាមដាន និងវាយតម្លៃ ដែលក្នុងនោះមានរួមទាំងឧបករណ៏សំរាប់ប្រមូលទិន្នន័យ និងសំរាប់ធ្វើរបាយការណ៏ ដើម្បីងាយស្រួលក្នុងការតាមដានផ្ទៀងផ្ទាត់ជាមួយនឹងសុច្ចនករសំខាន់ៗ | ៤.១.១) ពិនិត្យឡើងវិញពីសុច្ចនករសំខាន់ៗនៃកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្ដាយទៅកូន និងកំណត់ និយមន័យឱ្យស្របគ្នានឹងប្រព័ន្ធតាមដាននិងវាយតម្លៃជាតិ និងគោលការណ៏ណែនាំរបស់កម្មវិធីប្រយុទ្ធនឹងជម្ងឺអេដស៍ ព្រមទាំងឱ្យស្របគ្នាជាមួយនឹងសុច្ចនករអន្តរជាតិដែលត្រូវ ធ្វើរបាយការណ៏ផងដែរ ។ ការពិនិត្យឡើងវិញនេះផ្ដោតជាពិសេស លើការប្រមូលទិន្នន័យពីគ្រប់ប្រភពទាំងអស់ និង សំរួលការតាមដានស្ត្រីផ្ទុកមេរោគអេដស៍ និងការចែកចាយព័ត៌មាននៅគ្រប់កំរិត និងពីសេវាមួយទៅសេវាមួយទៀត ។ |
| | | ៤.១.២) កែសំរួលឧបករណ៏សំរាប់ប្រមូលទិន្នន័យនិងធ្វើរបាយការណ៏ ។ ឧបករណ៏នេះត្រូវតែងាយស្រួល និងមានប្រសិទ្ធិភាពក្នុងការតាមដានអ្នកជម្ងឺ ( ឧ:បញ្ចូលព័ត៌មាននៃមេរោគអេដស៍ទៅក្នុងសៀវភៅបញ្ជីស្តង់ដា គាំពារមាតានិងទារក និងសៀវភៅសុខភាពមាតា) |
| | | ៤.១.៣) កែសំរួលនិងធ្វើឱ្យកាន់តែប្រសើរឡើងនូវគោលការណ៏ណែនាំសំរាប់តាមដាននិងវាយតម្លៃ ដើម្បីផ្ដល់ការណែនាំពីរបៀបប្រមូលទិន្នន័យឱ្យបានច្បាស់លាស់ដល់បុគ្គលិក ដើម្បីងាយស្រួលក្នុងការប្រមូលផ្ដុំទិន្នន័យ នៃការបង្ការការចម្លងមេរោគអេដស៍ពីម្ដាយទៅកូនពីសេវាថែទាំផ្ទៃពោះ សេវាសំរាល សេវាព្យាបាលជម្ងឺឱកាសនិយមនិងជម្ងឺអេដស៍នៅគ្រប់មណ្ឌលសុខភាព និងគ្រប់កំរិតទាំងអស់ |

| | | |
|---|---|---|
| | ៤.២) ពង្រឹងការកត់ត្រាទិន្នន័យ (រួមទាំង ពិនិត្យផ្ទៀងផ្ទាត់គុណភាពទិន្នន័យ) ការធ្វើរបាយការណ៍ និង | ៤.២.១) ពង្រឹងការកត់ត្រាទិន្នន័យ ការគ្រប់គ្រង និងការបញ្ជូនទិន្នន័យឱ្យស្របគ្នានឹងការណែនាំពីការតាមដាន និងវាយតម្លៃ តាមរយៈការបណ្តុះបណ្តាលសមត្ថភាព ការអភិបាល និងតាមរយៈការត្រួតពិនិត្យនៅគ្រប់កំរិត |
| | ការគ្រប់គ្រងទិន្នន័យ នៅតាមសេវានានា នៅថ្នាក់ស្រុកប្រតិបត្តិថ្នាក់ខេត្ត និងថ្នាក់ជាតិ តាមរយៈការអភិវឌ្ឍន៍សមត្ថភាពការអភិបាល និងការគ្រប់គ្រង ផ្នែកតាមដាននិងវាយតម្លៃ | ៤.២.២) ធានាឱ្យមានការអនុវត្តន៍ត្រួតពិនិត្យគុណភាពទិន្នន័យ ហើយដែលការត្រួតពិនិត្យគុណភាពទិន្នន័យនោះ បានឆ្លុះបញ្ចាំងពីគោលការណ៍ណែនាំដែលបានចែងនៅក្នុងការតាមដាន និងវាយតម្លៃ និង ពីតួនាទីរបស់បុគ្គលិក ដែលជាអ្នកប្រមូលទិន្នន័យ ។ ការប្រមូលទិន្នន័យត្រូវពង្រឹងតាមរយៈការផ្តល់ព័ត៌មានត្រឡប់ទៅអ្នកដែលប្រមូលទិន្នន័យ និងតាមរយៈការធ្វើអភិបាលកិច្ច ។ |
| | ៤.៣) លើកទឹកចិត្តឱ្យមានការប្រើប្រាស់ និងផ្សព្វផ្សាយទិន្នន័យនៃកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន (ទាំងកម្មវិធីអេដស៍ និងកម្មវិធីសុខភាពមាតានិងទារក) នៅឯថ្នាក់ជាតិនិងថ្នាក់ខេត្ត ដើម្បីជំរុញឱ្យការធ្វើផែនការកម្មវិធីការគ្រប់គ្រង និង ការសហការសំរបសំរួលកាន់តែមានភាពប្រសើរឡើង | ៤.៣.១) ពង្រឹងយន្តកម្មទំនាក់ទំនង និងប្រជុំជាប្រចាំ ដើម្បីផ្លាស់ប្តូរ ពិនិត្យលើទិន្នន័យដែលបានមកពីគ្រប់កំរិត និងពីគ្រប់សេវាទាំងអស់ (ឧ: សេវាថែទាំផ្ទៃពោះ សេវាសំរាល សេវាព្យាបាលជម្ងឺឱកាសនិយមនិងជម្ងឺអេដស៍) ដើម្បីជួយគាំទ្រដល់ការធ្វើផែនការ និងការគ្រប់គ្រងដល់ថ្នាក់ស្រុកប្រតិបត្តិ ថ្នាក់ខេត្ត និងថ្នាក់ជាតិ |
| | | ៤.៣.២) បង្ហាញនិងវិភាគទិន្នន័យនៅពេលប្រជុំថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់ស្រុកប្រតិបត្តិ ដោយមានការចូលរួមពីបុគ្គលិកផ្នែកតាមដាននិងវាយតម្លៃ ដើម្បីផ្តល់ព័ត៌មានពីការធ្វើផែនការ និងការគ្រប់គ្រងពីភាពរីកចំរើននៃឯកសារ និងដើម្បីកំណត់បានពីភាពលំបាកដែលត្រូវដោះស្រាយ ទាក់ទងទៅនឹងការអនុវត្តន៍និងការត្រួតពិនិត្យតាមដាន |
| | ៤.៤) ពង្រឹងសមត្ថភាពតាមដាននិងវាយតម្លៃនៃកម្មវិធីបង្ការការចម្លងមេរោគ | ៤.៤.១) ធ្វើការវាយតម្លៃលើសមត្ថភាពនៃការតាមដាននិងវាយតម្លៃ ដើម្បីកំណត់ពីតំរូវការ និងដើម្បីផ្តល់អាទិភាពក្នុងការបណ្តុះបណ្តាលស្របគ្នាជាមួយផែនការវិមជ្ឈការ |

| | | |
|---|---|---|
| | អេដស៍ពីម្តាយទៅកូននៅគ្រប់កំរិតទាំងអស់តាមរយៈការបណ្តុះបណ្តាលសកម្មភាពគ្រប់បែបយ៉ាង ។ | ៤.៤.២) រៀបចំផែនការថវិកាបណ្តុះបណ្តាលសមត្ថភាពរយៈពេលវែងស្តីពីការតាមដាននិងវាយតម្លៃ និងរៀបចំគំរោងបណ្តុះបណ្តាលដោយប្រើបច្ចេកទេសដែលទទួលបានផលខ្ពស់សំរាប់ដាក់ចេញនូវការអនុវត្តន៍ តាមរយៈវិធានការបណ្តុះបណ្តាលចំរុះ (រៀនបណ្តើរធ្វើការបណ្តើរ និងវគ្គសុក្រិតការ ឬសិក្ខាសាលា) |
| | | ៤.៤.៣) ណែនាំបង្ហាញខ្លួនបុគ្គលិកឈានមុខដែលមានគំនិតផ្តួចផ្តើមមកពីមណ្ឌលនានាដើម្បីប្រមូលទិន្នន័យចែកចាយព័ត៌មាន និងវិភាគទិន្នន័យរួមគ្នាឱ្យបានទៀងទាត់ និងចាត់វិធានការការពារជាបន្ទាន់ (ឧ:គុណភាពនៃការផ្តល់សេវា) |
| | ៤.៥) លើកទឹកចិត្តនិងគាំទ្រយ៉ាងសកម្មដល់គម្រោងផ្តួចផ្តើមថ្មីៗលើការអនុវត្តន៍យុទ្ធសាស្ត្រសកលលោកទាំង៤នៃកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនដែលក្នុងនោះមានស្តីពីការផ្តល់អាហារូបត្ថម្ភ និងរបៀបចិញ្ចឹមទារក និងកុមារតូចៗផងដែរ ។ | ៤.៥.១) ធ្វើការវាយតម្លៃពាក់កណ្តាលកម្មវិធី និងនៅពេលបញ្ចប់កម្មវិធីសាកល្បង ដើម្បីវាយតម្លៃពីភាពជោគជ័យនៃការអនុវត្តន៍និងប្រសិទ្ធភាពនៃកម្មវិធី និងវាស់ពីផលប៉ះពាល់ និងនិរន្តភាពនៃកម្មវិធី |
| | | ៤.៥.២) ព្យាយាមពង្រឹងសុពលភាពនៃតេស្តនៃសេចក្តីសន្និដ្ឋានដែលមានស្រាប់ និងបង្កើតសម្មតិកម្មថ្មីៗទុកជាមូលដ្ឋានសំរាប់គំរោងការណ៍កម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន និងលើកទឹកចិត្តឱ្យមានការ ស្រាវជ្រាវអនុវត្តដើម្បីទុកជាបទពិសោធន៍ និងដើម្បីធ្វើឱ្យកម្មវិធីកាន់តែមានភាពប្រសើរឡើង ។ |

## ៥ ការផ្សារភ្ជាប់ទំនាក់ទំនងលើគ្រប់វិស័យ

ដើម្បីឱ្យកិច្ចប្រឹងប្រែងក្នុងការកាត់បន្ថយការចម្លងមេរោគអេដស៍ពីម្តាយទៅកូនពីគ្រប់ស្ថាប័ននៃរាជរដ្ឋាភិបាលមានការសហការ កាន់តែល្អប្រសើរ មជ្ឈមណ្ឌលជាតិគាំពារមាតានិងទារកសុំឱ្យមានការដាក់បញ្ចូលតំណាងពីក្រសួងកិច្ចការនារី និងក្រសួងមហាផ្ទៃ ទៅក្នុងក្រុមការងារបច្ចេកទេស ដើម្បីជាកំលាំងគោលរួមគ្នាលើកកំពស់សកម្មភាពបង្ការមេរោគអេដស៍ចំពោះស្ត្រីស្ថិតក្នុងវ័យបន្តពូជ និងដៃគូរបស់គាត់។

## ៦ ការតាមដាន និងវាយតម្លៃ

ការបង្កើតចំណុចគោលដៅជាតិដូចដែលបានរៀបរាប់នៅក្នុងផែនការយុទ្ធសាស្ត្រជាតិត្រូវបានរំពឹងថានឹងពញ្ញោចសកម្មភាពតាមដាននិងវាយតម្លៃតាំងពីថ្នាក់ជាតិថ្នាក់ស្រុកប្រតិបត្តិ រហូតដល់ថ្នាក់មណ្ឌលសុខភាព។ រហូតមកដល់បច្ចុប្បន្ននេះ សុច្ចនករសំខាន់ៗ ត្រូវបានយកមកប្រើសំរាប់ផ្ទៀងផ្ទាត់ត្រឹមតែការអនុវត្តន៍ក្នុងឆ្នាំមុនៗប៉ុណ្ណោះហើយមិនបានយកមកផ្ទៀងផ្ទាត់ជាមួយនឹងចំណុចគោលដៅនៃឆ្នាំបច្ចុប្បន្នទេដោយសារតែកម្មវិធីមិនបានបង្កើតចំណុចគោលដៅជាក់លាក់តាមពេលវេលា។ ការរៀបចំបង្កើតឱ្យមានចំណុចគោលដៅសំរាប់កម្មវិធីគឺជាមគ្គុទេសក៍មួយដែលកម្មវិធីនិងដៃគូអភិវឌ្ឍន៍ទាំងអស់អាចធ្វើការវាយតម្លៃពីជោគជ័យ និងធ្វើផែនការបំលាស់ប្តូរធនធានបាន។

មកដល់បច្ចុប្បន្ននេះ កម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនអាចកំណត់ភាពជោគជ័យរបស់ខ្លួនបានតាមរយៈការប្រើប្រាស់ភាគបែងនៃសុច្ចនករ ដែលផ្អែកទៅតាមចំនួនអតិថិជនដែលមកទទួលសេវានៅតាមមណ្ឌលបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន។ ខណៈដែលសុច្ចនករទាំងនេះអាចជួយវាយតម្លៃពីគុណភាពនៃការផ្តល់សេវានៅក្នុងរង្វង់មណ្ឌលបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនការវាយតម្លៃពីផលប៉ះពាល់នៃមណ្ឌលមួយនៅក្នុងសហគមន៍តំរូវឱ្យយកភាគបែងនៃសុច្ចនករដែលផ្អែកទៅតាមចំនួនប៉ាន់ស្មានប្រជាជនជាមូលដ្ឋាន។ ឆ្លើយតបទៅនឹងកង្វះខាតក្នុងការវាយតម្លៃពីអត្រាគ្របដណ្តប់ និងពីផលប៉ះពាល់នៃកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅទូទាំងប្រទេស ក្រុមការងារបច្ចេកទេសផ្អែកតាមដាននិងវាយតម្លៃ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍បានបន្ថែមសុច្ចនករសំខាន់ៗមួយចំនួនសំរាប់វាយតម្លៃពីភាពរីកចំរើននៃកម្មវិធីដើម្បីឈានឆ្ពោះទៅសំរេចបាននូវការទទួលស្គាល់ជាសកលនៃអ្នកផ្ទុកមេរោគអេដស៍។

សំណុំសុច្ចនករទាំងនោះមានដូចតទៅ:

- ចំនួន (%) សេវាថែទាំផ្ទៃពោះដែលធ្វើតេស្តឈាមរកមេរោគអេដស៍
- ចំនួន (%) ស្រុកប្រតិបត្តិដែលមានសេវាបង្ការការចម្លងមេរោគអេដស៍យ៉ាងតិចមួយកន្លែង
- ចំនួន(%) ស្ត្រីមានផ្ទៃពោះដែលមកទទួលសេវាថែទាំផ្ទៃពោះនៅមណ្ឌលដែលមានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន បានធ្វើតេស្តឈាមរកមេរោគអេដស៍និងទទួលលទ្ធផលតេស្ត
- ចំនួន (%) ស្ត្រីមានផ្ទៃពោះនៅទូទាំងប្រទេសបានធ្វើតេស្តឈាមរកមេរោគអេដស៍ (មណ្ឌលបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន និងគ្លីនិកវ៉ាក់) និងទទួលលទ្ធផលតេស្ត
- ចំនួន (%) ដៃគូស្ត្រីបានធ្វើតេស្តឈាមរកមេរោគអេដស៍និងទទួលលទ្ធផលតេស្ត

- ចំនួន (%) ស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ដែលបានទទួលឱសថប្រឆាំងមេរោគអេដស៍ ដើម្បីបង្ការការចម្លងមេរោគ អេដស៍ពីម្តាយទៅកូន (បង្ការឬព្យាបាល)
- ចំនួន (%) កុមារដែលកើតពីម្តាយផ្ទុកមេរោគអេដស៍ចាប់ផ្តើមបង្ការដោយប្រើឱសថកូទ្រីម៉ុក សាសុលក្នុងកំឡុងពីរខែ ដំបូងនៃកំណើត
- ចំនួន (%) កុមារដែលកើតពីម្តាយផ្ទុកមេរោគអេដស៍បានធ្វើតេស្តឈាម (ភីស៊ីអ) រកមេរោគអេដស៍ក្នុងកំឡុងពេល ១២ខែនៃកំណើត
- ចំនួន (%) កុមារដែលកើតពីម្តាយផ្ទុកមេរោគអេដស៍បានចិញ្ចឹមដោយទឹកដោះម្តាយសុទ្ធឬដោយទឹកដោះគោម្សៅសុទ្ធ រយៈពេល៦ខែដំបូង
- (%) កុមារឆ្លងមេរោគអេដស៍ពីម្តាយ

សុច្ចនករខាងលើមិនបានបញ្ចូលសុច្ចនករសំរាប់តាមដានសមាមាត្រស្ត្រីផ្ទុកមេរោគអេដស៍ដែលរកឃើញនៅពេលមកទទួលសេវាថែទាំផ្ទៃពោះ ហើយដែលមិនបានមកសំរាលកូននៅឯមន្ទីរពេទ្យដែលមានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនទេ។ សុច្ចនករទាំងនេះក៏មិនបានតាមដានពីសមាមាត្រស្ត្រីដែលមកសំរាលមិនបានទទួលបញ្ចប់សកម្មភាពព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍នៅពេលឈឺពោះសំរាលនិងក្រោយសំរាលដែរ (ស្ត្រីមិនបានទទួលឱសថណេវីរ៉ាពីននៅពេលដែលគាត់មកដល់មន្ទីរ សំរាលតិចជាង២ម៉ោងនៃការសំរាលកូន)។

នៅទីបញ្ចប់ ឧបករណ៍សំរាប់ប្រមូលទិន្នន័យត្រូវតែធ្វើឱ្យបានច្បាស់លាស់ រវាងស្ត្រីមានផ្ទៃពោះដែលត្រូវបញ្ជូនមកធ្វើតេស្តឈាម និងស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ដែលត្រូវបញ្ជូនទៅទទួលសេវាថែទាំនិងព្យាបាល ពីព្រោះតែបច្ចុប្បន្នទំនាក់ទំនងរវាងសេវា បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនត្រូវបានពង្រឹងជាមួយនឹង សមាសភាគដទៃទៀតក្នុងគំរោងថែទាំបន្ត និងជាមួយនឹងភ្នាក់ងារនៅតាមសហគមន៍ ស្របពេលជាមួយនឹងឱកាសធ្វើតេស្តឈាមត្រូវបានអនុវត្តតាមបែបវិមជ្ឈការ។ ដើម្បីកាត់បន្ថយការរាប់ជាន់គ្នានៃចំនួនស្ត្រីដោយសារ តែពួកគេត្រូវបញ្ជូនមកពីកន្លែងផ្សេង ហើយត្រូវបានរកឃើញតាមរយៈដំណើរការនៃការផ្តល់សេវាថែទាំផ្ទៃពោះ យន្តកម្មមួយត្រូវរៀបចំឡើងដើម្បីកាត់បន្ថយបញ្ហារាប់ជាន់គ្នានេះ ដូចជាគូសប្រអប់មួយក្នុងលិខិតបញ្ជូន ដែលបញ្ជាក់ថាមេរោគអេដស៍ត្រូវបានរកឃើញនៅពេលស្ត្រីកំពុងមានផ្ទៃពោះ ឬក៏ត្រូវបានរកឃើញមុនពេលមានផ្ទៃពោះទៅទៀត។

របាយការណ៍ពិនិត្យឡើងវិញរួមគ្នា លើកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនឆ្នាំ ២០០៧ បានរៀបរាប់ពីជំហានសកម្មភាពសំខាន់៧ដែលទាក់ទងទៅនឹងការតាមដាន នឹងវាយតម្លៃលើផែនការយុទ្ធសាស្ត្រសំរាប់បង្ការចម្លងមេរោគអេដស៍ពីម្តាយទៅកូននេះ នៅក្នុងឧបសម្ព័ន្ធទី២។ សេចក្តីលំអិតបែបនេះ មិនមាននៅក្នុងតារាងម៉ាទ្រីស Thematic Area ដូចខាងលើទេ ក៏ប៉ុន្តែវាគួរតែត្រូវបានចាត់ទុកជាផ្នែកមួយនៃយុទ្ធសាស្ត្រ បូកសរុបនៃ ការតាមដាន និងវាយតម្លៃព្រមទាំងផែនការការងារ និងរបាយការណ៍តាមដានផ្សេងៗរបស់លេខាធិការដ្ឋាននៃកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន។

## ៧ ចំណុចគោលដៅសុចូនករសំខាន់ៗសំរាប់កម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនឆ្នាំ ២០០៨_២០១៥

តាមរយៈអនុសាសន៍នៅក្នុងផែនការយុទ្ធសាស្ត្រនេះ កម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនរំពឹងថានឹងអាចសំរេចគោលដៅសម្រាប់ ឆ្នាំ២០០៨-២០១៥ បាន។ ផែនការរំកិល៣ឆ្នាំត្រូវបានបង្កើតសំរាប់ឆ្នាំនីមួយៗ ដោយផ្អែកតាមលទ្ធផលដែលសំរេចបានក្នុងឆ្នាំ ២០០៧។

សុចូនករនៃផែនការយុទ្ធសាស្ត្រជាតិ សំរាប់កម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនឆ្នាំ២០០៨-២០១៥:

| សុចូនករ | ចំណុចមូលដ្ឋាន | កាលបរិច្ឆេទ | ចំណុចគោលដៅ | | | |
|---|---|---|---|---|---|---|
| | | | ២០០៨ | ២០០៩ | ២០១០ | ២០១៥ |
| ១) ចំនួន (%) សេវាថែទាំផ្ទៃពោះ ដែលធ្វើតេស្តឈាមរកមេរោគអេដស៍ | ៩៥/៩៥៦ ១០% | ដំណាច់ឆ្នាំ ២០០៧ | ១៩៣ ២០% | ២៨៩ ៣០% | ៣៨៦ ៤០% | ៥០០ ៥១% |
| ២) ចំនួន (%) ស្រុកប្រតិបត្តិដែលមានសេវាបង្ការការចម្លងមេរោគអេដស៍យ៉ាងតិចមួយកន្លែង | ៥៨/៧៧ (៧៥%) | ដំណាច់ឆ្នាំ ២០០៧ | ៨៥% | ៩០% | ១០០% | ១០០% |
| ៣) ចំនួន (%) ស្ត្រីមានផ្ទៃពោះដែលមកទទួលសេវាថែទាំផ្ទៃពោះនៅមណ្ឌលដែលមានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនបានមកធ្វើតេស្តឈាមរកមេរោគអេដស៍ និងទទួលលទ្ធផលតេស្ត | ៦៦,១៨៦/ ៩១,០២១ ៧២.៧% | ដំណាច់ឆ្នាំ ២០០៧ | ៧៥% | ៨០% | ៨៥% | ៩៥% |
| ៤) ចំនួន (%) ស្ត្រីមានផ្ទៃពោះនៅទូទាំងប្រទេសបានធ្វើតេស្តឈាមរកមេរោគអេដស៍ (មណ្ឌលបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន និងគ្លីនិករ៉ាក់) និងទទួលលទ្ធផលតេស្ត | ៦៦,១៨៦/ ៤១០,០០០ ១៤.៩% | ដំណាច់ឆ្នាំ ២០០៧ | ២៥% | ៣៥% | ៥០% | ៧៥% |
| ៥) ចំនួន (%) ដៃគូស្ត្រីបានធ្វើតេស្តឈាមរកមេរោគអេដស៍និងទទួលលទ្ធផលតេស្ត | ១០,៦៧០/ ៥០,៦០៤ ២១.១% | ដំណាច់ឆ្នាំ ២០០៧ | ២៥% | ៣០% | ៣៥% | ៤០% |
| ៦) ចំនួន (%) ស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ដែលបានទទួលឱសថប្រឆាំងមេរោគអេដស៍ដើម្បីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន (បង្ការឬព្យាបាល) | ៥០៥/ ៤៥០៩ ១១.២% | ដំណាច់ឆ្នាំ ២០០៧ | ៣០% | ៤០% | ៥០% | ៧៥% |
| ៧) ចំនួន (%) កុមារដែលកើតពីម្តាយផ្ទុកមេរោគអេដស៍ចាប់ផ្តើមបង្ការដោយប្រើ ឱសថកូទ្រីម៉ុកសាសុលក្នុងកំឡុងពីខែដំបូងនៃកំណើត | គ្មាន | | ២៥% | ៣៥% | ៤៥% | ៧០% |

| | | | | | | |
|---|---|---|---|---|---|---|
| ៨) ចំនួន (%) កុមារដែលកើតពីម្តាយផ្ទុកមេរោគអេដស៍បានធ្វើតេស្តឈាម (ភីស៊ីអ) រកមេរោគអេដស៍ក្នុងកំឡុងពេល ១២ខែនៃកំណើត | គ្មាន | | ២៥% | ៣៥% | ៤៥% | ៧០% |
| ៩) ចំនួន (%) កុមារដែលកើតពីម្តាយផ្ទុកមេរោគអេដស៍បានចិញ្ចឹមដោយទឹកដោះម្តាយសុទ្ធឬដោយទឹកដោះគោម្សៅសុទ្ធរយៈពេល៦ខែដំបូង | គ្មាន | | ១០០% | ១០០% | ១០០% | ១០០% |
| ១០) (%) កុមារឆ្លងមេរោគអេដស៍ពីម្តាយ | ៣១.១% | ២០០៧ | ២៧.៥% | ២៥% | ២២.៥% | ១៦.៣% |

# ៨ ឧបសម្ព័ន្ធ

## ៨.១ ឧបសម្ព័ន្ធទី១: របៀបគិតចំណុចគោលដៅផ្អែកតាមចំនួនប្រជាជន សំរាប់ថ្នាក់ខេត្ត/ថ្នាក់ស្រុក

ចំណុចគោលដៅផ្អែកតាមចំនួនប្រជាជន សំរាប់ថ្នាក់ខេត្ត/ថ្នាក់ស្រុកអាចគណនាដូចតទៅនេះ

តំបន់: ខេត្ត/ស្រុក:.......................................................................................................

**P** = ចំនួនប្រជាជនសរុប

**CBR** = អត្រាកំណើតប្រចាំឆ្នាំ (ចំនួនកំណើតក្នុងប្រជាជន ១.០០០នាក់) នៅទូទាំងប្រទេសអត្រានេះស្មើនឹង ២៨.៥៤/១.០០០នាក់។ ប៉ុន្តែអត្រានេះមានការប្រែប្រួលតាមខេត្តនីមួយៗ ហើយដែលអាចរកបាននៅនាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាល ។

**អត្រាស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍** (សមាមាត្រនៃស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ក្នុងរបាយការណ៍ជាតិស្តីពីការអង្កេតរកអត្រាឆ្លង នៃមេរោគអេដស៍ ឆ្នាំ២០០៦) = 0.០១១ (ចំនួននេះគួរប្រើរហូតដល់មានរបាយការណ៍អង្កេតថ្មី)

**TR** = អត្រាចម្លងមេរោគអេដស៍ពីម្តាយទៅកូនដោយគ្មានអន្តរាគមន៍ ៣៥% (អត្រាប៉ាន់ស្មាន)

**TRP** = អត្រាចម្លងមេរោគអេដស៍ពីម្តាយទៅកូនដោយមានអន្តរាគមន៍ = ១០% (អត្រានេះនឹងប្រែប្រួល ទៅតាមការប្រើប្រាស់ឱសថប្រឆាំងមេរោគអេដស៍តិចជាងឬច្រើនជាង ៤អាទិត្យមុនពេលសំរាលមិនថាស្ត្រីទទួលបានថ្នាំគ្រប់ដូសនៅពេលសំរាល មិនថាទារកទទួលបានឱសថប្រឆាំងមេរោគអេដស៍ពេញលេញក្រោយពេលសំរាល និងមិនថានោះគឺជាកូនដែលចិញ្ចឹមដោយទឹកដោះម្តាយនោះទេ។ ក៏ប៉ុន្តែដើម្បីឱ្យងាយស្រួល យើងត្រូវគិតថាអត្រាចម្លងអាចមាន ១០% ទោះជាម្តាយ/កូនទទួលបានឱសថប្រឆាំងមេរោគអេដស៍រួមគ្នា ទាំងពីរនាក់ពីសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនបានពេញលេញក្តី ឬមិនពេញលេញក្តី ។)

**A** = ចំនួនកំណើត = P x CBR

**B** = ចំនួនកូនកើតពីម្តាយផ្ទុកមេរោគអេដស៍ = A x 0.011

**C=** ចំនួនកូនកើតពីម្តាយផ្ទុកមេរោគអេដស៍ដែលគេរំពឹងថានឹងឆ្លងមេរោគអេដស៍ បើសិនជាម្តាយមិនបានប្រើឱសថ ប្រឆាំងមេរោគ អេដស៍ = B x TR = B x 0.35

**D=** ចំនួនម្តាយផ្ទុកមេរោគអេដស៍ និងកូននៅក្នុងខេត្ត (ឬស្រុកប្រតិបត្តិ) ដែលបានទទួលឱសថប្រឆាំងមេរោគអេដស៍នៅពេលមានផ្ទៃពោះនិងនៅពេលសំរាលឬបានទទួលតែនៅពេលសំរាល រួមទាំងកូនក្រោយពេលសំរាល

**E=** ចំនួនកុមារដែលអាចជៀសផុតពីការឆ្លងមេរោគអេដស៍ = D x (1-TRP) = D x 0.9

**F=** អត្រាកុមារដែលអាចជៀសផុតពីការឆ្លងមេរោគអេដស៍ = E/C x 100

**ចំណុចគោលដៅរបស់យូអិនហ្គាស ឆ្នាំ២០១០ :** ៥០% នៃកុមារដែលរួចផុតពីការឆ្លងមេរោគអេដស៍ ចំណុចខ្វះខាតដែលការអនុវត្តន៍មិនបានឆ្លើយតបទៅនឹងចំណុចគោលដៅរបស់យូអិនហ្គាស២០១០: ៥០- F% ចំនួនកុមារឆ្លងដែលត្រូវបញ្ចៀសពីការឆ្លងមេរោគអេដស៍បន្ថែម ដើម្បីឆ្លើយតបទៅនឹងយូអិនហ្គាស ឆ្នាំ ២០១០:= (0.5 x C) - F

***ការណែនាំ:*** *ចូរចងចាំថាកូនដែលកើតពីម្តាយដែលបានទទួលឱសថប្រឆាំងមេរោគអេដស៍ ប្រមាណ៩០%អាចរួចផុតពីការឆ្លងមេរោគអេដស៍ពីម្តាយ។ តែបើសិនជា ម្តាយមិនបានទទួលឱសថប្រឆាំងមេរោគអេដស៍ទេ កូនដែលកើតមកប្រមាណជា ៦៥%អាចរួចផុតពីការឆ្លងមេរោគអេដស៍។ វាមានការខុសគ្នា ២៥%។ កុមារចំនួន៣០នាក់ក្នុងចំណោមកុមារ ១០០នាក់ដែលកើតពីម្តាយផ្ទុកមេរោគអេដស៍ដែលមិនបានទទួលអន្តរាគមន៍បង្ការ នឹងឆ្លងមេរោគអេដស៍ពីម្តាយ។ កុមារប្រមាណ១០នាក់ ក្នុងចំណោមកុមារ ១០០នាក់ ដែលកើតពីម្តាយផ្ទុកមេរោគអេដស៍ដែលបានទទួលអន្តរាគមន៍បង្ការ អាចឆ្លងមេរោគអេដស៍ពីម្តាយទៅកូន។ ដូច្នេះ កូនចំនួន ២៥នាក់ (ដែលបំរុងនឹងឆ្លងមេរោគអេដស៍ ) នៃម្តាយ១០០នាក់ដែលបានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍នឹងត្រូវបានរួចផុតពីការឆ្លងមេរោគអេដស៍ពីម្តាយ ឬក៏អាចនិយាយបានម្យ៉ាងទៀតថា រាល់ម្តាយ/កូន៤នាក់ ដែលបានទទួលការព្យាបាលបង្ការ នឹងមានកូន១នាក់ត្រូវបានរួចផុតពីការឆ្លងមេរោគអេដស៍។ ដើម្បីបញ្ចៀសការឆ្លងមេរោគអេដស៍នៅលើកូនម្នាក់យើងត្រូវព្យាបាលម្តាយ/កូនឱ្យបាន៤នាក់ (ទាំងម្តាយទាំងកូន)។ ដើម្បីរកឃើញស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ចំនួន ៤នាក់ យើងចាំបាច់ត្រូវផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមដល់ស្ត្រីមានផ្ទៃពោះចំនួន ៣៦៤នាក់ (៤នាក់/0.0១១)។ ដូច្នេះ យើងអាចធ្វើការសន្និដ្ឋានថា ស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ទាំងអស់ដែលគេរកឃើញបានទទួលការព្យាបាលហើយ និងស្ត្រីមានផ្ទៃពោះចំនួន ៣៦៤នាក់ បន្ថែមទៀតដែលត្រូវតែមកធ្វើតេស្តឈាមដើម្បីឱ្យកុមារដែលរំពឹងថាឆ្លងមេរោគអេដស៍ពីម្តាយបានជៀសផុតអំពីការឆ្លងមេរោគអេដស៍នេះ និងដើម្បីឆ្លើយតបទៅនឹងចំណុចគោលដៅរបស់យូអិនហ្គាសផងដែរ។*

*ជាការប្រាកដណាស់ថា យុទ្ធសាស្ត្របន្ថែមជាច្រើនទៀតត្រូវយកមកប្រើប្រាស់ដើម្បីបញ្ចៀសនូវការចម្លងមេរោគអេដស៍ពីម្តាយទៅកូននេះ ដូចជាការបញ្ជាក់ឱ្យប្រាកដថាស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ទាំងអស់រួមមានស្ត្រីដែលដឹងថាមានផ្ទុកមេរោគអេដស៍មុនពេលមានផ្ទៃពោះ និងស្ត្រីដែលដឹងថាមានផ្ទុកមេរោគអេដស៍នៅពេលមកទទួលសេវាថែទាំផ្ទៃពោះ បានទទួលឱសថប្រឆាំងមេរោគអេដស៍គ្រប់ៗគ្នា។*

*ដើម្បីឱ្យចំណុចគោលដៅត្រូវគ្នាសំរាប់ឆ្នាំបន្តបន្ទាប់ ត្រូវបន្ថែម ២% នៃចំនួនប្រជាជនពីលើឆ្នាំមុនៗកន្លងទៅ (=អត្រាកំណើនប្រជាជន) និងធ្វើការគណនាទៅតាមចំនួនដែលបានបន្ថែមនេះ ។ យើងត្រូវយកចិត្តទុកដាក់ផងដែរ ចំពោះការប្រែប្រួលនៃអត្រាកំណើត ឬការប្រែប្រួលនៃអត្រាឆ្លងមេរោគអេដស៍នៅលើស្ត្រីមានផ្ទៃពោះ ។*

## ៨.២ ឧបសម្ព័ន្ធទី២: វិធានការអនុវត្តន៍សំរាប់ការតាមដាន និងវាយតម្លៃ តាមរយៈអនុសាសន៍នៃការពិនិត្យឡើងវិញរួមគ្នា លើកម្មវិធីបង្ការការចម្លង មេរោគអេដស៍ពីម្តាយទៅកូនឆ្នាំ២០០៧

### ៨.២.១ កសាងសមត្ថភាពនិងធ្វើការណែនាំដល់មន្ត្រី-បុគ្គលិកនៅគ្រប់កម្រិតទាំងអស់ឱ្យប្រើប្រាស់ទិន្នន័យប្រកបដោយប្រសិទ្ធភាពសំរាប់ធ្វើផែនការកម្មវិធី កែលំអកម្មវិធី និងតាមដានអ្នកជម្ងឺ

**<u>សកម្មភាពជាគន្លឹះ</u> :**

***ថ្នាក់ជាតិ***

- បង្កើតអនុគណៈកម្មការត្រួតពិនិត្យតាមដាន និងវាយតម្លៃ ចេញដោយឡែកចេញពីក្រុមការងារបច្ចេកទេសបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ដែលមានអ្នកតំណាងមកពីកម្មវិធីជាតិ បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន កម្មវិធីជាតិសុខភាពបន្តពូជ អាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និងកាមរោគ នាយកដ្ឋានព័ត៌មាននិងផែនការក្រសួងសុខាភិបាល ក្រុមការងារបច្ចេកទេស បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ។ល ។
- បង្កើតគោលដៅចំណុចជាតិ សំរាប់ការពង្រីកសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ។
- បង្កើត និងផ្សព្វផ្សាយសេចក្តីណែនាំស្តីពីការប្រើប្រាស់ទិន្នន័យសំរាប់កែលំអ និងអនុវត្តកម្មវិធីដល់ថ្នាក់ខេត្ត និងស្រុកប្រតិបត្តិដែលក្នុងនោះមានសុច្ឆនករដែលស្តីពីការលើកកម្ពស់គុណភាព និងការអនុវត្តន៍ ។
- ក្រុមការងារបច្ចេកទេសបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន គួរពិនិត្យវិភាគលើទិន្នន័យនៃកម្មវិធីជាតិ ជារៀងរាល់ត្រីមាសព្រមទាំងផ្តល់អនុសាសន៍ និងគាំទ្រដល់ការកែលំអកម្មវិធី ។
- ដើម្បីគាំទ្រសេចក្តីថ្លែងការណ៍រួមស្តីពីសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន លេខាធិការដ្ឋាននៃកម្មវិធី បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន និងផ្នែកគ្រប់គ្រងទិន្នន័យរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និងកាមរោគគួរផ្តល់ព័ត៌មានស្តីពីសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនដល់គ្នាទៅវិញទៅមក ។
- លេខាធិការដ្ឋាននៃកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន គួររៀបចំរបាយការណ៍ប្រចាំឆ្នាំមួយ ស្តីពីដំណើរវិវត្តន៍ទៅមុខនៃកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន និងរៀបចំកិច្ចប្រជុំប្រចាំឆ្នាំជាមួយភាគី ពាក់ព័ន្ធនានា ដើម្បីផ្សព្វផ្សាយព័ត៌មាន និងស្វែងរកការគាំទ្រសំរាប់កែលំអកម្មវិធី ។ របាយការណ៍ទាំងនេះគួរត្រូវបានប្រើប្រាស់ដើម្បីដាក់បញ្ចូលទៅក្នុងការពិនិត្យឡើងវិញជាមួយភាគីពាក់ព័ន្ធនានា និងដាក់ទៅក្នុងការរៀបចំផែនការប្រតិបត្តិ ។

- អនុគណៈកម្មការត្រួតពិនិត្យនិងវាយតម្លៃគួរសហការជាមួយនាយកដ្ឋានព័ត៌មាន និងផែនការសុខាភិបាល ដើម្បីកំណត់ពីសូចនាករសម្រាប់កម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ដែលគួរតែដាក់បញ្ចូលទៅក្នុងប្រព័ន្ធព័ត៌មានសុខាភិបាលជាតិ ។
- ផ្នែកត្រួតពិនិត្យតាមដាន និងវាយតម្លៃរបស់លេខាធិការដ្ឋានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនគួរផ្តល់ព័ត៌មានត្រឡប់យ៉ាងហោចណាស់ម្តង ស្តីពីដំណើរវិវឌ្ឍន៍ទៅមុខនៃកម្មវិធីខេត្តលើសូចនាករសំខាន់ៗ ដែលបានវាស់វែងធៀបទៅនឹងសូចនាករជាតិ ក្នុងមួយត្រីមាសដល់អ្នកសម្របសម្រួលសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនថ្នាក់ខេត្ត ។

***ថ្នាក់ខេត្ត***

- ក្រុមការងារសុខាភិបាលខេត្តគួរបង្កើតចំណុចគោលដៅសំរាប់ពង្រីកកម្មវិធីដោយគិតតាមចំនួនប្រជាជនសរុបយោងទៅតាមគោលដៅចំណុចជាតិ និងរៀបចំផែនការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនដោយផ្អែកលើគោលការណ៍ណែនាំជាតិស្តីពីទិន្នន័យសំខាន់ៗ (ឧ. ការសម្រាលកូនប្រចាំឆ្នាំ ប្រេវ៉ាឡង់មេរោគអេដស៍ស្ថិតិសេវាសុខភាពមាតា និងទារក ។ល ។)
- គ្រប់សេវាផ្នែកសុខភាពមាតា និងទារកនិងផ្នែកគ្រប់គ្រងទិន្នន័យខេត្ត គួរតែចែករំលែកព័ត៌មានឱ្យគ្នាទៅវិញទៅមក ដើម្បីជាជំនួយក្នុងការរៀបចំធ្វើផែនការកម្មវិធីថ្នាក់ខេត្ត (កន្លែងពិនិត្យផ្ទៃពោះ មន្ទីរសម្ភពសេវាព្យាបាលជំងឺឱកាសនិយមនិងផ្តល់ឱសថប្រឆាំងមេរោគអេដស៍សំរាប់មនុស្សចាស់ និងកុមារ) ។

***ថ្នាក់ស្រុកប្រតិបត្តិ***

- ស្រុកប្រតិបត្តិ និងគ្រឹះស្ថានសុខាភិបាលទាំងឡាយ គួរបង្កើតគោលដៅចំណុចសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនដោយផ្អែកលើផែនការសកម្មភាពខេត្ត ។
- ស្រុកប្រតិបត្តិគួរបង្កើតឧបករណ៍សំរាប់តាមដានអ្នកជម្ងឺទៅទូទាំងកន្លែងផ្តល់សេវាទាំងអស់ ទាំងសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន សេវាOI/ART សេវាសម្ភព និងសេវាតាមដានជម្ងឺកុមារជាដើម ។
- ស្រុកប្រតិបត្តិគួររៀបចំកិច្ចប្រជុំក្រុមឱ្យបានទៀងទាត់ ដើម្បីពិនិត្យឡើងវិញលើទិន្នន័យគោល នៃកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនដែលបានប្រមូលនៅតាមសេវាថែទាំផ្ទៃពោះ សេវាសម្ភព សេវាOI/ART និង សេវាកម្មនៅតាមសហគមន៍ ដើម្បីកំណត់ពីនិន្នាការភាពទាក់ទងទៅនឹងដំណើរការអនុវត្តន៍និងគុណភាពនៃសេវា ដើម្បីពិនិត្យមើលពីបញ្ហាលំបាកនិងដំណោះស្រាយ និងដើម្បីធានាឱ្យមានការតាមដានល្អចំពោះអ្នកជម្ងឺ ។

## ៨.២.២ ពិនិត្យឡើងវិញលើប្រព័ន្ធត្រួតពិនិត្យតាមដានកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនដែលប្រើក្នុងពេលបច្ចុប្បន្ន និងដោះស្រាយគម្លាតទិន្នន័យគោល

**<u>សកម្មភាពជាគន្លឹះ :</u>**

- ពិនិត្យឡើងវិញលើសូចនាករ និងឧបករណ៍តាមដានកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនរបស់អន្តរជាតិ ដែលបានបង្កើតឡើងថ្មីៗ ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើការរៀបចំផែនការគ្រួសារ និងការចិញ្ចឹមទារក ដែលបច្ចុប្បន្ននេះមិនទាន់ត្រូវបានគេដាក់បញ្ចូលនៅក្នុងការប្រមូលទិន្នន័យនៃ

បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនថ្នាក់ជាតិទេ។ ត្រូវធ្វើការពិចារណាទៅលើរបៀបចិញ្ចឹមទារក និងត្រូវរាយការណ៍ជាប្រចាំពីស្ថានភាពអាហារូបត្ថម្ភនៃទារកប្រឈមទាំងឡាយ ។

- ពិនិត្យឡើងវិញលើនីតិវិធីបច្ចុប្បន្ននៃការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាម និងនីតិវិធីនៃធ្វើកំណត់ត្រានៅសេវាពិនិត្យផ្ទៃពោះ ដើម្បីធានាថារាល់ស្ត្រីដែលបានរកឃើញថាមានផ្ទុកមេរោគអេដស៍ទាំងអស់ត្រូវបានរាយការណ៍ និងតាមដាន។ បានន័យថា មិនមែនត្រឹមតែស្ត្រីដែលបានទទួលការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តប៉ុណ្ណោះទេ ។
- អនុគណៈកម្មាធិការត្រួតពិនិត្យតាមដាននិងវាយតម្លៃលើកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនគួរតែកោះប្រជុំដើម្បី :
  - ពិនិត្យឡើងវិញលើទិន្នន័យបច្ចុប្បន្នដែលប្រមូលមកពីសេវាOI/ARTសំរាប់មនុស្សពេញវ័យនិងកុមារ និងដើម្បីទទួលព័ត៌មានអំពីស្ត្រីផ្ទុកមេរោគអេដស៍ និងអំពីកុមារប្រឈមឱ្យបានជាប្រចាំពី សេវាOI/ART ដូចជាៈ
    - ចំនួនស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ និងចំនួនស្ត្រីផ្ទុកមេរោគអេដស៍ក្រោយសម្រាលៈ
      - ដែលទើបនឹងចុះឈ្មោះថ្មីៗនៅក្នុងសេវាថែទាំជម្ងឺអេដស៍ (HIV care)
      - ដែលបានវាយតំលៃនូវល័ក្ខខ័ណ្ឌដែលអាចទទួល ART
      - ដែលគ្រប់ល័ក្ខខ័ណ្ឌទទួល ART
      - ដែលចាប់ផ្តើមប្រើឱសថបង្ការប្រឆាំងមេរោគអេដស៍ (ARV prophylaxis)
      - ដែលចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ (ART)
    - ចំនួនកុមារប្រឈមដែលបាន :
      - ចាប់ផ្តើមទទួលឱសថកូទ្រីម៉ុកសាសុល CTX
      - ធ្វើតេស្តរកមេរោគអេដស៍
      - បញ្ជាក់ថាបានឆ្លងមេរោគអេដស៍ និងមិនបានឆ្លងបានមេរោគអេដស៍
  - ពិនិត្យឡើងវិញនិងកែសម្រួលសុច្ចនករ ព្រមទាំងឧបករណ៍អនុវត្តនីតិវិធីប្រតិបត្តិស្តង់ដាថែទាំតាមផ្ទះ “HBC SOP performance indicators” ដើម្បីដាក់បញ្ចូលទិន្នន័យនៃ សកម្មភាពដែលទាក់ទងនឹងសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ។
  - ពិនិត្យឡើងវិញ និងកែសំរួលឧបករណ៍ប្រមូលទិន្នន័យស្តង់ដា និងទំរង់របាយការណ៍ផ្សេងៗ ឱ្យបានចប់សព្វគ្រប់ ។
  - ផ្សព្វផ្សាយឱ្យប្រើប្រាស់នូវឧបករណ៍ប្រមូលទិន្នន័យនិងទំរង់របាយការណ៍ទាំងអស់ ។ បណ្តុះបណ្តាលមន្ត្រី-បុគ្គលិកសុខាភិបាលឱ្យចេះប្រើឯកសារទាំងនោះ និងផ្តល់ការគាំទ្រតាមដានដល់មន្ត្រី-បុគ្គលិកទាំងអស់ឱ្យបានជិតស្និទ្ធ ជាពិសេសនៅក្នុងដំណាក់កាលដំបូងនៃការអនុវត្តន៍ ។

- ផ្នែកគ្រប់គ្រងទិន្នន័យ និងអ្នកសម្របសម្រួលកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនថ្នាក់ខេត្តត្រូវប្រាកដថា រាល់ទិន្នន័យទាក់ទងទៅនឹងសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន នៅឯសេវា MCH/

PMTCT និង OI/ART ទាំងអស់ត្រូវបានផ្ញើជារៀងរាល់ខែឬត្រីមាសទៅកាន់លេខាធិការដ្ឋាន នៃកម្មវិធីសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ។

- គ្រប់ដៃគូអភិវឌ្ឍន៍ទាំងអស់ត្រូវផ្តល់ការគាំទ្រ និងផ្តល់ជំនួយបច្ចេកទេសដល់ផ្នែកតាមដាននិងវាយតម្លៃសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ដើម្បីធ្វើឱ្យប្រព័ន្ធមូលដ្ឋានទិន្នន័យ ជាតិសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនមានភាពជឿនលឿន ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើការគ្រប់គ្រងទិន្នន័យតាមប្រព័ន្ធអេឡិចត្រូនិក (software packages) និងដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរឧបករណ៍សំរាប់ប្រមូលទិន្នន័យនិងសំរាប់ធ្វើរបាយការណ៍ទាំងនោះ ។
- ក្រុមការងារបច្ចេកទេសនៃកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ត្រូវគាំទ្រដល់គំនិតផ្តួចផ្តើមនៃ គម្រោងសាកល្បងថ្មីៗ/គម្រោងស្រាវជ្រាវប្រតិបត្តិនានាសំរាប់ធ្វើជាគំរូអនុវត្តន៍ក្នុងប្រទេស ដើម្បីកែលំអសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនឱ្យកាន់តែមានភាពល្អប្រសើរឡើងដោយផ្អែកលើលទ្ធផលដែលប្រមូលបានមកធ្វើជាមូលដ្ឋាន ។

### ៨.២.៣ ដាក់បញ្ចូលព័ត៌មានទាក់ទងនឹងកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន និង អំពីមេរោគអេដស៍ទៅក្នុងសៀវភៅបទដ្ឋានកំណត់ត្រាសម្រាល សៀវភៅសុខភាពម្តាយ និងទៅក្នុងប័ណ្ណចាក់ថ្នាំបង្ការកុមារ និងធានាថា សៀវភៅកំណត់ត្រាពិនិត្យផ្ទៃពោះថ្មីនេះនឹងឆ្លុះបញ្ចាំងពីបច្ចុប្បន្នភាពនៃ ប្រព័ន្ធតាមដានកម្មវិធីជាតិ

<u>**សកម្មភាពសំខាន់ៗ :**</u>

- អនុគណៈកម្មាការតាមដាននិងវាយតម្លៃកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនគួររៀបចំសិក្ខាសាលាជាមួយ ភាគីពាក់ព័ន្ធដោយសហការជាមួយសេវាផ្នែកសុខភាពមាតានិងទារក ដើម្បី :
  - ពិនិត្យពិចារណាលើអនុសាសន៍អន្តរជាតិថ្មីៗស្តីអំពីមេរោគអេដស៍ និងការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន និងសំរួលព័ត៌មានទាំងឡាយ ដើម្បីដាក់បញ្ចូលទៅក្នុងសៀវភៅស្តង់ដាកំណត់ត្រាសុខភាពមាតានិង ទារកជាតិ សៀវភៅសុខភាពម្តាយ និងប័ណ្ណចាក់ថ្នាំបង្ការកុមារ ។ បន្ថែមពីលើនេះ អនុគណៈកម្មាការនេះគួរ ពិនិត្យនិងដកស្រង់បទពិសោធន៍ពីគំរូនានានៃសៀវភៅកំណត់ត្រា និងប័ណ្ណសុខភាពមាតា និងទារកនៃប្រទេសផ្សេងៗមួយចំនួនដែលមានដំណើរការប្រហាក់ប្រហែលគ្នានឹងប្រទេសកម្ពុជាដែរ (ឧ. បុតស្វាណា, ហ្ស៊ីមបាបវេ, លេហ្សូតូ ។ល។) ។
  - ពិនិត្យកែសំរួលឱ្យបានសំរេចនូវសៀវភៅកំណត់ត្រាសំរាប់ផ្នែកពិនិត្យផ្ទៃពោះ និងផ្នែកសម្រាល (ANC and Maternity registers) សៀវភៅសុខភាពម្តាយ និងប័ណ្ណចាក់ថ្នាំបង្ការកុមារ ដោយដាក់បញ្ចូលព័ត៌មានស្តីពីសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនទៅក្នុងទម្រង់បែបបទទាំងនោះក្នុងលក្ខណៈលាក់ការណ៍សំងាត់ ។
  - ផ្សព្វផ្សាយសៀវភៅកំណត់ត្រាសុខភាពម្តាយ និងប័ណ្ណចាក់ថ្នាំបង្ការកុមារ ។ បណ្តុះបណ្តាលបុគ្គលិកអំពីការប្រើប្រាស់សៀវភៅទាំងនេះ និងគាំទ្រតាមដានឱ្យបានជិតស្និទ្ធលើការប្រើប្រាស់សៀវភៅទាំងនោះ ជាពិសេសនៅក្នុងដំណាក់កាលដំបូងនៃការអនុវត្តន៍សកម្មភាព ។

## ៨.៣ ឧបសម្ព័ន្ធទី៣: ព័ត៌មានសំខាន់ៗដែលឆ្មបនៅសេវាថែទាំផ្ទៃពោះទាំងអស់ត្រូវដឹងដើម្បីពន្យល់ដល់ស្ត្រីមានផ្ទៃពោះអំពីសារៈសំខាន់នៃការធ្វើតេស្តឈាមនៅពេលមានផ្ទៃពោះ តាមវិធីសាស្ត្រនៃការផ្ដល់ប្រឹក្សានិងធ្វើតេស្តឈាមដែលផ្ដួចផ្ដើមដោយអ្នកផ្ដល់សេវាដូចតទៅ :

- នៅឆ្នាំ២០០៧ នៅប្រទេសកម្ពុជាគេបានប៉ាន់ប្រមាណថា ក្នុងចំណោមអ្នកឆ្លងមេរោគអេដស៍ថ្មីមានស្ត្រី និង កុមារប្រមាណ ៧១%[៥] ។ ដូច្នេះ យើងត្រូវផ្ដោតការយកចិត្តទុកដាក់លើប្រជាជនទាំងនេះ ដោយធ្វើយ៉ាងណារកឱ្យឃើញថា ស្ត្រីទាំងនោះមានផ្ទុកមេរោគអេដស៍ ដើម្បីបង្ការការឆ្លងមេរោគអេដស៍ទៅកូនរបស់គាត់ ។
- មេរោគអេដស៍មិនបង្កឱ្យមានរោគសញ្ញាជាច្រើនឆ្នាំក្រោយពីការឆ្លង ។ ដូច្នេះមនុស្សម្នាក់អាចឆ្លងមេរោគអេដស៍ពីយូរណាស់មកហើយតែមិនបានដឹងខ្លួនទេ ។ ហេតុដូច្នេះហើយបានជាយើងត្រូវលើកទឹកចិត្តឱ្យប្ដីប្រពន្ធមកធ្វើតេស្តឈាមទាំងពីរនាក់ ។
- មានតែការធ្វើតេស្តឈាមប៉ុណ្ណោះ ទើបអាចដឹងថាមនុស្សម្នាក់មានផ្ទុកមេរោគអេដស៍ ។
- ស្ត្រីដែលមានផ្ទុកមេរោគអេដស៍អាចចម្លងមេរោគអេដស៍ទៅកូនរបស់គាត់បាននៅពេលមានផ្ទៃពោះ នៅពេលឈឺពោះសំរាល និងនៅពេលបំបៅដោះកូន ។
- ការធ្វើតេស្តឈាមមិនតំរូវឱ្យបង់ប្រាក់ទេហើយ ការទទួលសេវាព្យាបាលថែទាំចំពោះអ្នកផ្ទុកមេរោគអេដស៍ក៏គ្មានការបង់ប្រាក់ដែរ ។
- ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍មិនគ្រាន់តែបង្ការការចម្លងមេរោគអេដស៍ពីម្ដាយទៅកូនតែប៉ុណ្ណោះទេ តែថែមទាំងអាចពន្យារអាយុជីវិតអ្នកផ្ទុកមេរោគអេដស៍ឱ្យរស់នៅបានយូរអង្វែងច្រើនឆ្នាំផងដែរ ។

ជាងនេះទៅទៀត ឆ្មបត្រូវដឹងអំពីទីតាំងនៃសេវាផ្ដល់ប្រឹក្សានិងធ្វើតេស្តឈាមដែលស្ថិតនៅជិតបំផុត ។ ឆ្មបត្រូវបំពេញលិខិតបញ្ជូន និងត្រូវដឹងថា តើមានវត្តមានអង្គការណាខ្លះដែលធ្វើការនៅក្នុងសហគមន៍ដែលអាចឧបត្ថម្ភថ្លៃធ្វើដំណើរដល់ស្ត្រីមានផ្ទៃពោះឱ្យមកធ្វើតេស្តឈាម ។

[5] HIV estimate and projections 2006-2012,NCHADS/MoH.2007.

## ៨.៤ ឧបសម្ព័ន្ធទី៤: និយមន័យនៃសូចនករជាតិសំខាន់ៗ

| សូចនករ | និយមន័យ | ប្រភពរបាយការណ៍ |
|---|---|---|
| **១) ចំនួន (%) សេវាថែទាំផ្ទៃពោះដែលធ្វើតេស្តឈាមរកមេរោគអេដស៍** | | |
| **ភាគយក** | ចំនួនគ្លីនិកថែទាំផ្ទៃពោះដែលមានសេវាធ្វើតេស្តឈាម | របាយការណ៍ពីមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក |
| **ភាគបែង** | ចំនួនគ្រឹះស្ថានសុខាភិបាលទាំងអស់ដែលមានសេវាថែទាំផ្ទៃពោះ | របាយការណ៍ពីមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក |
| **២) ចំនួន (%) ស្រុកប្រតិបត្តិដែលមានសេវាបង្ការការចម្លងមេរោគអេដស៍យ៉ាងតិចមួយកន្លែង** | | |
| **ភាគយក** | ចំនួនស្រុកប្រតិបត្តិដែលមានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន | របាយការណ៍ពីមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក |
| **ភាគបែង** | ចំនួនស្រុកប្រតិបត្តិទាំងអស់ដែលកំពុងមានដំណើរការ | របាយការណ៍ពីមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក |
| **៣) ចំនួន (%) ស្ត្រីមានផ្ទៃពោះដែលមកទទួលសេវាថែទាំផ្ទៃពោះនៅមណ្ឌលដែលមានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនបានធ្វើតេស្តឈាមរកមេរោគអេដស៍និងទទួលលទ្ធផលតេស្ត** | | |
| **ភាគយក** | ចំនួនស្ត្រីមានផ្ទៃពោះដែលមកទទួលសេវាថែទាំផ្ទៃពោះនៅមណ្ឌលដែលមានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនបានធ្វើតេស្តឈាមរកមេរោគអេដស៍ និងទទួលលទ្ធផលតេស្តក្នុងរយៈពេល១២ខែកន្លងទៅ | របាយការណ៍ពីមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក |
| **ភាគបែង** | ចំនួនស្ត្រីមានផ្ទៃពោះទាំងអស់ដែលបានដែលមកទទួល **សេវាថែទាំផ្ទៃពោះនៅឯមណ្ឌលដែលមានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន**ក្នុងរយៈពេល១២ខែកន្លងទៅ | របាយការណ៍ពីមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក |
| **៤) ចំនួន (%) ស្ត្រីមានផ្ទៃពោះនៅទូទាំងប្រទេសបានធ្វើតេស្តឈាមរកមេរោគអេដស៍និងទទួលលទ្ធផលតេស្ត** | | |
| **ភាគយក** | ចំនួនស្ត្រីមានផ្ទៃពោះនៅទូទាំងប្រទេសបានធ្វើតេស្តឈាមរកមេរោគអេដស៍ និងទទួលលទ្ធផលតេស្តក្នុងរយៈពេល១២ខែកន្លងទៅ | របាយការណ៍ពីមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក |
| **ភាគបែង** | ចំនួនស្ត្រីមានផ្ទៃពោះ**នៅទូទាំងប្រទេស**ដែលរំពឹងនឹងផ្តល់កំណើតឱ្យទារកក្នុងរយៈពេល១២ខែកន្លងទៅ | - របាយការណ៍ប៉ាន់ប្រមាណកំណើនប្រជាជនពីវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ<br>- របាយការណ៍សុខភាពប្រជាសាស្ត្រកម្ពុជា |

| | | |
|---|---|---|
| **៥) ចំនួន (%) ដៃគូស្ត្រីបានធ្វើតេស្តឈាមរកមេរោគអេដស៍ និងទទួលលទ្ធផលតេស្ត** | | |
| **ភាគយក** | ចំនួនដៃគូស្ត្រីបានធ្វើតេស្តឈាមរកមេរោគអេដស៍និងទទួលលទ្ធផលតេស្តនៅក្នុងរយៈពេល ១២ខែកន្លងទៅ | របាយការណ៍ពីមជ្ឈមណ្ឌល ជាតិគាំពារមាតានិងទារក |
| **ភាគបែង** | ចំនួនស្ត្រីមានផ្ទៃពោះទាំងអស់ដែលមកទទួលសេវាថែទាំផ្ទៃពោះយ៉ាងតិចម្តងនៅក្នុងរយៈពេល១២ខែកន្លងទៅ | របាយការណ៍ពីមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក |
| **៦) ចំនួន (%) ស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ដែលបានទទួលឱសថប្រឆាំងមេរោគអេដស៍ ដើម្បីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន** | | |
| **ភាគយក** | ចំនួនស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ដែលបានទទួលឱសថប្រឆាំងមេរោគអេដស៍ ដើម្បីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅក្នុងរយៈពេល១២ខែកន្លងទៅ | របាយការណ៍ពីមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក |
| **ភាគបែង** | ចំនួនស្ត្រីផ្ទុកមេរោគអេដស៍ទាំងអស់ដែលរំពឹងថានឹងផ្តល់កំណើតដល់ទារកនៅក្នុងរយៈពេល១២ខែកន្លងទៅ | - របាយការណ៍ប៉ាន់ប្រមាណកំណើនប្រជាជនពីវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ<br>- របាយការណ៍សុខភាពប្រជាសាស្ត្រកម្ពុជា<br>- របាយការណ៍អង្កេតអត្រាឆ្លងនៃមេរោគអេដស៍ |
| **៧) ចំនួន (%) កុមារដែលកើតពីម្តាយផ្ទុកមេរោគអេដស៍ចាប់ផ្តើមបង្ការ ដោយប្រើឱសថកូទ្រីម៉ុកសាសុលក្នុងកំឡុង ពេលពីរខែដំបូងនៃកំណើត** | | |
| **ភាគយក** | ចំនួនកុមារដែលកើតពីម្តាយផ្ទុកមេរោគអេដស៍ចាប់ផ្តើមបង្ការដោយប្រើឱសថកូទ្រីម៉ុកសាសុលក្នុងកំឡុងពេលពីរខែដំបូងនៃកំណើត | របាយការណ៍ពីមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និងកាមរោគ |
| **ភាគបែង** | ចំនួនកុមារប្រឈមទាំងអស់ដែលម្តាយបានទៅសំរាលកូននៅមន្ទីរពេទ្យ | របាយការណ៍ពីមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក |
| **៨) ចំនួន (%) កុមារដែលកើតពីម្តាយផ្ទុកមេរោគអេដស៍បានធ្វើតេស្តឈាមរកមេរោគអេដស៍ក្នុងកំឡុងពេល ១២ខែនៃកំណើត** | | |
| **ភាគយក** | ចំនួនកុមារដែលកើតពីម្តាយផ្ទុកមេរោគអេដស៍បានធ្វើតេស្តឈាមរកមេរោគអេដស៍ក្នុងកំឡុងពេល១២ខែ នៃកំណើត | របាយការណ៍ពីមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និងកាមរោគ |
| **ភាគបែង** | ចំនួនស្ត្រីផ្ទុកមេរោគអេដស៍ទាំងអស់ដែលរំពឹងថានឹងផ្តល់កំណើតដល់ទារកនៅក្នុងរយៈពេល១២ខែកន្លងទៅ | - របាយការណ៍ប៉ាន់ប្រមាណកំណើនប្រជាជនពីវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ<br>- របាយការណ៍សុខភាពប្រជាសាស្ត្រកម្ពុជា<br>- របាយការណ៍អង្កេតអត្រា ឆ្លងនៃមេរោគអេដស៍ |

| ៩) ចំនួន (%) កុមារដែលកើតពីម្តាយផ្ទុកមេរោគអេដស៍បានចិញ្ចឹមដោយទឹកដោះម្តាយសុទ្ធ ឬដោយទឹកដោះគោម្សៅសុទ្ធ រយៈពេល៦ខែដំបូង | | |
|---|---|---|
| **ភាគយក** | ចំនួនកុមារដែលកើតពីម្តាយផ្ទុកមេរោគអេដស៍បានចិញ្ចឹមដោយទឹកដោះម្តាយសុទ្ធ ឬ ដោយទឹកដោះគោម្សៅសុទ្ធរយៈពេល៦ខែដំបូង | របាយការណ៍ពីមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក |
| **ភាគបែង** | ចំនួនស្ត្រីផ្ទុកមេរោគអេដស៍ទាំងអស់ដែលរំពឹងថានឹងផ្តល់កំណើតដល់ទារកនៅក្នុងរយៈពេល១២ខែកន្លងទៅ | -របាយការណ៍ប៉ាន់ប្រមាណកំណើនប្រជាជនពីវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ<br>-របាយការណ៍សុខភាពប្រជាសាស្ត្រកម្ពុជា<br>-របាយការណ៍អង្កេតអត្រាឆ្លងនៃមេរោគអេដស៍ |
| **១០) ចំនួន(%)កុមារឆ្លងមេរោគអេដស៍ពីម្តាយ** | | |
| សុចនករនេះ គឺជាសុចនករយូអិនហ្គាស។ ជាធម្មតាគេធ្វើការគណនាតាមរយៈម៉ូឌែលកំព្យូទ័រ។ សុចនករនេះគ្មានភាគយក ឬភាគបែងទេ។ តាមការណែនាំរបស់យូអិនហ្គាស សុចនករនេះត្រូវបានគណនាដោយគិតមធ្យមភាគនៃអត្រាចម្លងមេរោគអេដស៍ពីម្តាយទៅកូននៃស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ រាប់ទាំងអ្នកដែលបានទទួល ឬមិនបានទទួលឱសថប្រឆាំងមេរោគអេដស៍។ | | |